CON-86

ក្រុមទីប្រឹក្សាអចិន្ត្រៃយ DFID/SIDA

# របាយការណ៍

# ស្តីពី

# ការសិក្សានៃការអនុវត្តមូលនិធិវិនិយោគខេត្ត~ក្រុង

# កម្មវិធីសិលា

រ៉ូប៊ិន ប៊ិដឌុលហ្វ

៣១ សីហា ២០០៤

ទីប្រឹក្សា SPM

OPM
Oxford
Policy
Management

361.25 PAT-
SEILA-FIN

library.ncdd.gov.kh
007659

**សមាជិកក្រុមស្រាវជ្រាវ**

លោក **រ៉ូប៊ិន ប៊ិដដុលហ្វ** ជាទីប្រឹក្សា និង អ្នកនិពន្ធ

លោក **ភុយ ប្អួយ** ក្រសួងមហាផ្ទៃ

លោក **កែវ ឫទ្ធា** ក្រសួងផែនការ

លោក **ជិម ផារិន** ក្រុមប្រឹក្សារដ្ឋមន្ត្រី

លោក **តែ សំបូរ** អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

លោក **ឌី ផល្លា** ទីប្រឹក្សា PLG ខេត្តតាកែវ

កញ្ញា **សុក ចាន់ស៊ីនួន** មន្ទីរផែនការខេត្តបាត់ដំបង

កញ្ញា **អ៊ុក បូរីណា** មន្ទីរផែនការខេត្តពោធិសាត់

361.25

PAT.SEILA.FIN

sh: MAE

# តារាងមាតិកា

តារាងមាតិកា........................................................................................ ១

បញ្ជីតារាង........................................................................................ ៤

សេចក្តីសង្ខេប........................................................................................ ៥

សាវតា........................................................................................ ៥

ការវិភាជន៍នៃមូលនិធិវិនិយោគខេត្ត-ក្រុង........................................................................................ ៥

ការកំណត់គំរោងការ........................................................................................ ៦

ប្រសិទ្ធិភាពនៃគំរោង........................................................................................ ៨

ការតាមពិនិត្យមើលកិច្ចសន្យាបណ្តោះអាសន្ន........................................................................................ ៩

ការបំពេញឱ្យគ្នារវាងមូលនិធិឃុំ-សង្កាត់ (CSF) និងមូលនិធិវិនិយោគខេត្ត-ក្រុង ( PIF)............. ១០

ការផ្តោតលើភាពក្រីក្រ និងទំនាក់ទំនងជាមួយយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ...................... ១១

អនុសាសន៍សំខាន់ៗ........................................................................................ ១២

គោលបំណងនៃការសិក្សា........................................................................................ ១៣

កំណែទំរង់វិស័យសាធារណៈនៅកម្ពុជា........................................................................................ ១៣

វិធីសាស្រ្ត........................................................................................ ១៥

សេចក្តីសង្ខេបនៃវិធីសាស្រ្ត........................................................................................ ១៥

ស្ថានភាពមិនអំណោយផល........................................................................................ ១៦

១. របកគំហើញនៃការសិក្សា........................................................................................ ១៦

១.ក. ការវិភាជន៍មូលនិធិវិនិយោគខេត្ត ដោយគ.ជ.ន.ស........................................................................................ ១៦

ការពិភាក្សា........................................................................................ ១៨

ការវិភាជន៍ដោយសមធម៌ និងតម្លាភាព........................................................................................ ១៨

ទំនាក់ទំនងរវាងមូលនិធិវិនិយោគខេត្តជាមួយនឹងចំណូលខេត្ត........................................................................................ ១៩

ការកំណត់ថវិកាជាមុនដោយ គ.ជ.ន.ស សំរាប់វិស័យយេនឌ័រ........................................ ២០

ការកំណត់ថវិកាជាមុនដោយ គ.ជ.ន.ស សំរាប់វិសយ័ផែនការ........................................ ២០

អនុសាសន៍លើការវិភាជន៍មូលនិធិវិនិយោគខេត្តដោយ គ.ជ.ន.ស........................................ ២១

១.ខ. ការវិភាជន៍មូលនិធិវិនិយោគខេត្ត ដោយ គ.អ.ជ.ខ........................................ ២១

សាវតា........................................ ២១

របកគំហើញ និងការពិភាក្សា........................................ ២២

ការវិភាជន៍ថវិកាទៅមន្ទីរ........................................ ២២

ការវិភាជន៍ថវិកាជាពីរដំណាក់កាល ៨០% និង២០%........................................ ២៦

តើមានឧទ្ទានុសិទ្ធច្រើនប៉ុណ្ណា?........................................ ២៧

តើនរណាខ្លះបានចូលរួមការវិភាជន៍ថវិកា?........................................ ២៨

មន្ទីរដែលរួញរា និងបានទទួលមូលនិធិច្រើនហួស........................................ ២៩

ការត្រួតពិនិត្យដំណើការបែងចែកថវិកានៅថ្នាក់ខេត្ត-ក្រុង........................................ ៣០

អនុសាសន៍លើការវិភាជន៍ថវិកានៃមូលនិធិវិនិយោគខេត្ត តាមរយៈ គ.អ.ជ.ខ/គប្រ........................................ ៣១

២. ការកំណត់គំរោងតាមរយៈបណ្តាមន្ទីរជំនាញ........................................ ៣១

សាវតា........................................ ៣១

របកគំហើញ និងការពិភាក្សា........................................ ៣១

ការកំណត់សកម្មភាពតាមបណ្តាមន្ទីរជំនាញ........................................ ៣១

ក្នុង និងក្រៅអាទិភាពឃុំ-សង្កាត់........................................ ៣៣

ការជ្រើសរើសទីតាំងសកម្មភាពដោយបណ្តាមន្ទីរជំនាញ........................................ ៣៥

អនុសាសន៍លើការកំណត់គំរោង........................................ ៣៧

៣. ប្រសិទ្ធិភាពនៃគំរោង........................................ ៣៧

ការវាយតំលៃសកម្មភាពគំរោងមូលនិធិវិនិយោគខេត្ត........................................ ៣៧

ការទទួលខុសត្រូវសំរាប់វាយតំលៃ........................................ ៣៧

ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលា........................................ ៣៩

ការវាយតំលៃបញ្ចប់គំរោងឆ្នាំ២០០៣ លទ្ធផលបញ្ជីសំនួរ........................................ ៣៩

ករណីសិក្សា: របកគំហើញនិងបញ្ហា មកពីគំរោង៥នៃមូលនិធិវិនិយោគខេត្ត........................................ ៤១

សហគមន៍នេសាទ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់)........................................ ៤១

បណ្ណាញធារាសាស្ត្រ ( មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង)........................................ ៤៤
បង្គន់អនាម័យគ្រួសារ ( មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបន្ទាយមានជ័យ)........................................ ៤៧
សេវាសុខភាពជាមូលដ្ឋាននៅថ្នាក់ឃុំ ( មន្ទីរសុខាភិបាល ខេត្តបាត់ដំបង)........................................ ៤៩
ការពង្រឹងគណៈកម្មការកំរងសាលា ( មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង)........................................ ៥០
អនុសាសន៍លើប្រសិទ្ធភាពគំរោង........................................ ៥២
៤. ការអនុវត្តលើកិច្ចសន្យាបណ្តោះអាសន្ន........................................ ៥៣
លទ្ធផលមកពីប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់........................................ ៥៣
លទ្ធផលមកពីបញ្ជីសំនួរ........................................ ៥៣
លទ្ធផលមកពីការចុះទៅសិក្សាស្រាវជ្រាវនៅខេត្តប្រាំ........................................ ៥៦
ការពិភាក្សា........................................ ៥៧
ការវាយតំលៃលើការអនុវត្ត/មិនអនុវត្តនៅឆ្នាំមុន........................................ ៥៧
កិច្ចព្រមព្រៀង និងផែនការ សំរាប់អនាគត........................................ ៥៨
អនុសាសន៍លើការតាមដានកិច្ចព្រមព្រៀងបណ្តោះអាសន្ន........................................ ៥៩
៥. ចំនុចបន្ថែមរវាងមូលនិធិវិនិយោគខេត្ត និងមូលនិធិឃុំ-សង្កាត់........................................ ៥៩
ការផ្តល់មូលនិធិឃុំ-សង្កាត់លើហេដ្ឋារចនាសម្ព័ន្ធ........................................ ៥៩
នរណាជាអ្នកសំរេច ហើយផ្អែកលើមូលដ្ឋានអ្វី?........................................ ៦០
ឃុំទទួលយកការទទួលខុសត្រូវ........................................ ៦១
អនុសាសន៍ស្តីពីការពង្រឹងទំនាក់ទំនង **CSF-PIF**........................................ ៦៣
៦. ទំនាក់ទំនងការផ្តោតនៃភាពក្រីក្រ នឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ........................................ ៦៣
មូលនិធិអភិវឌ្ឍន៍ខេត្ត ( **PIF**) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ........................................ ៦៣
ការធ្វើឱ្យមន្ត្រីអាចបំពេញការងារតាមតួនាទីទទួលខុសត្រូវ........................................ ៦៥
មូលនិធិវិនិយោគខេត្តនិងកំណែទំរង់ការគ្រប់គ្រងចំណាយសាធារណៈ........................................ ៦៦
ការពាក់ពន្ធ័របស់ក្រសួងនានាក្នុងដំណើការមូលនិធិវិនិយោគខេត្ត........................................ ៦៦
ការកំណត់មុខងារ........................................ ៦៧
អ្វីដែលលេខាធិការដ្ឋានដឹកនាំកម្មវិធីសិលាត្រូវវាយតំលៃ........................................ ៦៧
ឆ្ពោះទៅកិច្ចសំរបសំរួលប្រទេសផ្តល់ជំនួយ........................................ ៦៨
អនុសាសន៍លើភាពក្រីក្រ និងចំណងភ្ជាប់ទៅនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ........................................ ៦៩

សរុបបញ្ជីអនុសាសន៍................................................................................................ ៧០
អនុសាសន៍លើការវិភាជន៍នៃមូលនិធិវិនិយោគខេត្ត-ក្រុងដោយ គ.ជ.ន.ស....................................... ៧០
អនុសាសន៍លើការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុង នៅ គប្រ នៃ គ.អ.ជ.ខ................................ ៧០
អនុសាសន៍លើការកំណត់គំរោង.................................................................................... ៧១
អនុសាសន៍លើប្រសិទ្ធិភាពនៃគំរោង................................................................................. ៧១
អនុសាសន៍លើការតាមដានកិច្ចព្រមព្រៀងបណ្តោះអាសន្ន......................................................... ៧២
អនុសាសន៍លើការពង្រឹងទំនាក់ទំនងរវាងមូលនិធិឃុំ-សង្កាត និងមូលនិធិវិនិយោគខេត្ត-ក្រុង............ ៧៣
អនុសាសន៍លើភាពក្រីក្រ និងចំណងភ្ជាប់ទៅនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ....................... ៧៤

ឧបសម្ព័ន ១: ល័ក្ខខ័ណ្ឌយោង (នៅឯកសារភាសាអង់គ្លេស)

ឧបសម្ព័ន ២: ឆ្លើយតបបញ្ជីសំនួរ (នៅរបាយការណ៍បន្ថែម)

ឧបសម្ព័ន ៣: បញ្ជីសកម្មភាព ឆ្នាំ ២០០៣ (នៅឯកសារភាសាអង់គ្លេស)

ឧបសម្ព័ន ៤: សេចក្ដីណែនាំសំរាប់ការវិភាជន៍ PIF ដោយគ.អ.ជ.ខ (នៅឯកសារភាសាអង់គ្លេស)

បញ្ជីតារាង

តារាង១: កិច្ចសន្យានិងការចំណាយមូលនិធិវិនិយោគខេត្តរបស់ PLG ឆ្នាំ២០០៣.................................. ១៧
តារាងទី ២: ការវិភាជន៍មូលនិធិវិនិយោគខេត្ត ឆ្នាំ ២០០៣............................................................ ២៤
តារាងទី ៣: ការវិភាជន៍មូលនិធិវិនិយោគខេត្ត ឆ្នាំ ២០០៤............................................................ ២៥
តារាងទី ៤: ប្រភពកិច្ចសន្យាបណ្តោះអាសន្នក្នុង CIP: ទិន្នន័យ២០០៣របស់ CDPD ពីខេត្ត-ក្រុង ២៣........ ៣៣
តារាងទី ៥: កិច្ចសន្យាបណ្តោះអាសន្នដែលបានចុះហត្ថលេខា ឆ្នាំ២០០៣ តាមបណ្ដាមន្ទីរជំនាញ(CDPD)....... ៣៣
តារាងទី ៦: លទ្ធផលការវាយតំលៃតាមលើគំរោងនៃមូលនិធិវិនិយោគខេត្ត (មកពីបញ្ជីសំនួរ)..................... ៣៩
តារាង ៧: ការតាមដានបន្តលើកិច្ចសន្យាបណ្តោះអាសន្ន............................................................ ៥៣
តារាង៨: ការតាមដានលើកិច្ចសន្យាបណ្តោះអាសន្ន: មួយឃុំក្នុងខេត្ត-ក្រុង.......................................... ៥៤
តារាង៩: ការតាមដានបន្តលើកិច្ចសន្យាបណ្តោះអាសន្ន.............................................................. ៥៥
តារាង១០: ការតាមដានលើកិច្ចសន្យាបណ្តោះអាសន្ន ក្នុងឃុំនិងស្រុកដែលបានជ្រើសរើស........................... ៥៦

# សេចក្តីសង្ខេប

## សាវតា

គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាបានវិភាជន៍ មូលនិធិវិនិយោគខេត្ត (PIF) មានតំលៃប្រមាណពីរលានដុល្លាអាមេរិក ក្នុងមួយឆ្នាំៗ ទៅគ្រប់បណ្តាខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា។ លើកលែង ថវិកាមួយចំនួនតូចដែលត្រូវបានកំណត់ទុកមុនសំរាប់សកម្មភាពផែនការ និងយេនឌ័រ រីឯមួយចំនែកធំនៃមូលនិធិនេះ ត្រូវផ្តល់ជាកញ្ចប់រួម។ ពោលគឺអភិបាលខេត្ត និងគណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ មានសិទ្ធិធ្វើការសំរេច លើចំនួនថវិកា ដែលត្រូវវិភាជន៍ បន្តទៅអោយបណ្តាវិស័យនានាក្នុងខេត្ត។

ការកំណត់សកម្មភាពគំរោងរបស់បណ្តាមន្ទីរជំនាញ ត្រូវបានយោងទៅតាមផែនការវិនិយោគឃុំ-សង្កាត់ (ដែលបញ្ចូលក្នុងតារាងម៉ាទ្រិចនៃសកម្មភាពជាអាទិភាពតាមស្រុក-ខណ្ឌ"DPAM")។ ក្រោយពេលមូលនិធិវិនិយោគខេត្ត ក្រុងត្រូវបានបែងចែកទៅអោយបណ្តាមន្ទីរជំនាញហើយ មន្ទីរជំនាញនិមួយៗ បានទៅចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក-ខ័ណ្ឌ និងចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ អំពីគំរោងទាំងឡាយដែលត្រូវអនុវត្ត។ បន្ទាប់មក មន្ទីរជំនាញបានចុះកិច្ចសន្យាជាមួយ នឹងគណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ ក្នុងការធានាផ្តល់សេវានានាដែលខ្លួនបានយល់ព្រមជាបណ្តោះអាសន្ន ក្នុងដំណើរការសមាហរណកម្ម ផែនការថ្នាក់ស្រុក-ខ័ណ្ឌ។

ការធ្វើផែនការ និងវិភាជន៍មូលនិធិវិនិយោគនៅថ្នាក់ខេត្ត បានអនុលោមទៅតាមសេចក្តីណែនាំរបស់ក្រសួងផែនការ លេខ២៦៨០ផក។ ទិដ្ឋភាពផ្សេងទៀតនៃការធ្វើផែនការ ការអនុវត្តន៍ ការចុះកិច្ចសន្យា ការត្រួតពិនិត្យ និងវាយតំលៃ ត្រូវបានចាត់ចែងតាមបទបញ្ញត្តិនានា របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា។

ការសិក្សាស្រាវជ្រាវនេះ គឺដើម្បីស្រង់យកនូវមេរៀន បទពិសោធន៍នានាពីការអនុវត្តន៍មូលនិធិវិនិយោគខេត្ត ជាពិសេសគឺដើម្បីប្រមើលមើលពីប្រសិទ្ធិភាពនៃនីតិវិធីវិភាជន៍មូលនិធិនៅថ្នាក់ជាតិនិងខេត្ត-ក្រុង ការកំណត់គំរោងប្រសិទ្ធភាពនៃសកម្មភាព និងការរៀបចំកម្មវិធីវិនិយោគតាមរយៈសិក្ខាសាលា សមាហរណកម្មផែនការ ស្រុក-ខ័ណ្ឌ។ ការសិក្សានេះមានបំណងស្វែងរកអនុសាសន៍មួយចំនួនសំរាប់អនុវត្តក្នុងអនាគតដ៏ខ្លីផង (ខួបថ្មីនៃមូលនិធិវិយោគខេត្ត-ក្រុង នឹងចាប់ផ្តើមនៅក្នុងរយៈពេលពីរ-បីសប្តាហ៍ខាងមុខនេះ) និងសំរាប់រយៈពេលវែងផង (ថាតើមូលនិធិវិនិយោគខេត្ត-ក្រុងអាចរួមចំណែកយ៉ាងដូចម្តេចក្នុងបរិបទកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ)។

## ការវិភាជន៍នៃមូលនិធិវិនិយោគខេត្ត-ក្រុង

ការវិភាជន៍ថវិកាពីថ្នាក់ជាតិទៅថ្នាក់ខេត្ត-ក្រុង បច្ចុប្បន្នបានអនុវត្តដោយថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដោយមានការជួយគាំទ្រពីប្រធានគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ច

មូលដ្ឋាន។ រូបមន្តដែលប្រើសំរាប់ការវិភាជន៍នេះគឺ បែងចែកស្មើគ្នានូវថវិកាជាមូលដ្ឋាន៤០% ចែកដោយផ្អែកលើកត្តាឃុំ-សង្កាត់ (ដូចជាចំនួនឃុំ-សង្កាត់ទាំងអស់នៅខេត្ត-ក្រុង) ៣០% និងដោយផ្អែកលើកត្តាប្រជាជន៣០%។ មានឱកាសក្នុងការកសាងជាប្រព័ន្ធនីតិវិធីគំរូមួយ សំរាប់ការវិភាជន៍ថវិកាពីថ្នាក់ជាតិទៅថ្នាក់ខេត្ត-ក្រុង ដោយរៀបចំនូវដំណើរការវិភាជន៍ ដែលច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយជាង សំរាប់ការវិភាជន៍ថវិកានេះ។ មានឱកាសផងដែរក្នុងការបង្កើនសមភាពក្នុងយន្តការវិភាជន៍ថវិកានេះ ដោយរាប់បញ្ចូលនូវ កត្តាភាពក្រីក្រទៅក្នុងរូបមន្ត។ តែនៅក្នុងដំណាក់កាលចំពោះមុខនេះ ហាក់ដូចជាមិនទាន់មានវិធានការណា អាចធ្វើឱ្យមានការផ្លាស់ប្តូរជាដុំកំភួន ដល់នីតិវិធីនៃការវិភាជន៍ថវិកានេះឡើយ។ ការចងភ្ជាប់មូលនិធិវិនិយោគខេត្ត ជាមួយនឹងកញ្ចប់ចំណូលផ្សេងៗទៀតរបស់ខេត្តអាចជាវិធីមួយល្អ សំរាប់ធ្វើឱ្យមូលនិធិវិនិយោគខេត្តក្លាយជាមូលធនចំបង និងផ្តល់ឱកាសពង្រឹងសមត្ថភាពមន្ត្រីជាតិក្នុងការគ្រប់គ្រងភាពស្មុគស្មាញនៃការផ្ទេរថ្នុរថវិកា រវាងស្ថាប័នរដ្ឋាភិបាលនានា ក្នុងបរិបទសារពើពន្ធបែបវិមជ្ឈការ។

ដំណើរការនៃការវិភាជន៍មូលនិធិវិយោគខេត្ត-ក្រុង ដោយគណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ មានបង្កប់នូវវិធានអភិបាលកិច្ចល្អ។ តម្លាភាពត្រូវបានបង្កើន នៅពេលដែលមន្ទីរជំនាញថ្នាក់ខេត្ត និងអភិបាលស្រុកនានា បានយល់ដឹងអំពីកម្មវិធីវិនិយោគ និងគំរោងការរបស់មន្ទីរនិមួយៗ តាមរយៈដំណើរការវិភាជន៍។ គណនេយ្យភាព ត្រូវបានធានា នៅពេលដែលមន្ទីរជំនាញទាំងឡាយ ត្រូវចុះកិច្ចសន្យាជាមួយស្ថាប័នគ្រប់គ្រងខេត្ត លើការប្រើប្រាស់មូលនិធិដែលខ្លួនទទួលបាន សំរាប់ផ្តល់សេវាទាំងបរិមាណនិងគុណភាព។ ការចូលរួមពីសំរេចបាន ដោយមន្ទីរជំនាញនិមួយៗត្រូវឡើងធ្វើបទបង្ហាញពីគំរោងនានារបស់មន្ទីរ និងប៉ុនប៉ងដើម្បីទទួលបានការវិភាជន៍ថវិកាច្រើនបំផុត។ ការសំរបសំរួល កិច្ចអភិវឌ្ឍន៍ក៏បានកើតឡើងផងដែរ ដោយថ្នាក់ខេត្ត-ក្រុងមានឱកាស ចាត់ចែងសំរួលប្រភពធនធានផ្សេងៗពីបណ្តាមន្ទីរនានា មកសំយោគបំរើឱ្យកិច្ចអភិវឌ្ឍន៍រួមរបស់ខេត្ត។ ទាំងអស់នេះធ្វើឱ្យមានភាពល្អប្រសើរជាចំបងនៅក្នុងប្រពន្ធ័ នៃការបែងចែកនិងប្រើប្រាស់ ធនធានរបស់ម្ចាស់ជំនួយនានា តាមរយៈការវិភាជន៍ថវិកា ពីថ្នាក់ជាតិដែលជាញឹកញាយមន្ទីរនានានៅថ្នាក់ខេត្ត-ក្រុង បានដឹងយ៉ាងតិចតួចនូវអ្វីដែលមន្ទីរផ្សេងទៀតកំពុងធ្វើ ។

ការវិភាជន៍ថវិកាសំរាប់យេនឌ័រ និងផែនការ ធានាការចំណាយជាអប្បបរិមាលើសកម្មភាពទាំងពីរនេះ។ អាចមានការរិះគន់បាន ថាសេវាផែនការមានលក្ខណៈជាប្រតិបត្តិការរដ្ឋបាលជាជាងការវិនិយោគ ហើយមិនគួរស្ថិតនៅក្នុងមូលនិធិវិនិយោគខេត្ត-ក្រុងឡើយ។ ដោយមិនរាប់ពីផលវិជ្ជមានផ្សេងទៀតនៃប្រព័ន្ធវិភាជន៍ថវិកានេះ ការកំណត់ជាមុននូវមូលនិធិសំរាប់វិស័យមួយចំនួន និងការផ្តល់អំណាចក្នុងការធ្វើសំរេចចិត្តនៅថ្នាក់ខេត្ត-ក្រុង សំរាប់វិស័យដទៃបញ្ជាក់ថាយ៉ាងហោចណាស់ក៏មានសេចក្តីសំរេច មួយចំនួនត្រូវជជែកវែកញែកនិងចរចារ នៅថ្នាក់ខេត្ត-ក្រុង។

**ការកំណត់គំរោងការ**

បណ្តាមន្ទីរជំនាញថ្នាក់ខេត្ត-ក្រុង បានយោងទៅដល់កត្តាជាច្រើន ដែលជះឥទ្ធិពលដល់ការកំណត់គំរោងការរួមមាន គោលនយោបាយរបស់ក្រសួង ទិន្នន័យក្រសួងលើសេវាគ្រប់ដណ្តប់ អាទិភាពនិងទិន្នន័យឃុំ/ស្រុក

និងយុទ្ធសាស្ត្រ របស់គណៈកម្មាធិការប្រតិបត្តិនៃគ.អ.ជ.ខ។ ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង កត្តាទាំងនេះគ្រាន់តែជានិយាមការដ៏ទូលាយមួយដែលនៅមានទុកចន្លោះសំរាប់ឱ្យមន្ទីរនានា មានលទ្ធភាពជ្រើសរើស និងប្រើគំនិតផ្តួចផ្តើមរបស់ខ្លួនបាន។ នៅក្នុងខេត្តមួយចំនួន ឥទ្ធិពលនៃផែនការមូលដ្ឋាន ត្រូវបានកាត់បន្ថយ ដោយសារតារាងម៉ាទ្រិចនៃសកម្មភាពជាអាទិភាពរបស់ស្រុកនិងឃុំ មិនត្រូវបានចែកផ្សព្វផ្សាយ មុនសិក្ខាសាលាសមាហរណកម្មផែនការស្រុក។ ហើយពេលខ្លះ ទោះជាតារាងម៉ាទ្រិចនោះ ត្រូវបានចែកផ្សាយមុនសិក្ខាសាលាក្តី ក៏នៅយឺតជាងការសំរេចចិត្តរបស់មន្ទីរជំនាញនានា លើគំរោងសកម្មភាពដែលត្រូវដាក់ស្នើថវិកា។ ការយោងទៅរកតារាងម៉ាទ្រិចកាលពីឆ្នាំមុនអាចជាវិធីមួយល្អជាង ក្នុងការធានាអោយគំរោងវិនិយោគរបស់មន្ទីរជំនាញនានា ឆ្លើយតបបានច្រើនទៅនឹងអាទិភាពរបស់មូលដ្ឋាន។

ក្នុងស្ថានភាពដែលតំរូវការសេវាសាធារណៈនៅជនបទមានទំហំធំធេង ហើយបច្ចុប្បន្នមិនទាន់មានអន្តរាគមន៍ដ៏សក្តិសិទ្ធិណាមកដោះស្រាយភាពក្រីក្រនៅឡើយនោះ ការជ្រើសរើសរវាងគំរោងនានានៅថ្នាក់ខេត្ត មិនជាប្រការគួបារម្ភឡើយ តែការជ្រើសរើសទីតាំងអនុវត្តន៍គំរោងទើបជាប្រការគួរគិតគូរខ្លាំង។ ពេលដែលមន្ត្រីខេត្ត-ក្រុង ត្រូវបានសួរអោយពន្យល់ការពារការជ្រើសរើសទីតាំងគំរោង ជានិច្ចជាកាលគឺថាជាតំរូវការរបស់មូលដ្ឋាន។ ការពន្យល់មិនសូវអោយហេតុផលដែលទាក់ទងទៅនឹង ការសំឡឹងមើលទូទាំងខេត្ត-ក្រុង ហើយបញ្ជាក់ពីមូលហេតុថាឃុំនេះ ឬសង្កាត់នោះ សក្តិសមនឹងទទួលបានគំរោងជាងឃុំ-សង្កាត់ផ្សេងៗទៀត។

ចំពោះគ្រប់ករណី ប្រធានមន្ទីរគួរផ្តល់យុត្តិកម្ម លើការជ្រើសរើសទីតាំងគំរោងរបស់ខ្លួននៅមូលដ្ឋាន ដោយយោងទៅតាមផែនទីទូទាំងខេត្ត-ក្រុង។ អភិបាលស្រុកគួរត្រូវបានអញ្ជើញ ឡើងផ្តល់យោបល់ និងសួរបំភ្លឺ ក្រោយការបង្ហាញទាំងនេះ។ ចំពោះការវិនិយោគដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រតាមរយៈអភិវឌ្ឍន៍សេដ្ឋកិច្ច អាជ្ញាធរខេត្តគួរមានអំណាច ក្នុងការកំណត់ទីតាំងដែលសមស្របនឹងគំរោងនោះ។ ចំពោះការវិនិយោគសង្គមកិច្ច (ឬដែលមិនមែនសេដ្ឋកិច្ច) គួអោយមានលក្ខណៈវិនិច្ឆ័យមួយដែលតឹងរឹងជាង។ ទីមួយ គ្រប់ឃុំ-សង្កាត់ដែលនៅ មិនទាន់ទទួលបាននូវសេវាជាមូលដ្ឋាន គួរត្រូវបានកំណត់នៅលើផែនទីខេត្ត។ ទីពីរ គប្បីប្រើទិន្នន័យដែលពាក់ពន្ធ័ (ឧ: ផែនទី បង្ហាញពីទីតាំងភាពក្រីក្រផ្អែកលើអាហារូបត្ថម្ភជាមូលដ្ឋាន របស់កម្មវិធីស្បៀងអាហារពិភពលោក) ដើម្បីចាត់ថ្នាក់ភាពក្រីក្រ ឃុំនានាដែលមានតំរូវការសេវា។ គំរោងគួរតាំងនៅឃុំ-សង្កាត់ដែលក្រជាងគេហើយខ្វះសេវា។

មានករណីខ្លះ ប្រធានមន្ទីរខេត្ត-ក្រុង សំដែងការព្រួយបារម្ភថា គំរោងមន្ទីរដែលប្រើមូលនិធិវិនិយោគខេត្តមានសមាមាត្រទាប នៅក្នុងកម្មវិធីវិនិយោគឃុំ-សង្កាត់។ មានមន្ទីរខ្លះរហូតដល់ព្យាយាម ផ្សព្វផ្សាយឱ្យឃុំដឹងជាមុននូវគំរោងដែលខ្លួនគ្រោងធ្វើ ដើម្បីឱ្យឃុំអាចដាក់បញ្ចូលគំរោងទាំងនោះទៅក្នុងបញ្ជីអាទិភាពឃុំ-សង្កាត់។ ការធ្វើបែបនេះ បង្កជាគំរូដ៏គ្រោះថ្នាក់មួយ គឺថ្នាក់លើប្រាប់ថ្នាក់ក្រោមនូវអ្វីដែលគេត្រូវដាក់ក្នុងផែនការ ហើយអាចប្រឈមនឹងការធ្វើឱ្យខូចបង់ នូវគំនិតអភិវឌ្ឍន៍ "ពីក្រោមទៅលើ" ដែលកំពុងត្រូវបន្សាំតាមរយៈ ការកសាងផែនការ តាម

បែបចូលរួម។ ដូចនេះ វាជាប្រការសំខាន់ដែលគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវបញ្ជាក់ដល់ខេត្ត-ក្រុង ឡើងវិញថា ចំនួនគំរោងដែលគាំទ្រដោយមូលនិធិវិនិយោគខេត្ត "នៅក្នុងកម្មវិធីវិនិយោគឃុំ-សង្កាត់" មិនមែន ជាសូចនាករ វាស់ការអនុវត្តន៍ទេ ហើយតួលេខសមាមាត្របច្ចុប្បន្នដែលមានតែ ៣០% ក៏មិនគួរឱ្យព្រួយបារម្ភឡើយ។

**ប្រសិទ្ធិភាពនៃគំរោង**

ការពិនិត្យនូវមូលដ្ឋានទិន្នន័យនានា ជាពិសេសប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា (SCD) បានបញ្ជាក់ បន្ថែម លើពត៌មានដែលទទួលបានពីទីប្រឹក្សាត្រួតពិនិត្យនិងវាយតំលៃ (PLG)។ ប្រការទាំងនោះ មានដូចជា ទំហំ និងភាពលំអិតនៃការងារត្រួតពិនិត្យវាយតំលៃដែលបាននិងកំពុងអនុវត្តន៏នៅថ្នាក់ខេត្ត-ក្រុង មិនត្រូវបានធ្វើដូចគ្នា ទាំងស្រុងនៅថ្នាក់ជាតិឡើយ ព្រោះថ្នាក់ជាតិផ្តោតខ្លាំងតែលើការប្រមូលពត៌មានតាមដានត្រួតពិនិត្យប៉ុណ្ណោះ ដូចជា តាមដានតែធនធាន សកម្មភាព និងលទ្ធផល ប៉ុន្តែមិនបានសំឡឹងមើលនូវ ប្រសិទ្ធិភាព និងការជះឥទ្ធិពល របស់លទ្ធ ផលទាំងនោះ ឬបទពិសោធន៏ជាក់ស្តែងឡើយ។ មានការងារមួយចំនួនដែលមានសក្តានុពលអាចរៀបចំបន្ថែម លើ ប្រព័ន្ធ័ដែលមានរួចហើយនៅថ្នាក់ខេត្ត-ក្រុង ដើម្បីអោយគ.ជ.ន.ស មានពត៌មានស្តីពីការវាយតំលៃច្រើនជាងមុន ហើយ ដែលអាចមានប្រយោជន៍ច្រើនសំរាប់ម្ចាស់ជំនួយ។ វាច្បាស់លាស់ហើយថា មិនចាំបាច់អោយមានការពង្រឹងសមត្ថភាព បន្ថែមច្រើនដល់អគ្គលេខាធិការដ្ឋាន គ.ជ.ន.ស ដើម្បីវាយតំលៃលើរាល់សេវាទាំងអស់ ដែលបានផ្តល់ដោយមន្ទីរនានា នៅតាមខេត្ត-ក្រុងឡើយ។ អគ្គលេខាធិការដ្ឋាន គ.ជ.ន.ស គួព្យាយាមបញ្ចុះបញ្ចូលឱ្យមានការពង្រឹងសមត្ថភាពដល់ ក្រសួងពាក់ពន្ធ័នានា ដើម្បីវាយតំលៃលើការអនុវត្តន៏របស់បណ្តាមន្ទីរជាខ្សែបណ្តោយនៅថ្នាក់ខេត្ត-ក្រុងនិមួយៗ ដោយ ផ្តោតលើការកសាងគោលនយោបាយក្រសួង សំរាប់ប្រើក្នុងការចាត់ចែងសំរបសំរួលជំនួយពីប្រភពផ្សេងៗ និង ពង្រឹង ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់ថ្នាក់ជាតិ លើការវិនិយោគសំរាប់កិច្ចអភិវឌ្ឍន៍។

ពត៌មានដែលប្រមូលបានតាមរយៈបញ្ជីសំនួរ បង្ហាញថាមានខេត្តក្រុងមួយចំនួន (ដូចជាតាកែវ ឧត្តរមានជ័យ សៀមរាប រតនៈគីរី) បានចាប់ផ្តើមរួចហើយនូវការវាយតំលៃលើការងារឆ្នាំ២០០៣។ នេះអាចជា បទពិសោធន៏ដ៏មាន សារៈសំខាន់ សំរាប់ការពង្រឹងសមត្ថភាពថ្នាក់ខេត្ត-ក្រុង។

ការចុះពិនិត្យមើលពត៌មានលំអិតស្តីពីការអនុវត្តន៍ គំរោងចំនួន៥ដែលគាំទ្រដោយមូលនិធិវិនិយោគខេត្ត លើ វិស័យនិងខេត្តផ្សេងៗគ្នា បានរកឃើញថា គ្រប់សកម្មភាពទាំង៥នោះ មានផ្សារភ្ជាប់ទៅនឹង យុទ្ធសាស្ត្រជាតិដើម្បី កាត់បន្ថយភាពក្រីក្រ (NPRS) និងជាសក្តានុពល ពីព្រោះជះឥទ្ធិពលបួយចំនួនដល់ការកាត់បន្ថយភាពក្រីក្រ។ គំរោង ធំជាងគេក្នុងចំណោមនោះ គឺការជួសជុលឡើងវិញនូវប្រឡាយស្រោចស្រពមួយ មានតំលៃ២៥.០០០ដុល្លាអាមេរិក មានប្រវែងពីរគីឡូម៉ែត្រ ហើយមានផ្តល់ផលប្រយោជន៏ដល់ប្រជាពលរដ្ឋ៩៧គ្រួសារ។ នៅក្នុងឆ្នាំដំបូង កសិករ ទាំងនោះរងការខាតបង់ជាច្រើនចំពោះបន្ទាប់ពីការប្រមូលផល ហើយប្រាក់ឧបត្ថម្ភសំរាប់ជួសជុល និងថែរក្សានានាក៏ មិនគ្រប់គ្រាន់។ គំរោងនេះអាចនឹងដំណើរការបានល្អ ប្រសិនបើមានប្រភពផ្តល់ទឹកធំជាងនេះ និងមានការចូលរួម

វិភាគទានសំរាប់ថែទាំពីកសិករច្រើនជាងនេះ។ បញ្ហាជាគន្លឹះដែលកើតឡើងចំពោះគំរោងនេះ គឺមិនមានការសិក្សាប្រសិទ្ធភាពសេដ្ឋកិច្ចឱ្យបានគ្រប់គ្រាន់ជាមុន។ គណៈកម្មាការប្រតិបត្តិនៃគ.អ.ជ.ខ គួរត្រូវបានលើកទឹកចិត្តឱ្យសាកល្បងប្រថុយ ក្នុងការគាំទ្រគំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចដែលគេជឿថាអាចមានជោគជ័យ ហើយគំរោងដែល មិនបានជោគជ័យល្អ ក៏មិនគួរជាក្តីអាម៉ាស់ឡើយ។ យ៉ាងហោចណាស់ក៏គំរោងនិមួយៗ ត្រូវមានការប៉ាន់ប្រមើលមើលជាមុននូវប្រសិទ្ធភាពតំលៃ និងផលប្រយោជន៍គំរោង ដែលអាចជាមូលដ្ឋានសំរាប់វាយតំលៃបាន។ ការប្រៀបធៀបរវាងលទ្ធផលដែលបានគ្រោងទុកក្នុងឯកសារ និងលទ្ធផលជាក់ស្តែង គឺជាបទពិសោធន៍ដែលអាចសិក្សានិងចងក្រងទុក។

មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានលើកគំរោងបង្កើតសហគមន៍នេសាទដើម្បីការពារធនធានត្រីក្នុងបឹងធម្មជាតិមួយដែលមើលទៅសមទំនងហើយមានប្រយោជន៍។ ប៉ុន្តែក្នុងនោះក៏មានការប្រថុយផងដែរ ជាមួយនឹងការផ្តល់នាទីឱ្យខេត្តជាអ្នកដឹកនាំសំរបសំរួលសហគមន៍ ដើម្បីការពារធនធានធម្មជាតិរបស់ពួកគេខ្លួនឯង។

មន្ទីរអភិវឌ្ឍន៍ជនបទ ឡើងគំរោងលើកកំពស់សុខភាព និងអនាម័យ តាមរយៈការគាំទ្រការសាងសង់បង្គន់អនាម័យតាមគ្រួសារចំនួន៣០ ក្នុងឃុំមួយ។ គំរោងនេះផ្តល់ផលប្រយោជន៍ផ្ទាល់សំរាប់តែគ្រួសារណាដែលធូរធារប៉ុណ្ណោះ ដោយសារតំលៃចូលរួមបដិភាគខ្ពស់ (ទុនបដិភាគ បូកនិងការសាងសង់ជញ្ជាំងនិងដំបូល) ដែលគ្រួសារអ្នកទទួលផលនិមួយៗត្រូវរ៉ាប់រង។ ក្នុងចំណោម៣០បង្គន់អនាម័យ មានតែ២៥បង្គន់ដែលបានសាងសង់រួច ដោយមិនបានបញ្ជាក់ឱ្យឃើញក្នុងរបាយការណ៍ឡើយ។ យើងមិនមែនជាជំនាញការផ្នែកសុខភាពសាធារណៈទេ ហើយក៏មិនបានពិនិត្យមើលគោលនយោបាយក្រសួងអភិវឌ្ឍន៍ជនបទលើការផ្តល់បង្គន់អនាម័យដែរ ប៉ុន្តែក៏អាចសន្និដ្ឋានបានថា ការសាងសង់បង្គន់ មិនមែនជាវិធីសាស្ត្រ ដ៏ល្អដើម្បី ពង្រឹងអនាម័យជនបទឡើយ។

គំរោងមួយរបស់មន្ទីរសុខាភិបាល ដែលផ្តល់សេវាតាមរយៈមណ្ឌលសុខភាពនានា ពិបាកនឹងធ្វើការ វាយតំលៃជាខ្លាំង។ មួយចំនែកគឺដោយសារភាពខ្សោយនៃវិធីសាស្ត្ររបស់ក្រុមសិក្សាស្រាវជ្រាវ និងមួយចំនែកទៀតគឺដោយសារមិនមានការចងក្រងឯកសារច្បាស់លាស់ថា តើមានសេវាអ្វីខ្លះដែលបានផ្តល់? ហើយផ្តល់ទៅឱ្យកន្លែងណាខ្លះ?។

ចំណែកឯគំរោងមួយរបស់មន្ទីរអប់រំ ដែលគាំទ្រការកសាងសមត្ថភាពដល់គណៈកម្មការសាលាកំរង មានបញ្ចូលនូវការធ្វើសិក្ខាសាលាមួយព្រឹក។ ក្រុមសិក្សាមិនអាចរកបាននូវពត៌មានស្តីពីផលប៉ះពាល់នៃ វគ្គបណ្តុះបណ្តាលនេះឡើយ។ ការនេះបានបង្ហាញពីភាពខ្សោយនៃវិធីសាស្ត្ររបស់ក្រុមសិក្សា តែក៏ដោយសារភាពមិនច្បាស់លាស់នៃគោលបំណងសិក្ខាសាលាដែរ។ នៅក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា លទ្ធផលរំពឹងទុករបស់សិក្ខាសាលា នេះមានសរសេរយ៉ាងខ្លីថា "កសាងសមត្ថភាព គណៈកម្មការសាលាកំរង"។

## ការតាមពិនិត្យមើលកិច្ចសន្យាបណ្តោះអាសន្ន

ដោយហេតុថាកិច្ចព្រមព្រៀងបណ្តោះអាសន្ន ត្រូវបានធ្វើឡើងតាមការរំពឹងទុកជាមុន នូវការគាំទ្រពីមូលនិធិវិនិយោគខេត្ត-ក្រុង ភាគច្រើននៃកិច្ចព្រមព្រៀងទាំងនោះគឺបានឈានទៅដល់ការអនុវត្តគំរោង។ កិច្ចព្រមព្រៀងដែល

មិនបានទទួលការតាមពិនិត្យ ច្រើនជាកិច្ចព្រមព្រៀងដែលធ្វើជាមួយអង្គការក្រៅរដ្ឋាភិបាល។ ហេតុផលគឺដោយសារអង្គការក្រៅរដ្ឋាភិបាលមិនមានពត៌មានច្បាស់លាស់ពីស្ថានភាពមូលនិធិរបស់ខ្លួន សំរាប់ធ្វើការប៉ាន់ប្រមាណឱ្យបានត្រឹមត្រូវ (មិនមែនគេមិនដឹងថាកិច្ចព្រមព្រៀងក្នុងសមាហរណកម្មផែនការថ្នាក់ស្រុក ដែលមិនបានអនុវត្តន៍ នឹងត្រូវលើកមករំលឹកជាថ្មីនាអនាគតកាលនោះទេ) ឬដោយសារអង្គការមួយចំនួន ប្រើប្រាស់កិច្ចព្រមព្រៀងបណ្ដោះអាសន្ន ជាឧបករណ៍សំរាប់ស្វែងរកមូលនិធិ។

ជាញឹកញយគេឃើញមានភាពមិនដូចគ្នា រវាងគំរោងដែលមន្ទីរជំនាញថ្នាក់ខេត្តបានអនុវត្តន៍រួច ទៅនឹងអ្វីដែលក្រុមប្រឹក្សា និងមេឃុំ ជឿថាមន្ទីរជំនាញបានធ្វើហើយមែន។ ការកសាងឯកសារសំរាប់បញ្ជាក់ថា គំរោងត្រូវបានធ្វើរួច ឬក៏ត្រូវបានលុបចោល នឹងមានប្រយោជន៍ច្រើនក្នុងករណីបែបនេះ។ បើគេថែមកូឡោនមួយទៀតទៅក្នុងទំរង់កិច្ចព្រមព្រៀងបណ្ដោះអាសន្ន សំរាប់ឱ្យឃុំ-សង្កាត់កត់សំគាល់ថែម នៅពេលបានពត៌មានពីអ្នកផ្ដល់សេវា (មន្ទីរ/អង្គការ) អាចនឹងជួយសំរួលបញ្ហានេះបាន។

ផ្ទុយពីការសង្កេតឃើញរបស់អ្នកដទៃទៀត មេឃុំ-ចៅសង្កាត់ ភាគច្រើនដែលស្រាវជ្រាវបានជួបសំភាសន៍មិនបានគិតថា សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ជាឱកាសដែលឃុំអាចទាក់ទាញមន្ទីរខេត្ត-ក្រុង និងអ្នកផ្ដល់សេវាផ្សេងៗទៀត ឱ្យទទួលខុសត្រូវលើគំរោងឃុំនោះទេ។ ដូច្នេះហើយ គួរតែបានឱកាសសំរាប់បញ្ជាក់ឡើងវិញដល់មេឃុំនានា នូវមុខងារជាមូលដ្ឋាននៃសមាហរណកម្មផែនការថ្នាក់ស្រុក។

## ការបំពេញឱ្យគ្នារវាងមូលនិធិឃុំ-សង្កាត់(CSF)និងមូលនិធិវិនិយោគខេត្ត-ក្រុង (PIF)

ដំណើរការអនុវត្តន៍មូលនិធិវិនិយោគខេត្ត-ក្រុងរួមបញ្ចូលនូវយន្ដការនានា សំរាប់ឱ្យមន្ទីរជំនាញ និងក្រុមប្រឹក្សាឃុំ-សង្កាត់ អាចដកពិសោធន៍ក្នុងការសំរបសំរួលផែនការរបស់ខ្លួន។ ឃុំ-សង្កាត់អាចរៀនសូត្រ ក្នុងការលើកសំណើពីតំរូវការនិងបំណងផ្សេងៗ ហើយខេត្ត-ក្រុង ចាប់មានទំលាប់ក្នុងការឆ្លើយតបទៅនឹងសំណើទាំងនោះ។ សមត្ថភាពទាំងនេះនឹងមានសារៈសំខាន់សំរាប់ទូទាំងប្រទេស ប្រសិនបើនិន្នាការឆ្ពោះទៅអភិបាលកិច្ចបែបវិមជ្ឈការនិងវិសហមជ្ឈការ នៅតែបន្ដដោយមានការគាំទ្រផ្ដល់នូវមូលនិធិដ៏សមស្រប។ ដូច្នេះមានករណីច្រើនណាស់ដែលគ្រប់ស្រុកគួរបានទទួលចំណែកខ្លះនៃមូលនិធិវិនិយោគខេត្ត-ក្រុង ហើយក៏ដូចគ្នាដែរសំរាប់ មន្ទីរជំនាញនានាដែលមានតួនាទី រួមចំណែកកាត់បន្ថយភាពក្រីក្រ (ប៉ុន្ដែមិនមែនគ្រប់មន្ទីរក្នុងគ្រប់ស្រុកនោះទេ)។

ចំពោះវិសយ័ណាមួយ ក្នុងទីកន្លែងនិងកាលវេលាណាមួយ អាចនឹងលេចចេញនូវហេតុផលគ្រប់គ្រាន់ក្នុងការប្រើមូលនិធិឃុំ-សង្កាត់លើគំរោងហេដ្ឋារចនាសម្ព័ន្ធ ហើយផ្ដោតមូលនិធិវិនិយោគខេត្ត-ក្រុង តែទៅលើសេវាមិនមែនហេដ្ឋារចនាសម្ព័ន្ធ។ ទោះយ៉ាងណាក្ដី នៅមិនទាន់មានហេតុផលរឹងមាំ សំរាប់ឱ្យលេខាធិការដ្ឋាន គជនស គួរជំរុញការប្រតិបត្តិបែបនេះនៅឡើយ។ ក្នុងលក្ខណៈដែល ការតំរង់ទិសពីថ្នាក់ជាតិមានឥទ្ធិពលលើការធ្វើ សេចក្ដីសំរេចចិត្ត

របស់មន្ទីរជំនាញ ក្នុងការជ្រើសរើសគំរោងនៃមូលនិធិវិនិយោគខេត្ត-ក្រុងនោះ ការជំរុញបែបនេះគួរចេញមកពីបណ្តាក្រសួងខ្សែបណ្តោយ។

ជាទំលាប់ ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានជាអ្នកទទួលផលប្រយោជន៍ នៃជំនួយនានាមកពី "ថ្នាក់លើ"។ គោលនយោបាយវិមជ្ឈការ និងមូលនិធិឃុំ-សង្កាត់ ត្រូវបានផ្តោតឆ្ពោះលើការគាំពារដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាតួអង្គសកម្ម ក្នុងការតាមឃ្លាំមើលសកម្មភាពអភិវឌ្ឍន៍នានានៅមូលដ្ឋាន ទាំងគុណភាពនិងតំលៃ ដោយបានទទួលតួនាទីជា "ម្ចាស់គំរោង"។ ឥរិយាបទដូចគ្នានេះ គួរត្រូវបានជំរុញឱ្យប្រកាន់យកផងដែរ លើរាល់កិច្ចអភិវឌ្ឍន៍នានាដែលអនុវត្តនៅថ្នាក់មូលដ្ឋាន មិនចំពោះថាអ្នកណាទទួលខុសត្រូវលើគំរោងនោះឡើយ។ វាជាប្រការសំខាន់ ដែលត្រូវមានការណែនាំច្បាស់លាស់ពីថ្នាក់ជាតិ ឱ្យឃុំ-សង្កាត់ដឹងថាពួកគេមានតួនាទីត្រូវធ្វើដូច្នេះ។ វិធានការមានប្រសិទ្ធិភាពសំរាប់ពង្រឹងការពាក់ពន្ធ័របស់ឃុំ-សង្កាត់ លើការអនុវត្តន៍មូលនិធិវិយោគខេត្ត-ក្រុង រួមមាន ការធានាឱ្យឃុំ-សង្កាត់មានក្នុងដៃនូវផែនការការងារនិងថវិកានៃអនុកិច្ចសន្យាទាំងអស់របស់ គបប្រ ដែលនឹងត្រូវអនុវត្តនៅក្នុងឃុំ-សង្កាត់ខ្លួន និងធានាឱ្យតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ បានទទួលនាទីចូលរួមក្នុងការវាយតំលៃបញ្ចប់គំរោង។

**ការផ្តោតលើភាពក្រីក្រ និងទំនាក់ទំនងជាមួយយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ**

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ភ) ត្រូវបានដាក់បញ្ចូលក្នុងដំណើរការ រៀបចំសមាហរណកម្មផែនការថ្នាក់ស្រុក តាមរយៈប្រកាសរបស់ក្រសួងផែនការ លេខ៦៨០។ នេះគឺជាទង្វើដ៏ត្រឹមត្រូវមួយ។ ការធ្វើវិសោធនកម្ម នឹងត្រូវរង់ចាំដល់ពេលដែល យ.ជ.ក.ភ ត្រូវធ្វើបច្ចុប្បន្នភាព។ ជាក់ស្តែង ការតំរង់នីតិវិធីទៅតាម យ.ជ.ក.ភ មិនបានជួយបន្ថែមការផ្តោតលើភាពក្រីក្រ នៅក្នុងការអនុវត្តន៍មូលនិធិវិនិយោគខេត្ត-ក្រុង នៅពេលបច្ចុប្បន្ននេះទេ ពីព្រោះថា យ.ជ.ក.ភ មានលក្ខណៈទូលំទូលាយពេក និងមិនមានការចាត់អាទិភាពច្បាស់លាស់។ ពោលគឺវិធីសាស្ត្រនេះ មិនបានបន្ថែមតំលៃអ្វី លើការធ្វើសេចក្តីសំរេចចិត្តផ្សេងៗឡើយ។

គ.ជ.ន.ស គួរតែចូលរួមជួយកែលំអ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ តាមវិធីពីរ។ ដោយប្រយោល គួរជួយបញ្ចុះបញ្ចូលបណ្តាក្រសួង ឱ្យពង្រឹងគោលនយោបាយវិស័យរបស់ខ្លួន និងពង្រឹងការវាយតំលៃនានា ដើម្បីអាចទទួលបានមេរៀនធ្វើបទពិសោធន៍ ពីការអនុវត្តន៍មូលនិធិវិនិយោគខេត្ត-ក្រុងនៃកម្មវិធីសិលា និងកម្មវិធី/គំរោងផ្សេងៗទៀត។ ដោយផ្ទាល់ គ.ជ.ន.ស គួរវាយតំលៃ និងចងក្រងបទពិសោធន៍អំពីផលវិជ្ជមាននានា ដែលបានមកពីការពង្រឹងអភិបាលកិច្ច ក្រោមការគាំទ្ររបស់កម្មវិធីសិលា។ ការវាយតំលៃទាំងនេះត្រូវឆ្លើយទៅនឹងសំនួរដូចជាៈ តើមាន លក្ខណៈពិសេសណាខ្លះនៃមូលនិធិវិយោគខេត្ត-ក្រុងដែលបង្កជាគំរូអភិបាលកិច្ចល្អ? តើលក្ខណៈទាំងនោះជះឥទ្ធិពល អ្វីលើការអនុវត្តន៍? តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យលក្ខណៈពិសេសទាំងនោះមានអត្ថិភាព និងប្រសិទ្ធិភាព? តើគេអាចច្របាច់បញ្ចូលលក្ខណៈពិសេសជាអភិបាលកិច្ចល្អទាំងនោះ ទៅក្នុងគោលនយោបាយជាតិនានា ដូចជា យ.ជ.ក.ភ បានដូចម្តេចខ្លះ?

ការធ្វើឱ្យប្រសើរឡើងនូវការសំរបសំរួល និងប្រសិទ្ធផលនៃទុនវិនិយោគសាធារណៈ ក្នុងប្រទេសកម្ពុជា អាចជួយបង្កើន ផលវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រ។ មូលនិធិវិនិយោគខេត្ត-ក្រុងអាចប្រើដើម្បីៈ ក) ទាញក្រសួងនានាឱ្យមានតួនាទីខ្លាំងជាងមុនក្នុងកិច្ចការរៀបចំគោលនយោបាយ ខ) ផ្តល់នូវយន្តការសំរបសំរួលមួយល្អប្រសើរ សំរាប់ "ម្ចាស់ជំនួយនានា" (ទាំងជំនួយនិងកំចី)។ មូលនិធិវិនិយោគខេត្ត-ក្រុង បានផ្តល់ឱកាសសំរាប់ម្ចាស់ជំនួយនានា រៀបចំផែនការ និងថវិកា ខេត្ត-ក្រុង បានប្រសើរជាងមុនៈ គិតតាំងពីការចូលរួមទុនគាំទ្រមូលនិវិនិយោគខេត្ត-ក្រុង រហូតដល់ការផ្តល់ពត៌មានទៅ គ.អ.ជ.ខ នៅរៀងរាល់ខែកញ្ញា អំពីគំរោងថវិកាសំរាប់វិស័យនានាក្នុងខេត្ត-ក្រុង។ អគ្គលេខាធិការដ្ឋាននៃ គ.ជ.ន.ស ត្រូវបានដាក់ឱ្យធ្វើការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបង្កើនថែមទៀតនូវកាលានុវត្តភាព នេះ។

**អនុសាសន៍សំខាន់ៗ:**

បញ្ជីអនុសាសន៍ពេញលេញមួយ ត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ នៃការសិក្សានេះ ហើយអនុសាសន៍សំខាន់ៗមួយចំនួនមានបង្ហាញដូចនៅខាងក្រោមនេះ។ អនុសាសន៍១-៣ នឹងធានាឱ្យការធ្វើសំរេចចិត្តអំពីមូលនិធិវិនិយោគខេត្តផ្តោតខ្លាំងជាងមុនលើភាពក្រីក្រ ដោយការតំរង់ទិសឱ្យសេវាសង្គមនានាបាញ់ឆ្ពោះទៅរកអ្នកដែលត្រូវការបំផុត និងធានាថារាល់គំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចនឹងត្រូវបានធ្វើយុត្តិកម្មជាដំបូង និងបន្ទាប់មកវាយតំលៃតាមរូបបែបសេដ្ឋកិច្ច។ អនុសាសន៍ទី ៤ និង៥ ទាក់ទងទៅនឹងការប្រើមូលនិធិវិនិយោគខេត្ត-ក្រុងជាយន្តការពង្រឹងតួនាទីស្ថាប័ន និងការកាត់បន្ថយភាពក្រីក្ររបស់ក្រសួងនានា ម្ចាស់ជំនួយអន្តរជាតិ និងអ្នកផ្តល់ហិរញ្ញប្បទាន។

១. បណ្តាមន្ទីរជំនាញខេត្ត-ក្រុង គួរធ្វើយុត្តិកម្មសំរាប់ការជ្រើសរើសទីតាំងគំរោងរបស់ខ្លួន ដោយប្រើប្រាស់ផែនទីខេត្ត-ក្រុង ហើយអភិបាលស្រុកគួរត្រូវបានអញ្ជើញឱ្យផ្តល់យោបល់ និងអនុសាសន៍ (ត្រូវកែសំរួលប្រកាសលេខ២៦៨០ របស់ក្រសួងផែនការ)។

២. ចំពោះសេវាសង្គមជាមូលដ្ឋាន លក្ខណៈវិនិច្ឆ័យដែលគួរប្រើសំរាប់ជ្រើសរើសទីតាំងគំរោងគឺៈ ១) កំណត់រកឃុំ-សង្កាត់ទាំងឡាយដែលនៅមិនទាន់បានទទួលសេវានេះក្នុងកំរិតអប្បបរិមា។ ២) ជ្រើសរើសឃុំ-សង្កាត់ដែលក្រីក្រជាងគេក្នុងចំណោមនោះដើម្បីវិនិយោគ(កែសំរួលប្រកាសលេខ២៦៨០របស់ក្រសួងផែនការ)។

៣. កិច្ចសន្យាសំរាប់គំរោងនានាដែលផ្តោតលើការអភិវឌ្ឍន៍សេដ្ឋកិច្ច គួររួមបញ្ចូលនូវការគណនាសាមញ្ញអំពីប្រសិទ្ធិភាពសេដ្ឋកិច្ច។ ការសិក្សានេះអាចគិតក្នុងកំរិតប្រហាក់ប្រហែល ដោយមានទាំងការប៉ាន់ស្មានតំលៃ និងផលប្រយោជន៍ (តំលៃវិនិយោគ ទិន្នផល ថ្លៃទីផ្សារ តំលៃប្រតិបត្តិការ និងការរំលោះ) សំរាប់ជាមូលដ្ឋានដល់ការវាយតំលៃ និងដកពិសោធន៍ (ត្រូវកែសំរួល ប្រកាសលេខ២៦៨០ របស់ក្រសួងផែនការ)។

៤. គ.ជ.ន.ស គួរបញ្ចុះបញ្ចូលឱ្យគ្រប់បណ្តាក្រសួង រៀបចំបង្កើតអង្គភាពវាយតំលៃ និងគោលនយោបាយ ដែលត្រូវទទួលខុសត្រូវលើការវាយតំលៃរាល់គំរោង នៅក្រោមវិស័យខ្លួន (ជាពិសេសការវាយតំលៃប្រៀបធៀប

គំរោងដែលគាំទ្រដោយម្ចាស់ជំនួយផ្សេងគ្នា) ដើម្បីកសាងគោលនយោបាយវិស័យដែល ប្រកបដោយភាពចុះសំរុង និងគ្រប់ជ្រុងជ្រោយ។

៥. គ.ជ.ន.ស គួរមានកិច្ចសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធានាថាម្ចាស់ជំនួយ និងអ្នកផ្តល់ហិរញ្ញប្បទាននានាសំរាប់កិច្ចអភិវឌ្ឍន៍ បានដឹងពីយន្តការសំរាប់ការសំរបសំរួលមូលនិធិជំនួយតាមរយៈដំណើរការមូលនិធិវិនិយោគខេត្ត-ក្រុង និងចាត់វិធានការដើម្បីធានានូវយន្តការនេះត្រូវបានប្រើប្រាស់។ ត្រូវផ្តល់អនុសាសន៍ឱ្យម្ចាស់ជំនួយនានា បញ្ជូនមូលនិធិខ្លួនតាមរយៈមូលនិធិវិនិយោគខេត្ត-ក្រុង។

## គោលបំណងនៃការសិក្សា

មានលក្ខខណ្ឌយោងសំរាប់ការសិក្សានេះ បានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារភាសាអង់គ្លេស) ហើយបានរួមបញ្ចូលការពិពណ៌នាមូលនិធិវិនិយោគខេត្តកម្មវិធីសិលា។ គោលបំណងនៃការសិក្សានេះគឺវាយតំលៃការអនុវត្តន៍មូលនិធិវិនិយោគខេត្ត-ក្រុង និងផ្តល់នូវអនុសាសន៍សំរាប់អនាគត។ ការសិក្សាវាយតំលៃនេះ រួមមានៈ

- ការវិភាជន៍មូលនិធិពីថ្នាក់ជាតិទៅឱ្យថ្នាក់ខេត្ត-ក្រុង និងថ្នាក់ខេត្ត-ក្រុងទៅឱ្យបណ្តាមន្ទីរជំនាញ
- ការកំណត់គំរោងនៅតាមមន្ទីរជំនាញ
- ប្រសិទ្ធិភាពនៃសកម្មភាព
- រៀបចំកម្មវិធីសកម្មភាព ជាពិសេសតាមរយៈសមាហរណកម្មផែនការថ្នាក់ស្រុក (DIW)

អនុសាសន៍មានរួមបញ្ចូលទាំងសំណួមពរជាពិសេស

- ថាតើ ដើម្បីឱ្យការអនុវត្តស៊ីគ្នារវាងមូលនិធិឃុំ-សង្កាត់ និងមូលនិធិវិនិយោគខេត្ត-ក្រុង
- ថាតើ ដើម្បីឱ្យមូលនិធិវិនិយោគខេត្ត-ក្រុងមានប្រសិទ្ធិភាពដល់ការកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅក្នុងបន្ទាត់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។

## កំណែទំរង់វិស័យសាធារណៈនៅកម្ពុជា

កំណែទំរង់មន្ត្រីរាជការស៊ីវិល មានការរីកចំរើនយ៉ាងតិចតួច បើគិតចាប់ពីក្រោយការដាក់ឱ្យប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣។ បញ្ជីមន្ត្រីរាជការស៊ីវិលមានអតិផរណាធ្ងន់ធ្ងរ ប្រាក់បៀវត្ស៍មានកំរិតទាបជ្រុលមិនអាចលើកទឹកចិត្តឱ្យមន្ត្រីធ្វើការបាន ហើយរដ្ឋាភិបាលដែលគ្រប់គ្រងអំណាចបានបង្ហាញនូវឆន្ទៈទាបក្នុងការដោះស្រាយបញ្ហាទាំងនេះ។ ព្រមជាមួយគ្នានេះ ភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ បានធ្វើឱ្យស្ថានការណ៍កាន់តែយ៉ាប់ថែមទៀត ដោយផ្តល់នូវជំនួយក្នុងទំរង់ជាគំរោងនានា ដែលបាក់បង្កើនថែមនូវភាពរួញរាដល់ក្រសួងមន្ទីរនានា និងកាត់បន្ថយនូវលទ្ធភាពមន្ត្រីរាជការស៊ីវិល ក្នុងការបំពេញកិច្ចការតាមតួនាទីរបស់ខ្លួន។ ផលប៉ះពាល់កើតមានជាពិសេសនៅពេល

ដែលម្ចាស់ជំនួយនានាប្រកាន់គោលជំហរថាមិនផ្តល់ប្រាក់ខែបន្ថែមដល់មន្ត្រីរាជការទេ ប៉ុន្តែនៅក្នុងការអនុវត្តន៏ជាក់ស្តែងគេបែរជាព្យាយាមផ្តល់កំរៃបន្ថែមដល់មន្ត្រីរាជការដែលធ្វើការបំរើក្នុងគំរោងរបស់ខ្លួន[១] ។

កំណែទំរង់ការគ្រប់គ្រងថវិកាសាធារណៈ ហាក់ទើបនឹងចាប់ផ្តើមជំហានដំបូងរបស់ខ្លួនប៉ុណ្ណោះ។ ការរៀបចំផែនការ ការរៀបចំគំរោងថវិកា និងការគ្រប់គ្រងចំណាយនៅមិនទាន់មានការផ្សារភ្ជាប់គ្នា។ អ្នកនយោបាយ និងអ្នកដឹកនាំជាន់ខ្ពស់កម្ពុជា ហាក់មានចំណូលចិត្តក្នុងការកៀងគរប្រភពចំណូល និងវិនិយោគលើកិច្ចអភិវឌ្ឍន៏ ដោយប្រើប្រាស់ប្រពន្ធ័ក្រៅផ្លូវការរបស់ខ្លួនជាង ហើយមានសញ្ញាតិចតួចណាស់ក្នុងការផ្លាស់ប្តូរនិន្នាការនេះដោយក្រុមអ្នកនយោបាយ។

ក្នុងបរិបទនេះ កម្មវិធីសិលាបានផ្តល់នូវការអនុវត្តភាពមួយដល់មន្ត្រីរាជការថ្នាក់ខេត្តក្នុងការបំពេញនាទីជាអ្នកផ្តល់សេវាតាមរូបភាពដែលអាចជាការត្រៀមទុកដ៏ល្អមួយសំរាប់កំណែទំរង់វិស័យសាធារណៈ។ ការយកចិត្តទុកដាក់ជាពិសេសក្នុងកម្មវិធីសិលា បានផ្តោតទៅលើការលើកកំពស់គុណភាពនៃទំនាក់ទំនងការងារ ដូចជាគណនេយ្យភាព ភាពអាចឆ្លើយតបបានទៅនឹងសំណើផ្សេងៗ ភាពអាចប្រមើលដឹងមុន ការចូលរួម និងការពង្រឹងសមត្ថភាព ក្នុងការផ្តល់សេវាជាទូទៅ។ ជាមួយនឹងការរួមចំនែកធ្វើឱ្យឃើញថា ឃុំ និងខេត្ត គឺជាថ្នាក់ថវិកាសំខាន់ក្នុងរដ្ឋាភិបាល និងការជួយពង្រឹងសមត្ថភាពថ្នាក់ទាំងពីរនេះក្នុងការផ្តល់សេវាអាទិភាពមួយចំនួន កម្មវិធីសិលាបានក្លាយជាចំណែកមួយនៃការកសាងគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ។ ទោះជាយ៉ាងណាក្តី បញ្ហាថាតើតួនាទី និងភារកិច្ចអ្វីខ្លះ ដែលគួរប្រគល់ទៅឱ្យថ្នាក់និមួយៗ នៅមិនទាន់មានចំលើយនៅឡើយទេ។

នៅថ្នាក់ឃុំ ការពិសោធន៏របស់កម្មវិធីសិលាស្តីពី ផ្ទេរិមជ្ឈការថវិការទៅកាន់អាជ្ញាធរមូលដ្ឋាន ត្រូវបានទទួលយកជាបណ្តើរៗ ដោយក្រសួងនានានៅថ្នាក់ជាតិ ហើយពេលនេះស្ទើរតែមិនមានរចនាសម្ពន្ធ័ជារបស់សិលាផ្ទាល់នៅថ្នាក់ឃុំទេ ។ មានសក្តានុពលភាពដែលកម្មវិធីសិលា អាចធ្វើការសាល្បងពិសោធន៏ ស្រដៀងគ្នានេះ សំរាប់រចនាសម្ពន្ធ័ថ្នាក់ខេត្ត ។ ក្នុងករណីនេះ បញ្ហានានាមានលក្ខណៈស្មុគ្រស្មាញជាងច្រើន ហើយក៏ត្រូវការឱ្យមានការរៀបចំគោលនយោបាយនានាត្រៀមទុកជាមុនច្រើនដែរ។

---

[១] សូមមើលឯកសាររបស់ CDRI លេខ ១៥ សំរាប់ពន្យល់លើបញ្ហាទាំងនេះ ដែលជាលទ្ធផល ។

## វិធីសាស្ត្រ

### សេចក្ដីសង្ខេបនៃវិធីសាស្ត្រ

ការសិក្សានៃមូលនិធិវិនិយោគខេត្តមានសមាសធាតុបីសំខាន់ៗ:

១. វាយតំលៃឡើងវិញរាល់ឯកសារជាគន្លឹះ និងមូលដ្ឋានទិន្នន័យសំខាន់ៗ

២. មានបញ្ជីសំនួរបានដាក់ជូនទៅគ្រប់មន្ទីរផែនការខេត្ត-ក្រុង នឹង

៣. ចុះសិក្សាវាយតំលៃជាគុណភាពលើគំរោងប្រាំដែលបានទទួលមូលនិធិវិនិយោគខេត្ត (PIF) ក្នុងខេត្តចំនួនប្រាំ។

ទីប្រឹក្សាអន្តរជាតិបានធ្វើការ រួមជាមួយក្រុមមន្ត្រីបង្គោលមកពី ក្រុមប្រឹក្សាកំណែទំរង់សាធារណៈ(ដែលមានទីតាំងនៅទីស្ដីការគណៈរដ្ឋមន្ត្រី) ក្រសួងមហាផ្ទៃ និងក្រសួងផែនការ។ សមាជិកបន្ថែមដែលបានចូលរួមក្នុងការងារនេះដែរត្រូវ បានជ្រើសមកពីមន្ទីរផែនការខេត្តចំនួន២នាក់ ផ្នែកគ្រប់គ្រងកិច្ចសន្យានៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា (គ.ដ.ន.ស) ចំនួន១នាក់ និងគំរោងភាពជាដៃគូរដើម្បីអភិបាលកិច្ច (PLG) ចំនួន១នាក់[២]។ សមាជិកដែលត្រូវបានជ្រើសរើសឱ្យចូលរួមការងារនេះគឺផ្អែកលើមូលដ្ឋានពីរ ត្រូវមានចំណេះដឹងនិងបទពិសោធន៍ទាក់ទងនឹងប្រធានបទនេះ និងជាមន្ត្រីក្នុងស្ថាប័នដែលពាក់ពន្ធ័នឹងវិសហមជ្ឈការ និងគោលនយោបាយកាត់បន្ថយភាពក្រីក្រ ដែលអាចជាកន្លែងធ្វើការផ្សព្វផ្សាយមិនផ្លូវការ នូវលទ្ធផលនៃការសិក្សានេះ។

កម្មវិធីការងារត្រូវបានរៀបចំដូចខាងក្រោម:

**សប្ដាហ៍ទី ០១:** ទីប្រឹក្សាបានរៀបចំសំភាសន៏នៅភ្នំពេញ ពិនិត្យស្រាវជ្រាវឯកសារដែលមានស្រាប់ មូលដ្ឋានទិន្នន័យនានា និងបណ្ដុះបណ្ដាលសមាជិកក្រុមស្នូល។ ចែកចាយបញ្ជីសំនួរទៅគ្រប់ខេត្ត-ក្រុង (ដែលបានបំពេញដោយ ប្រធានមន្ទីរផែនការ និងមន្ត្រី CAU ខេត្ត-ក្រុង)។

**សប្ដាហ៍ទី ០២:** បន្ទាប់មកក្រុមស្នូលចុះទៅអនុវត្តនៅខេត្តពោធិ៍សាត់ ដើម្បីធ្វើការសំភាសន៏ជាមួយមន្ត្រីអនុវត្តគំរោង ក្រុមប្រឹក្សាឃុំ ស្រុក និងថ្នាក់ខេត្ត។

**សប្ដាហ៍ទី ០៣:** ក្រុមស្នូលបានពង្រីកសមាជិកបួននាក់បន្ថែម ហើយនឹងបែងចែកជាបួនក្រុម ក្នុងមួយក្រុមធ្វើការមួយខេត្តដូចជា: ខេត្តព្រៃវែង កំពង់ឆ្នាំង បាត់ដំបង បន្ទាយមានជ័យ ហើយអនុវត្តដូចវិធីសាស្ត្រនៅខេត្តពោធិ៍សាត់។

**សប្ដាហ៍ទី ០៤:** ក្រុមស្នូលបានរៀបចំធ្វើការវិភាគលទ្ធផលការសិក្សាស្រាវជ្រាវមកពីបណ្ដាខេត្ត បូកសរុបលទ្ធផលរបស់បញ្ជីសំនួរ និងសរសេររបាយការណ៍ ដើម្បីធ្វើការបង្ហាញលទ្ធផល។

---

[២] ការចូលរួមមកពី PLG មិនបានគ្រោងទុកជាមុនទេ។ មន្ត្រីមកពីអង្គភាពកាត់បន្ថយភាពក្រីក្រនៃក្រសួងផែនការត្រូវបានបញ្ចូលជាសមាជិកក្រុម ប៉ុន្តែគាត់បោកចេញពីក្រុមក្រុមវិញ ដោយទុកឱ្យយើងស្វែងរកមនុស្សម្នាក់ដែលធ្លាប់ស្គាល់/ដឹងនូវបញ្ហាទាំងនោះ ពីប្រភពផ្សេងវិញ។ ដូច្នេះ យើងសូមថ្លែងអំណរគុណដ៏ជ្រាវជ្រៅដោយបានទទួលការសហការណ៍ពីក្រុម PLG នៅខេត្តតាកែវ និងទីប្រឹក្សាផែនការតាមដានត្រួតពិនិត្យ និងវាយតំលៃទាំងអស់។

**ស្ថានភាពមិនអំណោយផល**

- ការសិក្សាមានរយៈពេលបួនសប្តាហ៍ប៉ុណ្ណោះ ជាមួយនឹងការចុះទៅសិក្សានៅខេត្តទាំងប្រាំមានចំនួនពីរសប្តាហ៍ ក្នុង ចំណោមបួនសប្តាហ៍ ។
- លទ្ធភាពនៃការរៀបចំវាយតំលៃបែបបរិមាណមិនសូវជាក់លាក់ ដោយហេតុថាមូលដ្ឋានទិន្នន័យសំខាន់ៗពីរ កំពុងស្ថិតក្នុងការផ្លាស់ប្តូរស្ថានភាពៈ ការបញ្ចូលទិន្នន័យមិនទាន់បានបញ្ចប់ ឬមិនបានបូកសរុបទៅក្នុងមូលដ្ឋាន ទិន្នន័យរួមតែមួយ ។
- មូលដ្ឋានទិន្នន័យនានាដែលមានស្រាប់ផ្តោតខ្លាំងលើបំណងត្រួតពិនិត្យ (ធនធាន សកម្មភាព លទ្ធផល) ជាជាងការវាយតំលៃ (ផលប្រយោជន៍ ផលប៉ះពាល់ បទពិសោធន៍) ។ ប្រការនេះបាន កាត់បន្ថយលទ្ធភាព របស់របស់យើងដើម្បីពង្រីកនូវលទ្ធផលបានមកពីការចុះសំភាសន៍ដ៏តូចមួយដែលយើងបានជ្រើសរើសគំរូ ។
- បញ្ជីសំនួរដែលបានបញ្ជូនទៅមានរយៈពេលខ្លីពេក មិនតែប៉ុណ្ណោះមានសំនួរមួយចំនួនពិបាកយល់ ហើយករណី ខ្លះទៀតទីប្រឹក្សាបានជួយបំពេញមន្ត្រីផែនការ ។
- ការស្រាវជ្រាវនេះគួរមានពេលវេលាគ្រប់គ្រាន់ សំរាប់ធ្វើការជ្រើសរើសនិងរៀបចំសមាជិកក្រុម ឱ្យមានវចនាសម្ព័ន្ធច្បាស់លាស់ និងវិធីសាស្ត្រធ្វើការជាក់លាក់ជាងនេះ ។

## ១. របកគំហើញនៃការសិក្សា

### ១.ក. ការវិភាជន៍មូលនិធិវិនិយោគខេត្តដោយ គ.ជ.ន.ស

ការវាយតំលៃលើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងដំណើរការវិភាជន៍មូលនិធិវិនិយោគខេត្ត (PIF) ពីថ្នាក់ជាតិទៅខេត្ត-ក្រុង និងនៅក្នុងខេត្ត-ក្រុងទៅបណ្តាមន្ទីរវិស័យ និងពិនិត្យមើលការរៀបចំកម្មវិធីវិនិយោគ ឱ្យស្របទៅនឹងយុទ្ធសាស្ត្រថ្នាក់ជាតិ និងអាទិភាពរបស់មូលដ្ឋានតាមរយៈសិក្ខាសាលា សមាហរណកម្មថ្នាក់ ស្រុក-ខណ្ឌ (DIW) ។

មូលនិធិវិនិយោគខេត្តនៃកម្មវិធីសិលាមានចំនួនប្រហែល ២.០០០.០០០ ដុល្លាអាមេរិកក្នុងមួយឆ្នាំ សំរាប់ឆ្នាំ ២០០៣ និង២០០៤ ហើយសង្ឃឹមថានឹងមានចំនួនប្រហែល២.៥០០.០០០ដុល្លាអាមេរិក សំរាប់ឆ្នាំ២០០៥ ។ ការវិភាជន៍ថវិកា នេះបានផ្អែកលើរូបមន្តដូចដែលប្រើប្រាស់វិភាជន៍មូលនិធិវិនិយោគខេត្តទៅ ខេត្ត-ក្រុង សិលា ក្នុងកំឡុងពេលនៃកម្មវិធី CARERE2[៣] ។ រូបមន្តនេះផ្អែកលើកត្តាពីរៈ ចំនួនជាមូលដ្ឋាន ប្រជាជនក្នុងខេត្ត និងចំនួនឃុំ-សង្កាត់នៅក្នុងខេត្ត ។

[៣] សូមមើលឯកសាររបស់លោក Tracey-White (២០០២) ទំព័រ ១៥-២០

**តារាង១: កិច្ចសន្យានិងការចំណាយមូលនិធិវិនិយោគខេត្តរបស់ PLG ឆ្នាំ២០០៣**

| កូដ | ខេត្ត~ក្រុង | សរុបចំនួនកិច្ចសន្យា និង អនុកិច្ចសន្យា[៤] នៃ PLG | សរុបថវិកា (US$) | សរុបថវិកា ២០០៣ US$ | % ចំណាយ ២០០៣ |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ១៥ | ១១៤.៧០០ | ១១៣.០៤៦ | ៩៩ |
| ២ | បាត់ដំបង | ១៧ | ១៤៣.៦០០ | ១៣៨.៩៩១ | ៩៧ |
| ៣ | កំពង់ចាម | ១៥ | ២២៤.៩០០ | ២០១.៣២៥ | ៩០ |
| ៤ | កំពង់ឆ្នាំង | ១៦ | ១១១.០០១ | ១០១.៣២០ | ៩១ |
| ៥ | កំពង់ស្ពឺ | ១៥ | ១២៩.៨០០ | ១២២.៣០០ | ៩៤ |
| ៦ | កំពង់ធំ | ៧ | ១៦.១០០ | ១១.២៤៨ | ៧០ |
| ៧ | កំពត | ៧ | ១១.០៥៣ | ១០.៣២៨ | ៩៤ |
| ៨ | កណ្ដាល | ៧ | ១០.៨២០ | ១០.១២៤ | ៩៤ |
| ៩ | កោះកុង | ៧ | ៤.៨២៨ | ៤.៨២៨ | ១០០ |
| ១០ | ក្រចេះ | ១៥ | ៩០.១០០ | ៨១.៧៧៨ | ៩១ |
| ១១ | មណ្ឌលគិរី | ៧ | ៤.៧៧៥ | ៣.១១១ | ៦៥ |
| ១២ | ភ្នំពេញ | ៧ | ៦.៥៦០ | ៦.៣៦៨ | ៩៧ |
| ១៣ | ព្រះវិហារ | ១២ | ៨៦.០០០ | ៧៧.១១៤ | ៩០ |
| ១៤ | ព្រៃវែង | ១២ | ១៦២.៥០០ | ១៥៤.៩៧៣ | ៩៥ |
| ១៥ | ពោសាត់ | ១៨ | ១២១.១០០ | ១១៤.២១៣ | ៩៤ |
| ១៦ | រតនៈគិរី | ១០ | ៣៥៥.០០០ | ៣២០.០៦៣ | ៩០ |
| ១៧ | សៀមរាប | ១៩ | ១៣១.៩៥១ | ១៣១.៩៥១ | ១០០ |
| ១៨ | ក្រុងព្រះសីហនុ | ៧ | ៣.៥១០ | ៣.៥១០ | ១០០ |
| ១៩ | ស្ទឹងត្រែង | ៧ | ២.៩៤០ | ២.៧៤៦ | ៩៣ |
| ២០ | ស្វាយរៀង | ១៤ | ១២៧.៩៩៧ | ១១៣.៨៨៨ | ៨៩ |
| ២១ | តាកែវ | ១៦ | ១៤៥.៩៩៩ | ១៣១.១១២ | ៩៧ |
| ២២ | ឧត្ដរមានជ័យ | ១៩ | ៦៤.៨៥៥ | ៥៨.៧៦៤ | ៩១ |
| ២៣ | ក្រុងកែប | ៧ | ២.៣០០ | ១.៨៦២ | ៨១ |
| ២៤ | ក្រុងប៉ៃលិន | ១៧ | ៣៦.០០០ | ៣៥.៩៩១ | ១០០ |
| **សរុប** | | **២៩៣** | **១.៩៧៧.៦៣៤** | **១.៨៣២.៩៩១** | **៩៣** |

[៤] រួមបញ្ចូលទាំងកិច្ចសន្យាមិនមែន PIF រវាងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងផ្នែកនៅក្រោម PRDC Excom ។ ជាធម្មតាតែងមាន៥ផ្នែកក្នុងខេត្តនិមួយៗ ហើយថវិកានេះចំណាយលើប្រតិបត្តិការ (រួមទាំងប្រាក់ខែបន្ថែម) ដើម្បីគាំទ្រតាមដានដល់សកម្មភាពអភិវឌ្ឍន៍ឃុំ ។

(ប្រភព:លក្ខខណ្ឌយោង "TOR")

មានករណីលើកលែងមួយចំនួនចំពោះការអនុវត្តតាមរូបមន្តនេះ។ ការលើកលែងទាំងនេះបានយោងទៅលើសមត្ថភាពនិងសេវាគាំទ្រនៅក្នុងខេត្ត-ក្រុងមួយចំនួន និងការផ្តល់មូលនិធិដោយឡែករបស់ម្ចាស់ជំនួយមួយចំនួន តាមរយៈមូលនិធិវិនិយោគខេត្ត (PIF) នៃកម្មវិធីសិលា។ នៅឆ្នាំ២០០៥ខាងមុខ នឹងមានករណីលើកលែងតែបីករណីប៉ុណ្ណោះ។ ខេត្តកំពង់ធំ និងកំពតបានទទួលធនធានតាមរយៈគំរោង IFAD CBRD និង GTZ RDP ដូច្នេះហើយក្នុងឆ្នាំ២០០៥ នេះនឹងមានការកាត់បន្ថយថវិកា ដោយវិភាជន៍ឱ្យក្នុងអត្រាស្មើៗគ្នាមួយ ដោយមិនអាស្រ័យតាមចំនួនឃុំ ឬប្រជាជនឡើយ។ ចំណែកឯខេត្តរតនៈគិរីវិញនឹងទទួលការគាំទ្រមូលនិធិពីជំនួយ SIDA សំរាប់អនុវត្តគំរោងការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ (CBNRM) ហើយគំរោងនេះនឹងបន្តទទួលមូលនិធិវិនិយោគ ខេត្តជាង ៣០០.០០០ដុល្លារអាមេរិកក្នុងមួយឆ្នាំដែលបានកំណត់ទុករួចជាស្រេចសំរាប់គំរោង។

ទោះជាមានការផ្តល់មូលនិធិផ្សេងៗទៀតជាច្រើនសំរាប់ពីវិស័យផ្សេងៗ តាមរយៈយន្តការកម្មវិធីសិលា (ដូចជាថវិកាកំចីកសិកម្មរបស់ IFAD និងកម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF) ឬតាមរយៈកម្មវិធីជំនួយផ្សេងៗ ទៀតក្រៅក្របខ័ណ្ឌនៃកម្មវិធីសិលាក្តី ក៏មិនមានកត្តាណាមួយជះឥទ្ធិពលដល់ ការធ្វើវិភាជន៍ថវិកា ដោយគណៈកម្មាធិការដឹកនាំកម្មវិធីសិលានោះទេ។

នៅពេលបែងចែកមូលនិធិនៃមូលនិធិវិនិយោគខេត្តទៅបណ្តាលខេត្ត-ក្រុង ដែលភាគច្រើនផ្តល់សិទ្ធិសំរេចក្នុងការវិភាជន៍បន្តទៅឱ្យខេត្ត មានសកម្មភាពពីរដែលត្រូវបានកំណត់ជាមុនដោយថ្នាក់ជាតិ។ សកម្មភាពផែនការ សំរាប់អនុគិច្ចសន្យាមន្ទីរផែនការខេត្ត ដែលរួមបញ្ចូលគ្រប់តំរូវការដើម្បីគាំទ្រការងារផែនការ សំរាប់កម្មវិធីវិនិយោគខេត្ត និងសកម្មភាពយេនឌ័រសំរាប់អនុគិច្ចសន្យាមន្ទីរកិច្ចការនារីខេត្ត ដែលផ្តោតត្រង់លើការគាំទ្រយុទ្ធសាស្ត្របញ្ជ្រាបយេឌ័រទៅក្នុងសកម្មភាពនានា នៃមូលនិធិកម្មវិធីសិលា។

**ការពិភាក្សា**

**ការវិភាជន៍ដោយសមធម៌ និងតម្លាភាព**

ការទទួលខុសត្រូវដ៏សំខាន់នៅថ្នាក់កណ្តាល ក្នុងការបែងចែកប្រាក់ជំនួយនៅក្នុងប្រព័ន្ធវិសហមជ្ឈការ និងវិមជ្ឈការ គឺត្រូវធានានូវសមធម៌តាមខ្សែទទឹង។ ពេលបែបសាមញ្ញគឺ តំបន់ណាដែលមានសក្តានុពលចំណូលខ្សោយគួរតែទទួលធនធានច្រើន។ ចំពោះការវិភាជន៍ថវិកាតែងតែជួបប្រទះការស្មុគស្មាញ និងជំទាស់គ្នា ជាពិសេសនៅពេលដែលជួររដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន(ឃុំ) និងរដ្ឋបាលថ្នាក់ខេត្តចាប់ផ្តើមមានប្រភពចំណូលផ្ទាល់របស់ខ្លួន។ រដ្ឋាភិបាលថ្នាក់កណ្តាលត្រូវតែដោះស្រាយបញ្ហាសមធម៌រវាងតំបន់ ព្រមជាមួយនឹងការធានាអោយខ្លាំងនូវការលើកទឹកចិត្តដល់ថ្នាក់មូលដ្ឋាន ដើម្បីបង្កើនបន្ថែមទៀតនូវការប្រមូលចំណូលផ្ទាល់ខ្លួន។

ក្នុងមុខងារជាគំរូពិសោធន៍សំរាប់ការរៀបចំប្រព័ន្ធវិសហមជ្ឈការទៅអនាគត មូលនិធិវិនិយោគខេត្តគួរត្រូវបានយកទៅប្រើប្រាស់ ដើម្បីពង្រឹងសមត្ថភាពក្នុងការវិភាជន៍ថវិកាទៅថ្នាក់ខេត្ត-ក្រុង ប្រកបដោយតំលាភាព និង

សមធម៌។ ប្រការនេះ គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាគួរមានចំណែកពាក់ព័ន្ធក្នុងការពិនិត្យមើលថា តើស្ថាប័នណាមួយក្នុងរដ្ឋាភិបាល គួរជាកន្លែងសមស្របសំរាប់តួនាទីនេះក្នុងពេលអនាគត ហើយរៀបចំពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងស្ថាប័ននោះជាបណ្តើរៗ ក្នុងការគណនានិងផ្ទៀងផ្ទាត់ការវិភាជន៍ថវិកានេះ។ កិច្ចការនេះអាចនឹងទាមទារ ឱ្យមានការជួយគាំទ្រពីអ្នកឯកទេសអន្តរជាតិ។ អាចនឹងមានកាលានុវត្តភាពដ៏មានតំលៃមួយផងដែរក្នុងការផ្សារភ្ជាប់ ការពង្រឹងសមត្ថភាពស្តីពីការវិភាជន៍មូលនិធិវិនិយោគខេត្តប្រកបដោយសមធម៌ ទៅនឹងការបណ្តុះបណ្តាលដល់មន្ត្រី ដែលពាក់ពន្ធ័នឹងការវិភាជន៍ថវិការាជរដ្ឋាភិបាល។

ការរៀបចំរូបមន្តសំរាប់ការវិភាជន៏ដែលមានសមធម៌ គួររួមបញ្ចូលទាំងកត្តាភាពក្រីក្រទៅក្នុងនោះផងដែរ។ រូបមន្តទាំងនេះមានរួចជាស្រេចក្នុងការអនុវត្តមូលនិធិឃុំ/សង្កាត់(CSF): បញ្ហាថា ត្រូវធ្វើដូចម្តេចដើម្បី បញ្ចូលកត្តាភាពក្រីក្រទៅក្នុងរូបមន្តសំរាប៊វិភាជន៏ថវិកាទៅបណ្តាខេត្ត-ក្រុង អាចជាចំណុចចាប់ផ្តើមដ៏ជាក់លាក់។ Tracey-White (២០០២) បានបង្ហាញឱ្យឃើញថាលក្ខណៈវិនិច្ឆ័យភាពក្រីក្រ ជាញយៗមិនគួរអោយជឿបានទេ ហើយវាធ្វើឱ្យមានភាពខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ ទៅលើលទ្ធផលចុងក្រោយនៃការវិភាជន៍។ ចំណុចទាំងនេះមានសុពលភាពជាពិសេសក្នុងបរិបទនៃមូលនិធិវិនិយោគខេត្តបច្ចុប្បន្នមានកំរិតតិចតួច។ ទោះជាយ៉ាងណាក្តី បើសិនទៅពេលអនាគតមានការដាក់បញ្ចូលគ្នានូវមូលនិធិច្រើនប្រភព ទៅក្រោមការវិភាជន៍ពីថ្នាក់ជាតិទៅថ្នាក់ខេត្ត នោះភាពខុសគ្នានឹងបង្ហាញកាន់តែច្បាស់ឡើងៗ ទៅតាមពេលវេលា។ លើសពីនេះទៀត វិធីដ៏ប្រសើរក្នុងការធ្វើឱ្យទិន្នន័យ និងលក្ខណៈវិនិច្ឆ័យ អំពីភាពក្រីក្រមានលក្ខណៈគួរឱ្យជឿជាក់បាននោះ គឺការចាប់ផ្តើមជំរុញឱ្យមានការ ពិភាក្សាជុំវិញប្រធានបទនេះ។

**ទំនាក់ទំនងរវាងមូលនិធិវិនិយោគខេត្តជាមួយនឹងចំណូលខេត្ត**

តាមរយៈកិច្ចសំភាសន៏ ក្រុមទីប្រឹក្សាភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន (PLG) និងមន្ត្រីរដ្ឋាភិបាលបានបង្ហាញឱ្យឃើញក្តីបារម្ភអំពីថា តើធ្វើដូចម្តេចឱ្យមូលនិធិវិនិយោគខេត្តក្លាយទៅជាមូលធនចំបងរបស់ខេត្ត? និងតើធ្វើដូចម្តេចឱ្យមូលនិធិវិនិយោគខេត្តដែលកើតឡើងពីម្ចាស់ជំនួយនានាវិវត្តន៏ទៅជាមូលធនដែលកើតឡើង ដោយចំណូលក្នុងស្រុក? ជំរើសដំបូងអាចជាការសាកល្បងភ្ជាប់ជាមួយគ្នានូវមូលនិធិវិនិយោគខេត្តទៅនឹង ប្រភពចំណូលក្នុងខេត្ត[៥]។ វិធីនេះអាចជាវិធានការរយៈពេលខ្លីនៃចំណងទាក់ទងរវាងចំណូលនិងចំណាយ ហើយអាចជួយដល់ថ្នាក់ជាតិក្នុងការសិក្សា រកវិធីលើកទឹកចិត្តដល់ការប្រមូលចំណូល។ ក្នុងការរៀបចំមួយបែបនេះ សមាមាត្រដ៏សមស្រប មួយនៃចំណូលដែលប្រមូលបាន (ឧ.ពន្ធដីមិនបានប្រើប្រាស់[៦]) អាចនឹងត្រូវ បង្វែរចូលទៅក្នុងមូលនិធិវិនិយោគខេត្តដោយរតនាគារ។ នៅពេលនោះ រូបមន្តវិភាជន៏ថ្នាក់ជាតិអាចផ្តល់ជារង្វាន់លើកទឹកចិត្តដល់ខេត្ត ដែលប្រមូលចំណូល

[៥] នេះមិនជាបញ្ហាដែលបានពិភាក្សាក្នុងកំឡុងពេលក្រុមទីប្រឹក្សាធ្វើការសំភាសន៏: ចំពោះបញ្ហានេះប្រហែលជាយកមកពិនិត្យរួចហើយ។

[៦] ក្រុមប្រឹក្សាកំណែទំរង់ដីធ្លីបានផ្តល់អំណាចឱ្យអាជ្ញាធរខេត្តក្នុងការប្រមូលពន្ធពីដីធ្លីមិនបានប្រើប្រាស់ជាវិធីមួយក្នុងការលើកទឹកចិត្តឱ្យការប្រើប្រាស់ដីធ្លី ប្រកបដោយប្រសិទ្ធិភាព និងទប់ស្កាត់ដីមិនបានប្រើប្រាស់។

បានល្អ ដោយការវិភាជន៍ថវិកាឱ្យច្រើនជាងមុន។ ហើយបើសិនជា យន្តការបែបនេះមិនអាចដាក់ឱ្យដំណើរការបាន ទេនោះ ការពិភាក្សាជុំវិញបញ្ហាថា តើធ្វើដូចម្តេចដើម្បីជំរុញឱ្យវាអាចដំណើរការបាន អាចនឹងមានសារប្រយោជន៍ ក្នុងការរៀបចំយន្តការរយៈពេលវែងមួយ។

**ការកំណត់ថវិកាជាមុនដោយ គ.ជ.ន.ស សំរាប់វិស័យយេនឌ័រ**

យោងទៅតាមការកំណត់មូលនិធិរួចជាស្រេចដោយ គ.ជ.ន.ស មានប្រតិកម្មថាថវិកាដែលកំណត់សំរាប់យេឌ័រ មានចំនួនតិចពេក។ បង្កប់ក្នុងនេះ មានការសន្មតថា ខេត្តមិនត្រូវបានអនុញ្ញាតិឱ្យវិភាជន៍ថវិកាថែមសំរាប់ សកម្មភាព ដែលបានកំណត់រួចហើយនោះទេ។ ដូច្នេះហើយ វាអាចមានសារៈសំខាន់ក្នុងការបញ្ជាក់ថាការកំណត់ថវិកាជាមុន សំរាប់ យេឌ័រ មិនបានបិទច្រកគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តក្នុងការវិភាជន៍មូលនិធិវិនិយោគខេត្តបន្ថែមឱ្យការគាំទ្រ សកម្មភាពបញ្ហាយេនឌ័រឡើយ។

បញ្ហាទីពីរទាក់ទងទៅនឹងសកម្មភាពយេនឌ័រដែរ គឺក្រសួងបានអនុម័តឱ្យមានវគ្គបណ្តុះបណ្តាលយេនឌ័រនានា ក្រោយពីថវិកានៅតាមខេត្ត ត្រូវបានវិភាជន៍ចប់រួចទៅហើយ។ យោងទៅតាមមន្ត្រីខេត្ត និងទីប្រឹក្សា PLG មួយចំនួន បញ្ជាក់ថា ថវិកាដែលវិភាជន៍រួចហើយនោះ មិនគ្រប់គ្រាន់សំរាប់ឆ្លើយតបទៅនឹងវគ្គនានាដែលតំរូវដោយក្រសួងទេ។ យើងមិនបានស្វែងយល់គ្រប់គ្រាន់លើបញ្ហាទាំងនេះទេ ប៉ុន្តែយើងយល់ថាមានបញ្ហាចោទឡើង អំពីទំនាក់ទំនងរវាង ការរៀបចំផែនការសកម្មភាព និងផែនការថវិកា សំរាប់កិច្ចការយេនឌ័រ។ បើសិនថវិកាបានរៀបចំមុនហើយ តើការ រៀបចំផែនការសកម្មភាពបានរៀបតំរូវតាមថវិកានោះឬទេ? ហើយបើផែនការសកម្មភាពបានរៀបចំមុន តើការវិភាជន៍ ថវិកាបានឆ្លើយតបទៅនឹងតំរូវការនៃផែនការនោះឬទេ?

**ការកំណត់ថវិកាជាមុនដោយ គ.ជ.ន.ស សំរាប់វិស័យផែនការ**

មូលនិធិវិនិយោគខេត្តដែលបានបែងចែកសំរាប់សកម្មភាពវិស័យផែនការ អាចបកស្រាយបានថាជាការគាំទ្រ ប្រតិបត្តិការរដ្ឋបាល ជាជាងការវិនិយោគទុន។ ករណីទាំងនេះអាចមានដូចជា សកម្មភាពសមាហរណកម្មផែនការ ថ្នាក់ស្រុក(DIW) ដែលត្រូវបានរំពឹងទុកថាជាផ្នែកសំយោគដ៏សំខាន់មួយ នៃប្រព័ន្ធរដ្ឋបាលសាធារណៈកម្ពុជា សំរាប់ រយៈពេលវែង។ ដោយសន្មតថា ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ និងស្ថាប័នផ្សេងៗទៀត ដែលកំពុងគិតគូរ អំពីកំណែទំរង់អភិបាលកិច្ចថ្នាក់ខេត្ត-ក្រុង នឹងសំលឹងមើលយ៉ាងយកចិត្តទុកដាក់ ដល់ការចំណាយលើប្រតិបត្តិការ និង លើបុគ្គលិក ដែលអនុវត្តន៍ដោយសិលា សំរាប់ជាគំរូមួយនៃការធ្វើផែនការហិរញ្ញវត្ថុនិងធនធានមនុស្សទៅអនាគត។ ការចាត់ទុក ចំណាយគាំទ្រវិស័យផែនការជាចំណាយប្រតិបត្តិការ ជាជាងចំណាយវិនិយោគ ហើយមិនចាត់បញ្ចូល ចំណាយទាំងនេះទៅក្នុងមូលនិធិវិនិយោគខេត្ត អាចជាប្រការត្រឹមត្រូវមួយ។

**អនុសាសន៍លើការវិភាជន៍មូលនិធិវិនិយោគខេត្តដោយ គ.ជ.ន.ស**

១. ចាត់ទុកការអនុវត្តន៍និតិវិធីវិភាជន៍ថវិកានេះ ជាឱកាសក្នុងការរៀបចំប្រព័ន្ធវិភាជន៍គំរូមួយដែលប្រកបដោយតំលាភាព និងសមធម៌ ជាការត្រៀមទុកមុនសំរាប់កំណែទំរង់វិសហមជ្ឈការ។ គួររួមទាំងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យនៃភាពក្រីក្រ ផងដែរ (ដូចក្នុងរូបមន្ត វិភាជន៍មូលនិធិឃុំ/សង្កាត់)។

២. គួរពិនិត្យមើលលទ្ធភាពផ្សារភ្ជាប់ មូលនិធិវិនិយោគខេត្ត ទៅនឹងចំណូលខេត្ត។

៣. ដោះមុខសញ្ញា និងសំរបសំរួលផ្ដល់វត្ថុបណ្ដុះបណ្ដាលដល់មន្ត្រីពាក់ព័ន្ធ នូវទ្រឹស្ដីនិងការអនុវត្តន៍ជាក់ស្ដែង នៃការធ្វើវិភាជន៍ថវិកាទៅអោយថ្នាក់ខេត្ត-ក្រុង (វិមជ្ឈការសារពើពន្ធ)។

៤. បញ្ជាក់ឱ្យច្បាស់ថា គ.អ.ជ.ខ អាចវិភាជន៍ថវិកាបន្ថែមឱ្យមន្ទីរដែលបានទទួលការវិភាជន៍រួចស្រេចពី គ.ជ.ន.ស។

៥. ពិចារណាចាត់ថ្នាក់ការចំណាយលើការងារផែនការ ជាចំណាយប្រតិបត្តិការ ជាជាងមូលនិធិវិនិយោគខេត្ត។

## ១.ខ. ការវិភាជន៍មូលនិធិវិនិយោគខេត្ត ដោយ គ.អ.ជ.ខ

**សាវតា**

ដំណើរការវិភាជន៍មូលនិធិវិនិយោគខេត្ត គឺតាមសេចក្ដីណែនាំរបស់ក្រសួងផែនការ លេខ៦៨០ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០០៣[៧]។ ដោយពិតទៅ សេចក្ដីណែនាំនេះផ្ដោតលើដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុកឆ្នាំ ២០០៣ តែប៉ុណ្ណោះ ហើយក៏មិនទាន់មានសេចក្ដីណែនាំណាមួយពីថ្នាក់ជាតិ ដែលចែងច្បាស់ពីការគ្រប់គ្រងមូលនិធិវិនិយោគខេត្តពិតប្រាដកនោះទេ[៨]។ ដំណើរការវិភាជន៍រួមបញ្ចូលលក្ខណៈវិនិច្ឆ័យបីប្រភេទ ដែលត្រូវអនុវត្តន៍ដោយមាន "តំលាភាព" និង "អាចបត់បែនបាន"។

- **ផ្ដោតលើគោលបំណងនៃសកម្មភាព**។ គោលបំណងនៃសកម្មភាពគួរមាន:
  - តំរង់ទៅការកាត់បន្ថយភាពក្រីក្រ
  - ស្របតាមផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
  - ផ្ដល់ផលប្រយោជន៍សេដ្ឋកិច្ច-សង្គមកិច្ចអោយបានច្រើនដល់ស្ត្រី និងកុមារ
  - ប៉ះពាល់ដល់បរិស្ថានតិចតួច ឬប្រសើរជាងទៀត ធ្វើឱ្យបរិស្ថានកាន់តែប្រសើរឡើង
  - មានប្រសិទ្ធភាពតំលៃ (តំលៃ/អ្នកទទួលផល) និងអាចបន្តរក្សាបានដោយមានជំនួយពីខាងក្រៅតិចបំផុត។
  - ស្របទៅនឹងគោលនយោបាយជាតិនិងខេត្ត (រាប់ទាំងផែនការនិងកម្មវិធីវិនិយោគខេត្ត)។
- **សមត្ថភាព និងការប្ដេជ្ញាចិត្តនៃបណ្ដាមន្ទីរជំនាញដើម្បីអនុវត្តគោលបំណងសកម្មភាព**។ តើមន្ទីរបាន

[៧] ម្នាក់ៗមិនធ្លាប់ដឹងមាតិកាសេចក្ដីណែនាំទាំងនេះគួរតែអានរួចជាស្រេច មុននឹងអានរបាយការណ៍ទាំងនេះ។ ផ្នែកនេះបានដាក់ក្នុងឧបសម្ព័ន្ធ ៤ (ឯកសារភាសាអង់គ្លេស)។

[៨] សេចក្ដីណែនាំកម្មវិធីសិលាបានបង្ហាញអោយឃើញយ៉ាងច្បាស់នាស់នូវនិតិវិធីសំរាប់កិច្ចសន្យា ពិនិត្យតាមដាន និងវាយតំលៃ ប៉ុន្តែ ខ្ញុំមិនបានជួបប្រទះឯកសារក្នុងកំឡុង ពេលសិក្សា។

សំរេចលើសពី៩០% នៃអនុកិច្ចសន្យាកម្មវិធីសិលានៃឆ្នាំមុនឬទេ? តើមន្ទីរមានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពដែលបានស្នើ ហើយតើមានជំនួយការបច្ចេកទេសឬទេ ប្រសិនជាចាំបាច់?

- លទ្ធភាព<u>**ផ្សារភ្ជាប់ និងសំយោគ**</u> ជាមួយគំរោងផ្សេងៗទៀត។ តើគំរោងដែលស្នើមក ជាផ្នែកមួយនៃគំរោងសហប្រតិបត្តិការជាមួយឃុំ-សង្កាត់ដែរឬទេ?តើមានការទាក់ទងគ្នាទៅនឹងសកម្មភាពផ្សេងទៀតនៅក្នុងឃុំ ឬមកពីមន្ទីរជំនាញផ្សេងៗ ឬNGO/IOឬទេ? តើសកម្មភាពនេះឆ្លើយតបទៅនឹងតំរូវការអន្តរឃុំ ឬអន្តរស្រុកឬទេ? តើគំរោងនេះជួយបំពេញផលប្រយោជន៍ឱ្យគំរោងផ្សេងទៀត ឬទេ?

ប្រភព: ក្រសួងផែនការ លេខ ៦៨០ ទំព័រ ៦

## របកគំហើញ និងការពិភាក្សា

### ការវិភាជន៍ថវិកាទៅមន្ទីរ

សេចក្ដីណែនាំបញ្ជាក់ថា គប្រ នៃគ.អ.ជ.ខ មិនត្រូវបែងចែកថវិកាទៅតែបី-បួនមន្ទីរអាទិភាព ឬផ្ដល់ថវិកាឱ្យទៅគ្រប់មន្ទីរទាំងអស់ឡើយ។ ជាទូទៅសេចក្ដីណែនាំនេះត្រូវបានអនុវត្តតាម[៩]។ ជាករណីលើកលែងមួយ ឆ្នាំ ២០០៤ ខេត្តព្រៃវែង ដែលបានពិចារណាលើសេចក្ដីណែនាំ និងជំរើសផ្សេងៗ ហើយបានអនុម័តផ្ដោតការវិនិយោគទៅលើមន្ទីរសំខាន់ៗចំនួន៣។ ដោយមូលហេតុនេះហើយដែលខេត្តព្រៃវែងត្រូវបានជ្រើសរើសក្នុង សំរាប់ចុះសិក្សាស្រាវជ្រាវ។ សូមមើលទំព័របន្ទាប់សំរាប់ការវិភាជន៍ថវិការបស់ ខេត្តព្រៃវែង ឆ្នាំ២០០៣ និង២០០៤ទៅបណ្ដាវិស័យ។

ចំលើយទទួលបានពីបញ្ជីសំនួរដែលផ្ញើជូនមន្ទីរផែនការខេត្ត-ក្រុងទាំង២៤( ឧបសម្ព័ន្ធ២) បានបញ្ជាក់ការគាំទ្រជាទូទៅចំពោះនិតិវិធីវិភាជន៍ថវិកា និងលក្ខណៈវិនិច្ឆ័យបច្ចុប្បន្ន (ក្នុង១៥ខេត្ត មាន៣ស្នើថាដំណើរការវិភាជន៍ថវិកានេះល្អណាស់ មិនចាំបាច់ផ្លាស់ប្ដូរទេ ហើយ១២ខេត្ត ស្នើថាដំណើរការវិភាជន៍ថវិកាល្អហើយ តែចាំបាច់ត្រូវការពង្រឹងការងារមួយចំនួនទៀត)។

ក្នុងកំឡុងពេលចុះស្រាវជ្រាវ ខេត្តពោធិសាត់ ព្រៃវែង បាត់ដំបង បន្ទាយមានជ័យ និងកំពង់ឆ្នាំង បានបង្ហាញនូវរបៀបដោះស្រាយផ្សេងៗពីគ្នា។ ចំពោះខេត្តព្រៃវែងមានបីមន្ទីរចាត់ទុកជាអាទិភាពដូចជា (a)អាចផ្ដល់ប្រយោជន៍ច្រើនចេញពីថវិកាដែលមាន និង(b)នៅមិនទាន់បានទទួលមូលនិធិពីប្រភពផ្សេងៗទៀត។ ដោយពិតទៅ លក្ខណៈវិនិច្ឆ័យទាំងនេះមិនសូវមានភាពជាក់លាក់ទេ។ នៅខេត្តព្រៃវែង មន្ទីរដែលបានទទួលមូលនិធិច្រើនជាងគេ (ជាង ៤០.០០០ដុល្លានៅឆ្នាំ២០០៣ និងជាង ៦០.០០០ដុល្លា នៅឆ្នាំ២០០៤) គឺមន្ទីរធនធានទឹក និងឧតុនិយម។ យោងតាមការសំភាសន៍មន្ត្រីមកពីមន្ទីរនោះផ្ទាល់ បានឱ្យដឹងថា មន្ទីរបានទទួលមូលនិធិជាង១លានដុល្លាអាមេរិក (ភាគច្រើនពីគំរោង WB និង ADB ដើម្បីជួសជុលហេដ្ឋារចនាសម្ព័ន្ធខូចខាតដោយទឹកជំនន់)។ ប៉ុន្តែដោយសារគំរោងទាំងនោះ

[៩] មើលតារាងនៅទំព័របន្ទាប់។ កត់សំគាល់ថា តារាងដែលបានប្រមូលផ្ដុំមកពីការបោះពុម្ពចេញចុងក្រោយនៃក្រុមទីប្រឹក្សា។ មានស្ថានភាព (តើហេតុអ្វី ផែនការ SRP មានតំលៃខ្ពស់ក្នុងឆ្នាំ ២០០៣?) និងលប់ចោល (តើមានការវិភាជន៍ថវិកាមណ្ឌលគីរីសំរាប់ឆ្នាំ ២០០៤?) ថា មិនបានតាមដានវាយតំលៃ។ ប៉ុន្តែ យើងកំពុងផ្ដល់ការវាយតំលៃសុក្រិតជាទូទៅថាតើ មូលនិធិវិនិយោគខេត្តបានបែងចែកក្នុងខេត្ត-ក្រុងនីមួយៗ។

គ្រប់គ្រងដោយក្រសួងនៅភ្នំពេញ មន្ទីរអាចដឹងថាមានមូលនិធិជំនួយតែនៅពេលមាន "ភ្លើងខៀវ" មកពីក្រសួង និងមានក្រុមការងារថ្នាក់ក្រសួង ចុះមកសិក្សា និងចាប់ផ្តើមអនុវត្តន៍គំរោង។

ខេត្តផ្សេងៗទៀតការវិនិយោគមានទំនងប្រហាក់ប្រហែលគ្នា ប៉ុន្តែអភិបាលខេត្តបាត់ដំបង បានបញ្ជាក់យ៉ាងជឿជាក់ថាការប្រមូលផ្តុំមូលនិធិទៅលើមន្ទីរមួយចំនួនតូច ដោយផ្តោតលើគំរោងធំៗ អាចនឹងមានប្រសិទ្ធិភាពជាង។ វាជាប្រការពិបាកបកស្រាយ ដែលមន្ត្រីនៅក្នុងខេត្តមួយ ធ្វើមិនដឹងមិនឮចំពោះសេចក្តីណែនាំ នៅពេលដែលខេត្តដទៃទៀតមានការរួញរានឹងធ្វើដូច្នេះ។

## តារាងទី ២: ការបែងចែកមូលនិធិវិនិយោគខេត្ត ឆ្នាំ ២០០៣

| ខេត្ត/ក្រុង | យេនឌ័រ | ផែនការ | កសិកម្ម | ទឹកស្អាត | ផ្លូវជនបទ | សុខាភិបាល | អប់រំ | បរិស្ថាន | ប្រើប្រាស់ដីធ្លី | ធនធានទឹក | ទេសចរណ៍ | សាសនា | ពតិមាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បាត់ដំបង(៩) | ៩៨៨៧ | ១០៦៥៨ | | ៧៤៦០ | ២៨៦៦០ | ១២៦៨១ | ៩៧៧០ | ១០២៦០ | ២៤២០០ | ១៤៥៦០ | | ៨១១២ | ៧៣៥២ |
| បន្ទាយមានជ័យ(៨) | ៧៥០០ | ១០២០០ | | ១៣៤០០ | ១៨៦០០ | ១៣៥០០ | ១០៩០០ | ១១០០ | ៨០០០ | ១៦១០០ | | ៥៥០០ | |
| កំពង់ចាម(៧) | ១៥២៨០ | ១៥៥០០ | ៣៧៥០០ | ២៧៦០០ | ៥២០០០ | ២៥៤០០ | ១៩៧២០ | | | ២៧៤០០ | | | ៤៥០០ |
| កំពង់ឆ្នាំង[10] (៩) | ៦៧៦៣ | ៧៨៨១ | ៣០៥០០ | ១០០១៩ | | | ១៥៨៥៥ | ៩៧០០ | ៥៥០០ | ១៥៤៨៩ | | ២៤៧៣ | ៦៧៥៨ |
| កំពង់ស្ពឺ(៧) | ១០០០០ | ៩០០០ | ៣៤០០០ | ២០០០០ | | ១០០០០ | ១៥០០០ | ១០០០០ | ៦៨០០ | ១៥០០០ | | | |
| កំពង់ធំ(០) | ៦០០០ | ១០១០០ | | | | | | | | | | | |
| កំពត(០) | ៦០០០ | ៥០៥៣ | | | | | | | | | | | |
| កណ្តាល(០) | ៥៤១០ | ៥៤១០ | | | | | | | | | | | |
| កោះកុង(០) | ១៦៤៤ | ៣១៨៤ | | | | | | | | | | | |
| ក្រចេះ(៧) | ៨០០០ | ៧០០០ | ១៤១០០ | | ១៥៨០០ | ៨១០០ | ១៥០០០ | ៣៨០០ | | ១៣៣០០ | | | ៥០០០ |
| មណ្ឌលគិរី(០) | ២៥៤៤ | ២៣៣១ | | | | | | | | | | | |
| ភ្នំពេញ(០) | ៣២៨០ | ៣២៨០ | | | | | | | | | | | |
| ព្រះវិហារ(៥) | ៦០៦២ | ៧១០៩ | ១៣០៣៧ | | | ១៨១៥៩ | ២១៤៣០ | ១៤២១២ | ៥៩៨៦ | | | | |
| ព្រៃវែង(៥) | ៨៤០៦ | ៩៦៥៤ | ៣៨៤០០ | ១៩៧០០ | ១៦៣០០ | | ២៦៤០០ | | | ៤៣៦០០ | | | |
| ពោធិ៍សាត់(៩) | ៧៦០០ | ៨០១០ | | | ១០៦៨០ | ១១៣៩០ | ១៤៦៤០ | ៣៤៨០០ | ១០៦៤៧ | ៩៧៤២ | ៤២៣០ | ៤៧០៦ | ៤៣៥៥ |
| រតនៈគីរី(៧) | ៣២៨៩០ | ១៥០០០ | ៧០២០០ | | | ១២៦១០ | ៥៧២០០ | ៨០៣៧០ | ២១៨០០ | | ៨០០០ | | ៥៦៩៣០ |
| សៀមរាប(៩) | ៧១៥៥ | ១៦៤៨២ | | ១៣១៨៤ | ១៧៩០០ | ៧៣៩៧ | ១៩៩២៩ | ៨៧៤៤ | ៩១៥០ | ១៥៤៥៥ | | ១១០៣៧ | ៩១៤៣ |
| ព្រះសីហនុ(០) | ១៨១០ | ១៧០០ | | | | | | | | | | | |
| ស្ទឹងត្រែង(០) | ១៥២០ | ១៤២០ | | | | | | | | | | | |
| ស្វាយរៀង(៦) | ៧១៤៧ | ៨៣០៥ | ៤២២៧២ | | ២៩៩៤៧ | ១០០០០ | ៨៤៣៧ | ៥៧៣៨ | | ១៦១៥០ | | | |
| តាកែវ(៩) | ៣៧៨៦ | ១០២៧២ | ៣០៦៨៤ | ១១៦៦៥ | ១២០០០ | ៨១៦១ | ១៣៦៥២ | ៦៤៦០ | ៥១៤៨ | ៣៩០៥២ | | ៦២៧៣ | |
| ឧត្តរមានជ័យ[11] (១០) | ៥២៩០ | ៦១៤៥ | ៦២៣៥ | ៨៧៨៥ | | ២៦៦៩ | ៥៦៧៥ | ៣៧០៤ | ២៩៨៣ | ៣៩០០ | ៣៣៣០ | ៨៥១០ | ១៩៧៥ |
| កែប(០) | ១១៥០ | ១១៥០ | | | | | | | | | | | |
| ប៉ៃលិន(៩) | ៤៦៣០ | ៥៥២៩ | ៣៩៨៦ | ៤១១០ | | ២០៣៣ | ២០០០ | ២៦៥៧ | ៤៥០០ | ៤០៨០ | | ១៤៧៥ | ១០០០ |

[10] ផ្នែកទីមួយៗហៅថា PBW (៤០៥៨ ដុល្លារអាមេរិក) ដែលបានរកឃើញក្នុងឯកសារ។ ខ្ញុំមិនដឹងថាតើមានអ្វីដែលមិនបានរាប់បញ្ចូលក្នុងតារាងនេះ។

[11] PBW ៤០៥៤ ដុល្លារអាមេរិក (មើល ការកត់សំគាល់សំរាប់ខេត្តកំពង់ឆ្នាំង)

## តារាងទី ៣: ការវិភាជន៍មូលនិធិវិនិយោគខេត្ត ឆ្នាំ ២០០៤

| ខេត្ត/ក្រុង | យេនឌ័រ | ផែនការ | កសិកម្ម | ទឹកស្អាត | ផ្លូវជនបទ | សុខាភិបាល | អប់រំ | បរិស្ថាន | គ្រប់គ្រងដី | ធនធានទឹក | ទេសចរណ៍ | សាសនា | ពតិមាន | សាធារណការ | សង្គមកិច្ច |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បាត់ដំបង(៩) | ៨៥០០ | ៩៨០០ | | ៦២៩០ | ២៧៧៩៨ | ១០៦៩៣ | ៨២៣៩ | ៩៥៨៧ | ១៧០០០ | ២៣១១៨ | | ៦៨៤០ | ៦៦៣៥ | | |
| បន្ទាយមានជ័យ(៩ | ៧៩០០ | ៨៦៨៩ | ៥០០០ | ១១៥៨៧ | ១៥៧០០ | ១១៥៨៤ | ៥៣០០ | ១០៧៤០ | ១៣៧០០ | ១២០០០ | | ៤៨០០ | | | |
| កំពង់ចាម(៨) | ១២០០០ | ១១២០០ | ៣៤០០០ | ២៥១២៨ | ៦៨៨៣៩ | ២៧៥១៥ | ២០៦៩៧ | ៤៥០០ | | ២២៤៨៤ | | | ៣៨០០ | | |
| កំពង់ឆ្នាំង(៩) | ៧១០០ | ៧៦០០ | ២៣០០០ | ១១២៨៨ | ១៩៧៤ | | ២០១៥០ | ៨៣៥០ | ៩៤៦៨ | ១៣៦២០ | | ២៥០០ | | | ២៥០០ |
| កំពង់ស្ពឺ(៧) | ៨៩០០ | ៨០០០ | ៣២៥០០ | ២៥០០០ | | ៧៣០០ | ៩០០០ | ៨៥០០ | ៦០០០ | ១១៨០០ | | | | | |
| កំពង់ធំ(០) | ៣០០០ | ៧៥០០ | | | | | | | | | | | | | |
| កំពត(០) | ៣៥០០ | ៨០០០ | | | | | | | | | | | | | |
| កណ្ដាល(១១) | ១៥៥០០ | ១០៨០០ | ២១២០០ | ៦០០០ | ២៩៧៣០ | ១៦៥០០ | ១២៥០០ | ១២០០០ | ៦៧៥០ | ២៤០២០ | | ៣៥០០ | ៤៧០០ | ៨៨០០ | |
| កោះកុង(០) | ៥០០០ | ៥៥០០ | | | | | | | | | | | | | |
| ក្រចេះ(៦) | ៥០០០ | ៥៨០០ | ១០៦០០ | | ២២០០០ | ៨៦០០ | ៦៥០០ | ២៣០០ | | ១៤៥០០ | | | | | |
| មណ្ឌលគិរី | | | | | | | | | | | | | | | |
| ភ្នំពេញ(៩) | ៧៨០០ | ៨៥០០ | ១៦៥០០ | ១៥០០០ | | ១២០០០ | ៣០៥០០ | ៧០០០ | ៧៥០០ | ១១៥០០ | | ៨៧០០ | | | ៨០០០ |
| ព្រៃវែង(៤) | ៨០០០ | ៩០០០ | | ១៣១១៦ | ២៥០០០ | | ៣១៥៦០ | | | ៦៦៣២៤ | | | | | |
| ព្រះវិហារ(៥) | ៧៤០០ | ៧១០០ | | | | ១៥១៥០ | ២១០០០ | ៥៣៥០ | ១២៥០០ | ២៥០០ | | | | | |
| ពោរសាត់(៦) | ៨០០០ | ៨៥០០ | ១៤៥០០ | | ១៦០០០ | ១០០០០ | | | | ១២៥០០ | ៧៥០០ | | | | ៨០០០ |
| ត្រនះគិរី(៥) | ៣០២៩៣ | ៦០០០ | ៦១៤៩១ | | | | ២៦៣៦៨ | ១០២៣៤០ | ៦៤៦០២ | | | | ៤០០២០ | | |
| សៀមរាប(៩) | ៧៥០០ | ១៦៣០៥ | | ៧១៣០ | ២៩០២៣ | ៧៣៧៣ | ១៦៨៩៤ | ៤៥១០ | ៩៤០០ | ១៦១៤៦ | | ១១៣៩៥ | ២៨៧០ | | |
| ព្រះសីហនុ(០) | ៥០០០ | ៥៥០០ | | | | | | | | | | | | | |
| ស្ទឹងត្រែង(៧) | ៤៥០០ | ៥៥០០ | ១៣០០០ | ៥៥០០ | ១០៥០០ | ៤៥០០ | | ៤០០០ | | ១០០០០ | | | ៥០០០ | | |
| ស្វាយរៀង(៩) | ៦៥០០ | ១១០០០ | | ៤៨០០ | ២០៥០៣ | ៦១៤៥ | ៧៨០០ | ៩៩៦០ | ៧២៦៧ | ២២២១២ | | | ៥៩១៣ | | ៤៩០០ |
| តាកែវ(១១) | ៨០០០ | ៩៥០០ | ២៣២១០ | ១១៩១៥ | ១២១៤៤ | ១៣២០០ | ១៥៦០០ | ១០០០០ | ៨៥០០ | ១៧៥១៤ | ៣១០០ | ៧២៥០ | ៤០២១ | | |
| ឧត្តមានជ័យ(១១) | ៥៧៤៥ | ៥០០០ | ៤៦១៣ | ៥៩០២ | | ១៣៧១ | ២១៩០ | ១៥៣០ | ១០៩៨២ | ៥១៥០ | ១២០០ | ៦១៨២ | ៥៨៧៤ | ៤២៥៩ | |
| កែប(០) | ៣០០០ | ៣៥០០ | | | | | | | | | | | | | |
| ប៉ៃលិន(៩) | ៣៦៤០ | ៤៦៣០ | ៣៦១៣ | ៥១៣៥ | | ៥៩៦០ | ២៣០០ | ៣៣៩៣ | ៧៦០៥ | ៥៣៧០ | | ១៨១៤ | ៤៥៤០ | | |

**អក្សរដិតខ្មៅ** បញ្ជាក់ថាការវិភាជន៍ថវិកាទៅតាមវិស័យមានតំលៃខ្ពស់ក្នុងខេត្ត។ តួលេខក្នុងវង់ក្រចកបញ្ជាក់ពីចំនួនមន្ទីរមិនរាប់បញ្ចូលឃេនឌ័រ និងផែនការ ដែលទទួលការវិភាជន៍ពីមូលនិធិ វិនិយោគខេត្ត។

## ការវិភាជន៍ថវិកាជាពីរដំណាក់កាល ៨០% និង២០%

បញ្ហាតែមួយគត់នៃការវិភាជន៍ថវិកា ដែលបានលើកឡើងដោយអ្នកផ្តល់ចំលើយជាច្រើននាក់តាមរយៈបញ្ជីសំនួរ (ខេត្ត៤ ក្នុងចំណោមខេត្ត ១៥) គឺការតំរូវឱ្យ គ.អ.ជ.ខ វិភាជន៍ថវិកាជាពីរដំណាក់: ៨០%មុនការធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក និង ២០% បន្ទាប់ពីការធ្វើសមាហរណកម្មផែនការថ្នាក់ស្រុករួច។

ខេត្តបាត់ដំបងបានគាំទ្រការបែងចែកថវិកា ៨០%និង២០% ទាំងស្រុង។ ប្រការដែលគួរអោយចាប់អារម្មណ៍គឺអភិបាលខេត្ត គ្មានការរួញរាក្នុងការធ្វើសំរេចចិត្តវិនិយោគថវិកា២០%ចុងក្រោយ ទៅលើការសាងសង់ទ្វារទឹកនៅទំនប់មួយយ៉ាងធំនៅភាគខាងលិចខេត្ត[១២]។ ចំពោះខេត្តព្រៃវែង បានសំរេចចិត្តថាសេចក្តីណែនាំនេះមិនសូវល្អ ហើយក៏មិនអនុវត្តតាម។ នៅខេត្តពោធិសាត់ គ្រប់សមាជិក គប្រ និងបណ្តាមន្ទីរជំនាញដែលក្រុមស្រាវជ្រាវបានជួប សុទ្ធតែបញ្ជាក់ថាបានអនុវត្តតាមសេចក្តីណែនាំ តែមិនឯកភាពតាមសេចក្តីណែនាំនេះទេ និងទាមទារឱ្យមានការផ្លាស់ប្តូរ។

អភិបាលខេត្តព្រៃវែងបានទទួលស្គាល់ថា ការមិនបានអនុវត្តតាមសេចក្តីណែនាំ គឺជាកំហុសឆ្គង (ប៉ុន្តែគាត់នៅតែមានអារម្មណ៍ថា ការសំរេចចិត្តរបស់ខេត្តគឺត្រឹមត្រូវហើយ)។ ផ្សេងពីនេះ អ្នកធ្លាប់បានចូលរួមសិក្ខាសាលាជាតិស្តីពីការតាក់តែងសេចក្តីណែនាំនេះ បានរំលឹកឡើងវិញថាសិក្ខាសាលានោះ បានព្រមព្រៀងឱ្យខេត្តនូវជំរើសអនុវត្តតាម ឬមិនអនុវត្តន៏តាម ការបែងចែកជាពីរដំណាក់ ៨០%និង២០% ហើយថាសេចក្តីណែនាំ របស់ក្រសួងមិនបានគោរពតាមស្មារតីសិក្ខាសាលានោះឡើយ។

ការកើតឡើងនូវទង្វើមិនគោរពទៅតាមនិតិវិធី និងអត្ថន័យសេចក្តីណែនាំ មានលក្ខណៈវិជ្ជមាន (ហើយបានរំលឹកយើងថា ការសន្និដ្ឋានដែលថាមានការភយ័ខ្លាចបាក់ស្បាតជាទូទៅ នៅក្រោមប្រព័ន្ធការិយាធិបតេយ្យកម្ពុជាគឺមិនពិតទាំងស្រុងនោះទេ)។ ទោះយ៉ាងណាក្តី វាហាក់ដូចជាមានភាពចាំបាច់ក្នុងការបញ្ជាក់ឡើងវិញទៅលើ "ការណែនាំ និង អនុសាសន៏នានា " នៅក្នុងសេចក្តីណែនាំ ដើម្បីធានាឱ្យមានភាពច្បាស់លាស់ត្រង់ថា តើក្នុងករណីណាខ្លះដែលខេត្តត្រូវ អនុញ្ញាតិ និងមិនអនុញ្ញាតិ ឱ្យការអនុវត្តន៍ខុសពីសេចក្តីណែនាំ។

ទាក់ទងទៅនឹងការបែងចែកថវិកាជាពីរដំណាក់នេះដែរ ផលប្រយោជន៏ដែលបានមកពីការរក្សាមូលនិធិមួយចំនែកទុកបំរុង រហូតដល់ក្រោយសមាហរណកម្មផែនការថ្នាក់ស្រុកនោះ ហាក់មិនអាចទប់ទល់បានជាមួយនឹងអំណាចការិយាធិបតេយ្យក្នុងដំណាក់នៃការវិភាជន៏ថវិកាជុំទីពីរឡើយ។ មានសញ្ញាច្បាស់លាស់ថាកង្វះគុណភាពនិងតំលាភាពកើតឡើងក្នុងការវិភាជន៏ថវិកាចុងក្រោយ២០% ដោយការវិភាជន៏នេះមិនត្រូវបានពិភាក្សាក្នុងសមាហរណកម្មផែនការថ្នាក់ស្រុក ហើយក៏មិនតំរូវអោយអនុមត័ដោយ គ.អ.ជ.ខ ពេញអង្គដែរ។

---

[១២] នេះជាករណីដែលចាប់អារម្មណ៍ដើម្បីតាមដានវាយតំលៃចំពោះការសិក្សាវាយតំលៃក្នុងពេលអនាគត។

## តើមានឆន្ទានុសិទ្ធច្រើនប៉ុណ្ណា?

ក្នុងការសំភាសន៍នៅថ្នាក់ជាតិ ជាពិសេសជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ បានបញ្ជាក់ពីផលចំណេញនៃការដំណើរការវិភាជន៍ថវិកា។ ដោយសង្ខេប ផលចំណេញទាំងនោះគឺៈ ១) មានការពិភាក្សាគ្នារវាងមន្ទីរសំខាន់ៗ[១៣] នៅថ្នាក់ខេត្ត ដែលជាឱកាសសំរាប់**សំរបសំរួល** និងសំយោគការផ្តើមគំនិតនានា (ដូចជាការធានាថាការផ្សព្វផ្សាយកសិកម្ម ត្រូវផ្តល់នៅតំបន់ដែលមានការសាងសង់រចនាសម្ព័ន្ធធារាសាស្ត្រ ឬថាការឃោសនាសុខភាពជនបទ ត្រូវផ្តល់នៅកន្លែងដែលមានសង់បង្គន់អនាម័យ និងអណ្តូងទឹក)។ ២) មានការកើនឡើងនូវ**តំលាភាព**ព្រោះថាមន្ទីរនានា និងអភិបាលស្រុក បានដឹងទាំងអស់គ្នា អំពីគំរោងការ និងថវិកាដែលមាន។ ៣) មាន**គណនេយ្យភាព**ចំពោះអាជ្ញាធរខេត្ត ដោយមន្ទីរជំនាញនានា បានចុះកិច្ចសន្យាជាមួយអភិបាលខេត្ត។ ប្រការទាំងនេះផ្ទុយគ្នាទៅនឹងនិតិវិធីបច្ចុប្បន្ន ដែលអនុវត្តន៍ចំពោះថវិកាជាតិ (ថវិកាសាធារណៈ?) ដែលវិភាជន៍ទៅឱ្យមន្ទីរជំនាញនានាថ្នាក់ខេត្ត។

ប្រការគួរអោយចាប់អារម្មណ៍គឺ ក្នុងពេលដែលមូលនិធិវិនិយោគខេត្តបានគឺជាមូលនិធិមួយដែលបើកឱ្យមានឆន្ទានុសិទ្ធ រាល់ផលវិជ្ជមានខាងលើរបស់វា អាចនឹងត្រូវរក្សាដដែល ទោះបីជាថ្នាក់ជាតិបានសំរេចកាត់បន្ថយសិទ្ធខ្លះនៅថ្នាក់ខេត្តក្តី។ មានចន្លោះគ្រប់គ្រាន់សំរាប់ឆ្លុះបញ្ចាំង គោលនយោបាយថ្នាក់ជាតិ ដោយការបង្កើន ចំនួនមូលនិធិដែលកំណត់ជាមុនដោយថ្នាក់ជាតិឱ្យច្រើនជាងមុន។ ដូចគ្នានេះដែរ ក្រសួងនានាក៏គួរដាក់បញ្ជាតិឱ្យខ្លាំងជាងមុនចំពោះប្រភេទសកម្មភាពដែលចាត់ទុកជាអាទិភាព។ ដោយហេតុថា នៅមានបញ្ហាមួយចំនួនទៀត ដែលត្រូវពិភាក្សា និងសំរេចនៅថ្នាក់ខេត្ត ផលចំណេញស្តីពីកិច្ចសំរបសំរួល តម្លាភាព និងគណនេយ្យភាព នឹងមិនបាត់បង់ទេ។

សំណូមពរក្នុងសេចក្តីណែនាំ ក៏ដូចជាការរំពឹងទុករបស់ទីប្រឹក្សា PLG នានា គឺថាមូលនិធិវិនិយោគខេត្ត និងផ្តោតជាចំបងទៅលើសកម្មភាពជាសារវន្តនានា ដូចជា បណ្តុះបណ្តាល បង្កើនការយល់ដឹងការរៀបចំ និងពង្រឹងក្រុមអ្នក ប្រើប្រាស់។ល។ ហើយសកម្មភាពទាំងនេះនឹងជួយបំពេញបន្ថែមលើសកម្មភាពជារូបវន្តនានា ដែលជាទូទៅស្ថាបនា តាមរយៈរដ្ឋាភិបាលមូលដ្ឋានដោយមូលនិធិអភិវឌ្ឍន៍ឃុំ/សង្កាត់។ ប៉ុន្តែ មន្ត្រីថ្នាក់ខេត្តនានា ជាពិសេសអភិបាលខេត្ត បានចាប់អារម្មណ៍ថា វិធីដែលផ្តល់ផលជាក់ស្តែងក្នុងការកាត់បន្ថយភាពក្រីក្រ គឺការវិនិយោគលើគំរោងហេដ្ឋារចនា-សម្ព័ន្ធ។ ទាំងនេះបង្ហាញអោយឃើញមួយចំនែកថាតំរូវការសំខាន់ និងចាំបាច់បំផុតនៅថ្នាក់ខេត្តគឺហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែ ក៏បង្ហាញដែរថា ការសំរេចចិត្តនេះ មិនមែនផ្អែកលើហេតុផលបច្ចេទេសតែមួយប៉ុណ្ណោះទេ គឺមានហេតុផលនយោបាយផងដែរ។ អភិបាលខេត្តពេញចិត្ត នឹងទទួលផលចំណេញខាងនយោបាយ តាមរយៈការភ្ជាប់ឈ្មោះរបស់ខ្លួន ទៅនឹងសមិទ្ធផលរូបវន្តសាធារណៈធំៗ ជាជាងវគ្គបណ្តុះបណ្តាលតូចតាច[១៤]។

បញ្ហានេះត្រូវលើកយកមកសិក្សាជាថ្មីទៀត នៅក្នុងបទពិភាក្សា នៃជំពូកនានាខាងក្រោម។ នៅជំហាននេះ យើងបានកត់សំគាល់គ្រប់គ្រាន់ហើយ ថាមានវិសាលភាពសំរាប់ថ្នាក់ជាតិធ្វើការតំរង់ទិស ថាគួរប្រើមូលនិធិវិនិយោគ

---

[១៣] មន្ទីរសំខាន់ជាមន្ទីរដែលមិនមានតួនាទីចែកចាយសេវាដោយផ្ទាល់ តែដែលបានផ្តល់ការគាំទ្រ និងមានតួនាទីសំរបសំរួលដែលអាចជួយមន្ទីរជំនាញរបស់គាត់ដើម្បីចែក ចាយសេវា។ ដូច្នេះ រួមបញ្ចូលទាំងមន្ទីរផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត។

[១៤] នេះមិនចាំបាច់ជៀស។ ប៉ុន្តែ នេះជាការពិតដែលប្រជាជនកម្ពុជានៅពេលបច្ចុប្បន្ន។

ខេត្តបែបណាដើម្បីកុំឱ្យបាត់បង់នូវអត្ថប្រយោជន៍នានា នៃដំណើរការវិភាជន៍ថវិកាបច្ចុប្បន្ន។ ជាមួយនេះដែរ ការរំពឹងទុករបស់ថ្នាក់គ្រប់គ្រង ដែលបង្កប់ក្នុងកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ គឺការផ្តល់អំណាច និងការទទួលខុសត្រូវថែមទៀតសំរាប់ជាកំលាំងជំរុញ ដែលពេលនេះការប្រឈមនានាដើម្បីអំណាចទាំងនោះ ហាក់ត្រូវថយចុះទៅវិញ។

**តើនរណាខ្លះបានចូលរួមការវិភាជន៍ថវិកា?**

គ.អ.ជ.ខ គប្រ មានតួនាទីដឹកនាំក្នុងការរៀបចំវិភាជន៍ថវិកា។ សមាជិក គ.អ.ជ.ខ[១៥] ពេញអង្គចូលរួមក្នុងជំហានមួយចំនួនដូចខាងក្រោម:

| | | |
|---|---|---|
| ១ | ប្រជុំដើម្បីជូនដំណឹងទៅមន្ទីរជំនាញនានា និងNGOs/IOs ដែលសកម្មចូលរួម ក្នុងដំណើរការសមារណកម្មផែនការថ្នាក់ស្រុក | ភារកិច្ចទី២ ទំព័រ៧ នៃសេចក្តីណែនាំរបស់ក្រសួងផែនការ |
| ២ | ប្រជុំអនុមត័លើសំណើ គប្រ នៃការវិភាជន៍ថវិកា ៨០% ដំបូង | ភារៈកិច្ចទី ៤ ទំព័រ ១១ |
| ៣ | ប្រជុំប្រកាសការវិភាជន៍មូលនិធិវិនិយោគខេត្ត ៨០% និងរៀបចំកាលវិភាគសិក្ខាសាលាសមារណកម្មផែនការថ្នាក់ស្រុក | ភារៈកិច្ចទី ៥ ទំព័រ ១១ |

ភារៈកិច្ចទី៤ នៃដំណើរការវិភាជន៍ ចាប់ផ្តើមដោយមន្ទីរជំនាញនានាឡើងបង្ហាញសំណើគំរោងរបស់ខ្លួន និងបន្តទៅទៀតដោយ គប្រ វិនិច្ឆ័យលើការបែងចែកថវិកា។ ទោះជាសេចក្តីណែនាំមិនបានបញ្ជាក់ថាត្រូវឱ្យមន្ទីរជំនាញមានវត្តមានបន្តក្នុងរបៀបវារៈចុងក្រោយនៃអង្គប្រជុំនេះក្តី សភាពជាក់ស្តែងនៃដំណើរការតំរូវឱ្យ មានពេលច្រើនជាងការប្រជុំមួយដង។ ក្នុងខេត្តពោធិ៍សាត់ មន្ត្រីCAUបានពន្យល់ថា គប្រ វាយតំលៃលើការស្នើសុំរបស់មន្ទីរ និងធ្វើការវិភាជន៍ជាដំបូង។ បន្ទាប់មកមន្ត្រី CAU ជូនដំណឹងដល់មន្ទីរវិញពីលទ្ធផលវិភាជន៍ថវិកា ដែលតិចជាងអ្វីដែលគេបានស្នើ និងបញ្ជាក់ពីបំណង គប្រ ដែលចង់ឱ្យមន្ទីរប្រើប្រាស់ការវិភាជន៍មូលនិធិនេះ។

ពេលមួយបែបទៀត នៅខណៈដែលប្រធានមន្ទីរនានា និងអភិបាលស្រុក មាននាទីតិចតួចក្នុងការ វិភាជន៍ថវិកា គប្រ នៃ គ.អ.ជ.ខ ក្តាប់ការទទួលខុសត្រូវភាគច្រើននៃដំណើរការនេះ។ ជាផ្លូវការ អភិបាលខេត្តជាប្រធាន គប្រ ប៉ុន្តែ វាអាស្រយ័ផងដែរនឹងវិធីធ្វើការរបស់អភិបាលខេត្តនិមួយៗ ថាតើគាត់ចូលចិត្តពាក់ព័ន្ធដោយផ្ទាល់ (ឧ. អភិបាល ខេត្តពោធិ៍សាត់រង់ចាំ ដល់ដំណើរការវិភាជន៍ថវិកាបញ្ចប់សិន ទើបគាត់ពិនិត្យនឹងអនុមត័ រីឯខេត្តព្រៃវែងវិញ អភិបាលខេត្តចូលរួមសកម្មក្នុងការប្រជុំ)។ អភិបាលខេត្តកំពង់ឆ្នាំង យល់ថាជាប្រការខុសឆ្គងមួយ ដែលតំរូវឱ្យ គប្រ ទទួលខុសត្រូវលើកិច្ចការនេះ ព្រោះថាក្នុង គប្រ មានប្រធានមន្ទីរមួយចំនួន (ឧ.កសិកម្ម អភិវឌ្ឍន៍ជនបទ កិច្ចការនារី) ដែលជាអ្នកប្រកួតប្រជែងយកមូលនិធិ ហើយគ្មានតំណាងមន្ទីរដទៃទៀត (ឧ. សុខាភិបាល អប់រំ និងពត៌មាន)។ ដូចនេះហើយ អភិបាលខេត្តបានបង្កើតគណៈកម្មការតូចជាង គប្រ ដើម្បីធ្វើការសំរេចលើវិភាជន៍ថវិកា ដែលមានតែ មន្ទីរផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រតនាគារ និងមន្ត្រីCAU។ នេះគឺជាក្តីសង្ឃឹមដ៏ល្អមួយសំរាប់អ្នកទាំងឡាយដែល គួរចូលពាក់ព័ន្ធក្នុងការសំរេចចិត្តលើបញ្ហានេះនាអនាគត នៅពេលដែល គប្រ ត្រូវបាន"បញ្ជ្រាប"ទៅ

---

[១៥] បញ្ហាមួយដែលបានកើតឡើងនៅថ្នាក់ជាតិ តែយើងមិនបានរុករកក្នុងអំឡុងពេលស្រាវជ្រាវ ដែលជានិច្ចជាកាលអភិបាលស្រុកមិនបានអញ្ជើញចូលរួមក្នុងអង្គប្រជុំនេះ។

ក្នុងរដ្ឋបាលខេត្ត។ ការកែសំរួលសមាសភាព គប្រ ឱ្យស្របតាមការរំពឹងទុក និងជាគំរូសំរាប់កំណែទំរង់ (Evans 2003) អាចជាការល្អ។

## មន្ទីរដែលរវល់ និងបានទទួលមូលនិធិច្រើនហួស

បញ្ហាមួយដែលលើកឡើងតាមដោយទីប្រឹក្សាPLG គឺមានមន្ទីរមួយចំនួនរវល់ នឹងទទួលអនុវត្តន៍មូលនិធិវិនិយោគខេត្ត។ តំណាងមន្ទីរខេត្ត-ក្រុងមួយចំនួនបានបកស្រាយបញ្ហានេះដោយយោងទៅមូលហេតុពីរ។ មួយគឺដោយសារមន្ទីរបានទទួលមូលនិធិពីប្រភពផ្សេងៗទៀតជាច្រើនរួចមកហើយ បន្ទុកការងារពីគំរោងទាំងនោះ ធ្វើឱ្យមន្ទីរមិនមានសល់សមត្ថភាពគ្រប់គ្រាន់សំរាប់ធ្វើសកម្មភាពមូលនិធិវិនិយោគខេត្ត( មន្ទីរអប់រំខេត្តពោធិ៍សាត់) ។ម្យ៉ាងវិញទៀត អត្រាប្រាក់បេសកកម្ម ក្រោមកម្មវិធីសិលា មានកំរិតទាបជាងអត្រារបស់រដ្ឋាភិបាល (ខេត្តបាត់ដំបង) ។

ចំពោះករណីមន្ទីរសុខាភិបាលខេត្តពោធិ៍សាត់ក្នុងឆ្នាំ ២០០៣ មានកើតឡើងនូវករណី "ទទួលមូលនិធិលើស" ។ ក្រោយពីបានទទួលការវិភាជន៍មូលនិធិវិនិយោគខេត្ត មន្ទីរសុខាភិបាលក៏បានទទួលផងដែរនូវមូលនិធិដ៏ច្រើនពី កម្មវិធី DFID សំរាប់សកម្មភាពការការពារជំងឺអេដស៍។ ជាលទ្ធផល មន្ទីរសុខាភិបាល មិនបានអនុវត្តមូលនិធិវិនិយោគខេត្ត ដែលផ្តោតលើសកម្មភាពអេដស៍ ហើយថវិកា ត្រូវបង្វិលទៅឱ្យ គ.ដ.ន.ស វិញនៅចុងឆ្នាំ។

សេចក្តីណែនាំបានបញ្ជាក់យ៉ាងច្បាស់រួចហើយថា មន្ទីរគួរពិចារណាលើសមត្ថភាព និងធនធានផ្ទាល់ខ្លួននៅពេលស្នើសុំថវិកាពីមូលនិធិវិនិយោគខេត្ត ហើយ គប្រ មិនគួរមានយល់ថាខ្លួនមានកាតព្វកិច្ចត្រូវតែបែងចែកថវិកា ទៅគ្រប់មន្ទីរ ឬមន្ទីរជាអាទិភាព (សុខាភិបាល អប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទ)នោះទេ។ បង្កប់ពីក្រោមការសន្ទនាទាំងនេះ គឺនៅមានករណីដែល គប្រ ប្រកាន់ខ្ជាប់ថាខ្លួនគួរបែងចែកថវិកា អោយទៅមន្ទីរអាទិភាព ហើយមន្ទីរទាំងនោះ មានភារកិច្ចត្រូវធ្វើការស្នើសុំ និងទទួលមូលនិធិ។ នេះគឺជាបញ្ហា ព្រោះថាបានធ្វើឱ្យបាត់បង់ឱកាសជួយគាំទ្រមន្ទីរដែល "ទទួលមូលនិធិមិនគ្រប់" ហើយជួនកាលបង្កជាសំពាធជំរុញឱ្យមន្ទីរដែល"ទទួលមូលនិធិលើស" ប្រើថវិកាខុសទិស[១៦] ។ ក្នុងកំរិតដែលស្ថានភាពទាំងនេះ ត្រូវបានបង្កឡើងដោយ ភាពមិនអាចព្យាករណ៍បាន នៃកម្មវិធីនានា គាំទ្រដោយម្ចាស់ជំនួយជាច្រើន (ដែលការទំលាក់មូលនិធិ មិនអាចដឹងបាន នៅពេលដែល គអជខ ធ្វើការបែងចែកមូលនិធិវិនិយោគខេត្ត) វាមិនមែនជាបញ្ហាដែលត្រូវដោះស្រាយនៅថ្នាក់ខេត្តឡើយ។ យ៉ាងណាក្តី គួរមានការបញ្ជាក់ឡើងវិញចំពោះ គ.អ.ជ.ខ/គប្រ ថាមិនគួរផ្តល់មូលនិធិ ឱ្យមន្ទីរលើសពីសមត្ថភាពដែលគេមាន និងខុសពីបំណងដែលគេចង់ធ្វើនោះឡើយ។

---

[១៦] គួរឱ្យចាប់អារម្មណ៍ទីប្រឹក្សាម្នាក់បានផ្តល់នូវយោបល់គាំទ្រការវិភាជន៍ថវិកាទៅអោយមន្ទីរដែលមានការស្ទាក់ស្ទើរនៃការប្រើប្រាស់មូលនិធិដូចជាហេតុផលដែល មន្ទីរមួយចំនួនមិនពេញចិត្តមូលនិធិវិនិយោគខេត្ត គឺថាមូលនិធិនេះ ត្រូវបានចាត់ចែងប្រសើរជាងដោយមានឱកាសតិចសំរាប់ការបែងចែងមូលនិធិមិនចំគោលដៅ: ដូចនេះសំខាន់ការវិភាជន៍ទៅឱ្យ "មន្ទីរជំនាញដែលរវល់" ឱ្យមាន របៀបរៀបរាយដែលមន្ទីរបានបរិយាយនូវនិតិវិធីដ៏លំបាកជាច្រើន និងកំរិតនៃការយល់ដឹងថាតើ មូលនិធិ និងសកម្មភាពត្រូវបានចាត់ចែង (មិនច្បាស់) ។

## ការត្រួតពិនិត្យដំណើរការបែងចែកថវិកានៅថ្នាក់ខេត្ត-ក្រុង

តាមរយៈការសាកសួរអ្នកដែលបានចូលរួមក្នុងដំណើរការវិភាជន៍ថវិកា ការស្វែងយល់អំពីដំណើរការនេះហាក់មិនបានគ្រប់គ្រាន់ឡើយ។ មានការត្រួតពិនិត្យដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក មួយចំនួនបានប្រព្រឹត្ត ទៅយ៉ាងល្អប្រសើរ។ ការវិភាជន៍មូលនិធិវិនិយោគខេត្ត ដោយ គ.អ.ជ.ខ មានដំណើរការរយៈពេលវែងដែលមានការ ប្រជុំបន្តបន្ទាប់គ្នា មិនងាយស្រួលក្នុងការតាមដានត្រួតពិនិត្យឡើយ។ ទោះជាយ៉ាងណាក្តី វាអាចមានប្រយោជន៍ខ្លះ ដែរ ក្នុងការយកវិធីតាមដានសមាហរណកម្មផែនការថ្នាក់ស្រុក មកប្រើក្នុងករណីនេះ។ កិច្ចការនេះអាចធ្វើបាន ដោយមន្ត្រីថ្នាក់ជាតិនិងទីប្រឹក្សា ចុះធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់ (ប្រហែលទៅនឹងការចុះទៅមើលសមាហរណកម្មថ្នាក់ ស្រុក) ឬដោយការចុះកិច្ចសន្យាជួលអ្នកសិក្សាស្រាវជ្រាវឱ្យស្នាក់នៅ និងតាមមើលក្នុងខេត្តរហូតដល់ចប់សព្វគ្រប់ ដំណើរការ[១៧]។ វិធីនេះអាចផ្តល់ឱកាសងាយស្រួលដល់អ្នកស្រាវជ្រាវដើម្បីសំភាសន៍ជាមួយអ្នកចូលរួមសំខាន់ៗ រវាងការប្រជុំនិមួយៗ ស្វែងយល់អំពីចំណេះដឹង និងឥរិយាបទរបស់ពួកគេ ចំពោះដំណើរការនេះ។

បញ្ហាមួយចំនួនដែលអាចមានតំលៃទៅនឹងការតាមដានត្រួតពិនិត្យរួមមាន:

- តើទីប្រឹក្សាមានតួនាទី អ្វីខ្លះ?
- តើអ្នកណាខ្លះចូលរួមពិភាក្សាក្នុងដំណាក់និមួយៗ នៃការធ្វើសេចក្តីសំរេច? តើនរណាមានឥទ្ធិពលជាងគេ?
- តើការមិនផ្តល់តួលេខផែនការ (PIF) ទៅឱ្យបណ្តាមន្ទីរមុនពេលធ្វើសំណើ បានជួយជំរុញឱ្យមាន ការពិភាក្សាការប្រកួតប្រជែង និងការច្នៃប្រឌិត ដល់កំរិតណាដែរ? (តើពោមការពិតខេត្តមួយចំនួនប្រើប្រាស់ តួលេខផែនការ ដើម្បីជៀសវាងទំនាស់ និងការខកចិត្ត ដែរឬទេ?
- តើជាក់ស្តែងមានមន្ទីរមួយចំនួនរួញរា ក្នុងការទទួលមូលនិធិវិនិយោគខេត្ត ដែរឬទេ?
- តើមន្ទីរនានាអនុវត្តតាមជំហានទាំងបី ក្នុងដំណើរការរៀបចំបញ្ជីសកម្មភាពអាទិភាពវិស័យបានត្រឹមកំរិតណា?
- តើទីតាំងគំរោងដែលប៉ាន់ស្មានពីដំបូង មានការកែតំរូវច្រើនឬទេ ក្នុងអំឡុងដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក?
- តើតារាងម៉ាទ្រិចនៃសកម្មភាពអាទិភាពតាមស្រុក (DPAM) មានប្រយោជន៍ឬទេ? តើតារាងនេះងាយស្រួលសំរាប់មន្ត្រីបណ្តាមន្ទីរជំនាញយល់ពត៌មានក្នុងតារាងម៉ាទ្រិចនៃសកម្មភាពតាមស្រុកឬទេ? តើបណ្តាមន្ទីរជំនាញយល់ថាតារាងនេះ មានការទាក់ទាញ ត្រឹមកំរិតណាដែរ?
- តើប្រធានបណ្តាមន្ទីរជំនាញដែលជាសមាជិក គប្រ យកប្រៀបលើ មន្ទីរដែលមិនមែនជាសមាជិក ឬទេ?
- តើអភិបាលស្រុកចូលរួមក្នុងការប្រជុំ គអជខ ដូចម្តេចដែរ? អភិបាលស្រុកបានតំណាងឱ្យផលប្រយោជន៍នៃស្រុកទាំងនោះ ឬទេ?

[១៧] មណ្ឌលសិក្សាកំរិតខ្ពស់ ជាស្ថាប័នមួយ ដែលមានការទាក់ទងក្នុងការសិក្សាពីមូលនិធិវិនិយោគខេត្ត ឆ្នាំ ២០០២ អាចមានលទ្ធភាពល្អ ដើម្បីធ្វើការងារដូចនេះ។

**អនុសាសន៍លើការវិភាជន៍ថវិកានៃមូលនិធិវិនិយោគខេត្ត តាមរយៈ គ.អ.ជ.ខ/គប្រ**

១. ការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុងទាំងមូល(១០០%) ត្រូវធ្វើឱ្យបានមុនការធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក (ត្រូវកែសំរួល ប្រកាសលេខ២៦៨០ របស់ក្រសួងផែនការ)។

២. បញ្ហា "ទទួលមូលនិធិលើស" និងមន្ទីរជំនាញដែលរូញរា គួរពិភាក្សាឱ្យបានល្អិតល្អន់នៅវេទិកាថ្នាក់ជាតិ។

៣. គួពិនិត្យកែសំរួលសមាសភាពនៃគណៈកម្មាធិការប្រតិបត្តិ/គ.អ.ជ.ខ ដោយពិចារណាលើការដកតំណាងមន្ទីរជំនាញចេញ ពីគណៈកម្មាធិការប្រតិបត្តិ។

៤. បង្កើនធនធានសំរាប់ដំណើរការត្រួតពិនិត្យតាមដាន លើការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុង (ដំណើរការត្រួតពិនិត្យសមាហរណកម្មផែនការថ្នាក់ស្រុក-ខណ្ឌឆ្នាំ ២០០៣)។

## ២. ការកំណត់គំរោងតាមរយៈបណ្តាមន្ទីរជំនាញ

*វាយតំលៃ និងវិភាគ លើការកំណត់គំរោងនៃមូលនិធិវិនិយោគខេត្ត របស់បណ្តាស្ថាប័នជំនាញ។ តើមានការផ្តល់ការប្រឹក្សាយោបល់ឬទេ? ហើយបើមាន តើអ្នកចូលរួមមានឥទ្ធិពលលើដំណើរការជ្រើសរើសឬទេ?*

**សាវតា**

ដំណើរការជ្រើសរើសគំរោងចាប់ផ្តើមនៅពេលបណ្តាមន្ទីរជំនាញរៀបចំបញ្ជីសកម្មភាពអាទិភាព។ ដំណើរការនេះត្រូវបានគូសវាសក្នុងសេចក្តីណែនាំថាជា "ដំណើរការ៣ជំហាន": សកម្មភាពអ្វី វិនិយោគកំរិតណា និងការគាំទ្រនៅកន្លែងណា។ កាលបើ គប្រ បានសំរេចវិភាជន៍មូលនិធិ និងសកម្មភាពសំរាប់មន្ទីរនិមួយៗហើយ មន្ទីរអាចពិនិត្យមើលតារាងម៉ាទ្រិចនៃសកម្មភាពអាទិភាពតាមស្រុក ដើម្បីកែសំរួលលើសកម្មភាពដែលមន្ទីរបានស្នើសុំឱ្យ ស្របតាមនោះ។ បន្ទាប់មកមន្ទីរទៅចូលរួមសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដោយមានកិច្ចសន្យាបណ្តោះអាសន្ន ដែលបានរៀបចំទុកជាមុនសំរាប់មេឃុំ/សង្កាត់ចុះហត្ថលេខា បើសិនជាពួកគាត់យល់ព្រមទទួលគំរោងទៅអនុវត្តក្នុងមូលដ្ឋានខ្លួន។

**របកគំហើញ និងការពិភាក្សា**

**ការកំណត់សកម្មភាពតាមបណ្តាមន្ទីរជំនាញ**

បណ្តាមន្ត្រីថ្នាក់ខេត្ត-ក្រុងបានរៀបរាប់ពីកត្តាជាច្រើន ដែលជះឥទ្ធិពលដល់ការកំណត់គំរោងមន្ទីរ រួមមាន: គោលនយោបាយក្រសួង ទិន្នន័យក្រសួងលើសេវាគ្របដណ្តប់ ទិន្នន័យនិងផែនការ ឃុំ/ស្រុក និងយុទ្ធសាស្ត្ររបស់ គ.អ.ជ.ខ/គប្រ។ ទោះជាយ៉ាងនេះក្តី ក្នុងពេលអនុវត្តន៍ជាក់ស្តែង ប្រធានមន្ទីរបានពេញចិត្តនឹងប្រើឆន្ទានុសិទ្ធរបស់ខ្លួននៅពេលធ្វើសំណើសុំសកម្មភាពទាំងនោះ។ តំណាងមន្ទីរអភិវឌ្ឍន៍ជនបទក្នុងខេត្តមួយ បានចាត់ទុកសំនួរអំពីការជ្រើសរើសសកម្មភាពយ៉ាងដូចម្តេច ថាជាការមិនគួរឱ្យជឿ។ គាត់បានពន្យល់ថា គាត់គ្រាន់តែអនុវត្ត សកម្មភាពដែលជាផ្នែកមួយនៃអាណត្តិការងាររបស់មន្ទីរអភិវឌ្ឍន៍ជនបទប៉ុណ្ណោះ មិនបានអនុវត្តសកម្មភាពដែលជាអាណត្តិរបស់មន្ទីរផ្សេងទៀតទេ។ ត្រូវសង្កត់សួរបន្ថែមទៀត អំពីការចាត់អាទិភាពសកម្មភាព គាត់បញ្ជាក់ថា មន្ទីរអភិវឌ្ឍន៍ជនបទ

មានផែនការដែលបានបញ្ជីគំរោងនានាតាមបរាទិភាពរួចជាស្រេចទៅហើយ ដូច្នេះបញ្ហាគឺគ្រាន់តែរើសយកគំរោងដែលមានអាទិភាពបន្ទាប់ក្នុងបញ្ជីជាការស្រេច ។

មានរបាយការណ៍បញ្ជាក់បន្ថែមទៀតថា ក្នុងករណីមួយចំនួនតារាងម៉ាទ្រិចនៃសកម្មភាពអាទិភាពរបស់ ស្រុក និងឃុំ មិនត្រូវបានចែកផ្សព្វផ្សាយដល់មន្ទីរនានាមុនសិក្ខាសាលាសមាហរណកម្មផែនការស្រុកឡើយ ដូច្នេះហើយ នៅពេលធ្វើការសំរេចចិត្ត មន្ទីរមិនអាចជ្រើសចំគំរោងអាទិភាពឃុំជានិច្ចនោះទេ។ ក្នុងអំឡុងពេលស្រាវជ្រាវ ខ្ញុំខកខានមិនបានសួរ នូវសំនួរជាគន្លឹះមួយចំនួនដែលគួរសួរ ដូចជា:

- តើមន្ទីរខេត្ត-ក្រុងបានប្រើប្រាស់តារាងម៉ាទ្រិច( ហើយយល់ឃើញថាមានប្រយោជន៍) នៃសកម្មភាពជាអាទិភាព របស់ស្រុកសំរាប់ឆ្នាំ មុនៗបានត្រឹមកំរិតណា?
- តើមានផែនការអ្វីខ្លះដែលបណ្តាមន្ទីរជំនាញខេត្ត-ក្រុងបានរៀបចំទុកជាមុនរួចហើយ ( ដូចជាផែនការ៥ឆ្នាំ) ?

ជាទូទៅ ការទទួលអារម្មណ៍ដែលខ្ញុំបង្កឱ្យមានគឺ អាទិភាពនានានិងលក្ខណ:វិនិច្ឆ័យផ្សេងៗ ត្រូវបានបកស្រាយដោយមន្ត្រីថ្នាក់ខេត្ត-ក្រុងថាជាលក្ខណ:វិនិច្ឆ័យសំរាប់ទទួលបានថវិកា។ ពោលគឺ មន្ទីរយល់ថាសកម្មភាពជាអាទិភាព ត្រូវស្ថិតក្នុងនិយាមកាមួយ ដែលកំណត់ដោយក្រសួងរបស់ខ្លួន សេចក្តីណែនាំ និង គប្រ។ យើងមិនអាចរកឃើញការពន្យល់ឱ្យបានច្បាស់លាស់ទេថាតើ លក្ខណ:វិនិច្ឆ័យនានា ត្រូវបានយកមកប្រើប្រាស់យ៉ាងដូចម្តេច សំរាប់ចាត់អាទិភាពសកម្មភាពនានា។ ដោយជាក់ស្តែងគឺនីតិវិធីពាជំហាន ( សកម្មភាព កំរិតគាំទ្រ និងទីតាំង) ក្នុងសេចក្តីណែនាំ មិនត្រូវបានឆ្លុះបង្ហាញតាមការពន្យល់នានា អំពីការជ្រើសរើសគំរោងទេ[១៨] ។

ដោយហេតុនេះហើយ វាជាការពិបាកដើម្បីប្រមើលមើលពីគុណភាព នៃសេចក្តីសំរេចនានា ដែលបានធ្វើរួច ដូចជា: ការពន្យល់នានា ហាក់មិនសុីគ្នាទៅនឹងការសំរេចដែលបានធ្វើឡើយ។ ក្នុងទិដ្ឋភាពខ្លះទៀត ប្រការនេះមិនគួរជាទីភ្ញាក់ផ្អើលណាស់ទេ។ វាអាចមើលឃើញថាជាការមិនអាច ញែកឱ្យឃើញភាពខុសគ្នារវាងសកម្មភាពដ៏មានអត្ថប្រយោជន៍ផ្សេងៗ ក្នុងបរិបទនៃការរួមចំណែកកាត់បន្ថយភាពក្រីក្រ ( ឧ. ការជួសជុលបន្ទប់រៀន ជាមួយនឹងថ្នាក់អនក្ខរកម្មមនុស្សពេញវ័យ ជាមួយនឹង ការពង្រឹងតួនាទីមាតាបិតាក្នុងការថែទាំសាលា) ។ បើសិនមន្ត្រីខេត្ត-ក្រុង អាចពាក់ពន្ធ័ក្នុងការសំរេចចិត្ត ហើយភ្ជាប់ការសំរេចចិត្តទាំងនោះ ទៅនឹងគោលនយោបាយលប់បំបាត់ភាពក្រីក្រ វាអាចនឹងមានតំលៃដល់មន្ត្រីទាំងនោះ ក្នុងការចូលរួមពិភាក្សាយោបល់អំពីគុណប្រយោជន៍នានានៃសកម្មភាពមន្ទីរ។ កិច្ចពិភាក្សាបែបនេះ អាចធ្វើឡើងនៅក្នុងវេទិកាអភិវឌ្ឍន៍ខេត្ត-ក្រុង ដែលសំដៅបង្កើតឱកាសផ្លាស់ប្តូរគំនិតជាជាងការធ្វើផែនការពិតប្រាកដ។ ( តាមការពិត គួរមានកិច្ចពិភាក្សាយោបល់បែបនេះ ចាត់ឡើងសំរាប់កសាងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រផ្សេងៗ ដែលផ្តួចផ្តើម និងចូលរួមដោយជនកម្ពុជាផ្ទាល់) ។

---

[១៨] ម្យ៉ាងទៀត ដំណើរការត្រួតពិនិត្យតាមដានដែលទាក់ទងទៅនឹងមន្ត្រីដើម្បីការសំរេចនូវបញ្ហាទាំងនេះ នឹងមានសុពលភាពជាច្រើនដែលជាវិធីមួយដែលការយល់ដឹងបំផុតលើដំណើរការជាជាង យើងរៀបចំធ្វើការសំភាសន៍រយ:ពេលខ្លីៗ ដែលមានរយ:ពេល ៨ខែបន្ទាប់ការកើតឡើង ។

## ក្នុង និងក្រៅអាទិភាពឃុំ-សង្កាត់

ជាទូទៅ មូលនិធិវិនិយោគខេត្ត ត្រូវបានរៀបចំឡើងសំរាប់ឆ្លើយតបទៅនឹងអាទិភាពនានានៃការអភិវឌ្ឍន៍មូលដ្ឋាន។ ប្រការសំខាន់គឺ អាទិភាពអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានដាក់ជូនបណ្ដាមន្ទីរជំនាញតាមរយៈផែនការវិនិយោគឃុំ-សង្កាត់ ដែលត្រូវតែស្រង់មកបញ្ចូលក្នុងតារាងម៉ាទ្រិចនៃសកម្មភាពជាអាទិភាពស្រុក-ខណ្ឌ " DPAM"រាល់ឆ្នាំ។ ដូចបានអធិប្បាយខាងលើ បណ្ដាមន្ទីរជំនាញមិនបានចាប់ផ្ដើមពិចារណាអត្ថន័យនៃតារាងម៉ាទ្រិចនេះទេ មុនពេលគេកំណត់សកម្មភាពជាអាទិភាពរបស់មន្ទីររួច និងធ្វើការ " ស្មាន " អំពីទីតាំងរបស់សកម្មភាពនៅមូលដ្ឋាន។

សូចនាករមួយដែលបានត្រួតពិនិត្យ ក្នុងទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ គឺថាតើសកម្មភាពទាំងនោះស្ថិតក្នុងបញ្ជីអាទិភាពអភិវឌ្ឍន៍របស់ឃុំ-សង្កាត់ ក្នុងឆ្នាំឬទេ។ តារាងខាងក្រោមបានបង្ហាញ ឱ្យឃើញការចុះសំរុងគ្នាយ៉ាងគួរឱ្យភ្ញាក់ផ្អើល រវាងវិស័យផ្សេងៗគ្នា និងរវាងកិច្ចសន្យាបណ្ដោះអាសន្នដែលចុះហត្ថលេខាដោយមន្ទីររដ្ឋាភិបាល (៣០%) (សូមមើលតារាងបន្ទាប់) ជាមួយនឹងកិច្ចសន្យាបណ្ដោះអាសន្នចុះហត្ថលេខាដោយអ្នកផ្ដល់ជំនួយទាំងអស់ (សូមមើលតារាងដោយផ្ទាល់ខាងក្រោម)។

**តារាងទី ៤: ប្រភពកិច្ចសន្យាបណ្ដោះអាសន្នក្នុង CIP: ទិន្នន័យ២០០៣របស់ CDPD ពីខេត្ត-ក្រុង ២៣**

| វិស័យ | កិច្ចសន្យាបណ្ដោះអាសន្នក្នុង CIP | | កិច្ចសន្យាបណ្ដោះអាសន្នក្រៅ CIP | | សរុប | |
|---|---|---|---|---|---|---|
| | បរិមាណ | % | បរិមាណ | % | បរិមាណ | % |
| រដ្ឋបាល និងសន្តិសុខ | ៦៥៧ | ២៥% | ២០២៤ | ៧៥% | ២៦៨១ | ១០០% |
| សេដ្ឋកិច្ច | ២៤២៩ | ២៩% | ៥៨៣៥ | ៧១% | ៨២៦៤ | ១០០% |
| យេនឌ័រ | ១៩២៦ | ៤១% | ២៧១៩ | ៥៩% | ៤៦៤៥ | ១០០% |
| ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | ៨៣០ | ៣៩% | ១២៩៤ | ៦១% | ២១២៤ | ១០០% |
| សង្គមកិច្ច | ៣៦៣៧ | ៣១% | ៨២៥២ | ៦៩% | ១១៨៨៩ | ១០០% |
| ការគាំទ្រសំរាប់ស្ថាប័ន | ៧ | ១% | ៤៧៤ | ៩៩% | ៤៨១ | ១០០% |
| **សរុប** | **៩៤៨៦** | **៣២%** | **២០៥៩៨** | **៦៨%** | **៣០០៨៤** | **១០០%** |

**តារាងទី៥: កិច្ចសន្យាបណ្ដោះអាសន្នដែលបានចុះហត្ថលេខា ឆ្នាំ២០០៣ តាមបណ្ដាមន្ទីរជំនាញ(CDPD)**

| មន្ទីរ | ក្នុងបញ្ជីអាទិភាពឃុំ | ក្នុងបញ្ជីអាទិភាពឃុំជាភាគរយ | មិនមានក្នុងបញ្ជីអាទិភាពឃុំ | សរុប |
|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៨១៤ | ២៤% | ២៥១១ | ៣៣២៥ |
| ពាណិជ្ជកម្ម | ៨ | ៥% | ១៦០ | ១៦៨ |
| វប្បធម៌ និងវិចិត្រសិល្បៈ | ៥២ | ២៣% | ១៧៤ | ២២៦ |
| សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២ | ១០០% | ០ | ២ |

| | | | | |
|---|---|---|---|---|
| អប់រំ យុវជន និងកីឡា | ៣៩៤ | ៤២% | ៥៤៤ | ៩៣៨ |
| បរិស្ថាន | ៣០២ | ៣០% | ៧១១ | ១០១៣ |
| សុខាភិបាល | ១០៧២ | ៣០% | ២៩១៦ | ៣៩៨៨ |
| ឧស្សាហកម្ម រ៉ែ និងថាមពល | ៨ | ១៤% | ៤៩ | ៥៧ |
| ពត៌មាន | ២០ | ១០% | ១៨៦ | ២០៦ |
| រៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់ | ៥៧ | ២៣% | ១៨៦ | ២៤៣ |
| ធម្មការ និងសាសនា | ២៤ | ២៤% | ៧៧ | ១០១ |
| ផែនការ | ០ | ០% | ៩២ | ៩២ |
| សាធារណៈការ និងដឹកជញ្ជូន | ៦០ | ៣៣% | ១២០ | ១៨០ |
| អភិវឌ្ឍន៍ជនបទ | ៤០២ | ២៩% | ៩៧៥ | ១៣៧៧ |
| សង្គមកិច្ច អតីតយុទ្ធជន | ២២១ | ៤០% | ៣២៥ | ៥៤៦ |
| ទេសចរណ៍ | ២២ | ១៩% | ៩២ | ១១៤ |
| ធនធានទឹក និងឧតុនិយម | ៨៦ | ៣៤% | ១៦៤ | ២៥០ |
| កិច្ចការនារី | ១១៦៩ | ៣៩% | ១៨៤៨ | ៣០១៧ |
| **សរុប** | **៤៧១៣** | **៣០%** | **១០៧៣០** | **១៥៤៤៣** |

ហាក់មិនមានគំលាតគ្នាច្បាស់លាស់រវាងវិស័យឬមន្ទីរផ្សេងៗឡើយ ទោះបីជាគំរោងប្រភេទហេដ្ឋារចនាសម្ព័ន្ធមានប្រៀបច្រើនទៅលើ គំរោងប្រភេទផ្សព្វផ្សាយ និងបណ្តុះបណ្តាលនានា។

តួលេខទាំងនេះ បង្កឱ្យមានការព្រួយបារម្ភ ក្នុងចំណោមមន្ត្រីដែលពាក់ព័ន្ធនឹងការចាត់ចែង និងគ្រប់គ្រងមូលនិធិវិនិយោគខេត្ត។ យ៉ាងហោចណាស់មានខេត្តពីរ ដែលយើងបានឮថាប្រធានមន្ទីរ ជំរុញឱ្យមន្ត្រីសំរបសំរួល ផ្តល់ពត៌មានឱ្យឃុំដឹងមុនអំពីការជ្រើសរើសគំរោង ដើម្បីឱ្យឃុំអាចបញ្ចូលគំរោងទាំងនោះទៅក្នុងអាទិភាពឃុំ-សង្កាត់។ ដោយពិតប្រាកដ រាល់និន្នាការបែបនេះ គឺជាការមើលស្រាលចំពោះផែនការអភិវឌ្ឍន៍ឃុំ ដែលកសាង និងធ្វើជាម្ចាស់នៅថ្នាក់មូលដ្ឋានផ្ទាល់។ នេះជាជំហានគ្រោះថ្នាក់មួយ ឆ្ពោះទៅសភាពដែលថ្នាក់លើបញ្ជោទៅថ្នាក់ក្រោមនូវអ្វីដែលគេត្រូវដាក់ក្នុងផែនការ។

មានការផ្តល់យុត្តិកម្មជាច្រើនចំពោះសកម្មភាពដែលផ្តល់ដោយមន្ទីរ តែមិនមាននៅក្នុងបញ្ជីអាទិភាពឃុំ។ ជាការពិតណាស់ ដែលថាពត៌មានបច្ចេកទេសអាចរកបានពីថ្នាក់ជាតិនិងក្រសួង ត្រូវបានប្រើជាបង្អែកផ្លូវច្បាប់ ក្នុងការជ្រើសរើសអាទិភាពខ្លះ (ឧ. ការផ្សព្វផ្សាយសុខភាពសាធារណៈ) ដែលមិនសូវជាមានលក្ខណៈបន្ទាន់ចំពោះ ប្រជាជននៅមូលដ្ឋាន។ ជាទូទៅ ភាគច្រើននៃប្រជាជននៅមូលដ្ឋានហាក់យល់ថា កិច្ចអភិវឌ្ឍន៍គឺសំដៅតែលើការកសាងហេដ្ឋារចនាសម្ព័ន្ធ មិនមែនលើការកសាងសមត្ថភាព និងសេវាផ្សព្វផ្សាយនានាឡើយ។

ក្នុងការសំភាសន៍ជាមួយក្រុមប្រឹក្សាឃុំក្នុងទីស្នាក់ការឃុំ ក៏ដូចជា ជាមួយនឹងមេឃុំ និងមន្ត្រីថ្នាក់ស្រុកនៅសាលាស្រុក មានការលើកឡើងពីបញ្ហានៃសកម្មភាពជាអាទិភាពរបស់ឃុំ។ ក្រុមប្រឹក្សាឃុំបានផ្តល់ការពន្យល់ថា

សកម្មភាពជាអាទិភាពសំខាន់ៗរបស់ឃុំ ភាគច្រើនជាគំរោងហេដ្ឋារចនាសម្ព័ន្ធដែលមានតំលៃខ្ពស់ លើសពីសមត្ថភាពថវិការបស់មន្ទីរខេត្ត ដូច្នេះហើយមន្ទីរក៏បំបែរការយកចិត្តទុកដាក់ទៅលើសកម្មភាពដែលមានតំលៃទាប ដូចជាការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ។ ហេតុផលនេះត្រូវបានទទួលយក ហើយក៏មិនមានការរិះគន់ ដល់មន្ទីរចំពោះការខកខានមិនបានឆ្លើយតបទៅនឹងអាទិភាពឃុំដែរ ។

ប្រការទាំងនេះ បង្ហាញឱ្យឃើញនូវសារៈសំខាន់ ដែលថ្នាក់ជាតិឱ្យខេត្តនានាយល់ច្បាស់ថា សមាមាត្រនៃកិច្ចសន្យាបណ្តោះអាសន្ន ដែលឆ្លើយត្បទៅនឹងបញ្ជីអាទិភាពឃុំក្នុង DPAM មិនមែនជាសូចនាករសំរាប់វាស់ការអនុវត្តរបស់មន្ទីរទេ ហើយជារឿងស្របច្បាប់ ដែលមន្ទីរអាចជ្រើសយកសកម្មភាពអាទិភាពនៅក្រៅតារាង DPAM ។ ការផ្សព្វផ្សាយស្ថិតិ៣២% និងបញ្ជាក់ថាតួលេខនេះជាបទដ្ឋានទូទៅដែលអាចទទួលយកបាន អាចជាមធ្យោបាយល្អ ក្នុងការធ្វើឱ្យមន្ត្រីនៅខេត្តមួយចំនួន មានការស្ងប់ចិត្តបាន។ សូចនាករនេះ នៅមានប្រយោជន៍ដែរ ក្នុងការជួយបង្ហាញថា តើសកម្មភាពនៃផែនការថ្នាក់ខេត្ត និងផែនការថ្នាក់ឃុំ ឆ្លើយត្បត្រឹមកំរិតណា។ ទោះយ៉ាងណាក៏ត្រូវមានសំនួរតាមដានវាយតំលៃជាច្រើនទៀត ដើម្បីសួរក្នុង ការវាយតំលៃនូវបញ្ហាទាំងនេះ ។

## ការជ្រើសរើសទីតាំងសកម្មភាពដោយបណ្តាមន្ទីរជំនាញ

ថ្វីបើការជ្រើសរើសសកម្មភាពពិបាកយល់ តែវាក៏មិនងាយនឹងមានកំហុសដែរ ដោយសារតំរូវការទាំងអស់សុទ្ធតែជាសេវាមូលដ្ឋានសំខាន់ៗ។ ការជ្រើសរើសទីតាំងគំរោងនៅមូលដ្ឋាន ជាប្រធានបទដែលរងការរិះគន់ច្រើនជាងពីមេឃុំ និងអភិបាលស្រុក ហើយជាប្រការដែលមិនងាយនឹងធ្វើឱ្យប្រសើរឡើងឡើយ ។

ក្នុងការសំភាសន៍ជាមួយមេឃុំ និងអភិបាលស្រុកនៅសាលាស្រុក យើងបានស្នើឱ្យពួកគាត់ធ្វើ ចំណាត់ថ្នាក់ភាពក្រីក្រឃុំនិមួយៗក្នុងស្រុក។ បន្ទាប់មកយើងបានពិនិត្យចំនួនកិច្ចសន្យាបណ្តោះអាសន្ន ដែលឃុំនិមួយៗបានទទួល ហើយសុំមេឃុំ និងអភិបាលស្រុកអោយធ្វើការវិភាគ និងផ្តល់យោបល់។ ជាទូទៅយើងបានរកឃើញឃុំដែលក្រជាងគេបានទទួលកិច្ចសន្យាបណ្តោះអាសន្នតិចជាងឃុំដែលធូរធា។ នៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ យើងបានសិក្សាអំពីកិច្ចសន្យាបណ្តោះអាសន្នដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០០២ និងអនុវត្តនៅឆ្នាំ២០០៣។ ក្នុងឆ្នាំ២០០២ សាលាស្រុកបានទទួលទិន្នន័យពីកម្មវិធីស្បៀងអាហារពិភពលោក (WFP) ដែលប្រើកំរិតអាហារូបត្ថម្ភជាខ្នាត ក្នុងការចាត់ថ្នាក់ភាពក្រីក្រនៃឃុំនិមួយៗ។ វិធីសាស្ត្រនេះត្រូវបានទទួលស្គាល់ថាមានភាពត្រឹមត្រូវ និងរាចយកជាការបានដោយអភិបាលស្រុក និងប្រធានឃុំ ហើយនឹងបានកំណត់ឃុំស្រែស្តុកជាឃុំដែលក្រីក្របំផុតនៅក្នុងស្រុក ក្នុងអំឡុងឆ្នាំ២០០២-២០០៣នោះ។ ពត៌មាននេះបានដឹងនៅពេលដែល សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកបានបញ្ចប់ហើយឃុំស្រែស្តុកបានទទួលកិច្ចសន្យាបណ្តោះអាសន្នតិចជាងគេបំផុត(១១) ធៀបនឹងឃុំឯទៀត (ឃុំធូរធារជាងគេបានទទួលបានកិច្ចសន្យាបណ្តោះអាសន្នចំនួន១៨ និងឃុំស្វាយហ្លួង ដែលជាឃុំធូរធារលំដាប់ទី៤នៃឃុំទាំង៩ ស្ថិតនៅបណ្តោយផ្លូវជាតិរវាងទីរូមខេត្ត និងទីរូមស្រុក ទទួលបានចំនួន៤៩គំរោង)។ អភិបាលស្រុក និងមេឃុំ បានពន្យល់ថាអ្នកផ្តល់សេវាទាំងមន្ទីរជំនាញរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល មិនចូលចិត្តធ្វើដំណើរឆ្ងាយពេក ហេតុដូចនេះបានជាជ្រើសរើសឃុំមិនសូវដាច់ស្រយាលដើម្បីធ្វើការ ហើយជាញឹកញាប់គឺប៉ះចំឃុំដែលធូរធារ។ អភិបាលស្រុក

កណ្ដៀង នៅចាំបានថាមេឃុំ បានពោលពីបញ្ហានេះនៅក្រៅអង្គប្រជុំ មិនមែនក្នុងពេលធ្វើសិក្ខាសាលាទេ។ គាត់បានពន្យល់ទៀតថា មិនសូវមានប្រយោជន៍ទេនៅពេលនោះ ដោយសារទីតាំងគំរោងត្រូវបានសំរេចរួចជាស្រេចហើយ។

ចំពោះគំរោងមួយចំនួន ទីតាំង ត្រូវបានគេកំណត់ទុកស្រេចជាមុន អាស្រ័យដោយប្រភេទនៃគំរោងនោះ។ នៅខេត្តព្រៃវែង គអជខ បានចាត់ទុកធារាសាស្ត្រជាសកម្មភាពអាទិភាព។ ឆ្លងតាមការខុសឆ្គងកន្លងមក ដែលសំណង់ធារាសាស្ត្រត្រូវយកទៅដាក់នៅក្នុងស្រុក ដែលមានប្រភពទឹកតូច ខេត្តបានសំរេចថាត្រូវសាងសង់គំរោងប្រភេទនេះនៅទីតាំងដែលមានប្រភពទឹកគ្រប់គ្រាន់។ (ចំពោះគំនិតនេះ គំរោងគាំទ្រដោយមូលនិធិប្រាសាក់ បានស្តារឡើងវិញនូវប្រឡាយចាស់ៗមួយចំនួនដែល កសាងក្នុងរបបខ្មែរក្រហម ក្នុងឃុំដែលមានទីតាំងប្រមាណ ២គម ពីទីរួមខេត្តនៃស្រុកមួយធូរធារជាងគេក្នុងខេត្ត)។

ចំពោះសកម្មភាពផ្សេងៗទៀត បានស្តែងចេញថាត្រូវមានសំណូមពរមកពីឃុំជាច្រើនក្នុងខេត្ត។ ដូចជានៅខេត្តបន្ទាយមានជ័យ បង្គន់អនាម័យសំរាប់គ្រួសារចំនួន៣០ ត្រូវបានផ្តល់ឱ្យឃុំរហាល ស្រុកបន្ទាយមានជយ័។ នៅពេលសុំអោយពន្យល់ថា ហេតុអ្វីឃុំនេះត្រូវបានជ្រើសរើស ជាជាងឃុំដ៏ទៀត មន្ត្រីមកពីមន្ទីរមិនអាចពន្យល់បានទេ។

នេះជាប្រការសមហេតុផលនិងសំខាន់ ដែលមន្ទីរជំនាញត្រូវអាចពន្យល់បានថា ហេតុអ្វីឃុំមួយ (ឬច្រើន) ត្រូវបានជ្រើសរើសមុនឃុំឯទៀតក្នុងខេត្ត ឱ្យទទួលបានការវិនិយោគ។ ក្នុងករណីសេវាសង្គមកិច្ចជាមូលដ្ឋាន គួរមានលក្ខណៈវិនិច្ឆ័យដូចជា (១)ការគ្របដណ្តប់នៃសេវាក្នុងខេត្ត និង(២) ភាពក្រីក្រ។ ពោលម៉្យាងទៀត មន្ទីរគួរកំណត់ឱ្យបាននូវឃុំដែលនៅមិនទាន់បានទទួលសេវាទាំងនេះក្នុងកំរិតសមរម្យនៅឡើយ ហើយបន្ទាប់មកមន្ទីរគួរជ្រើសរើសឃុំដែលក្រីក្រជាងគេ ក្នុងចំណោមនោះឱ្យទទួលការវិនិយោគ។ ប្រភពទិន្នន័យដែលមានការទទួលស្គាល់ និងបានធ្វើបច្ចុប្បន្នភាព (កំណត់ដោយក្រសួងផែនការ) គួរត្រូវយកមកប្រើប្រាស់ក្នុងការកំណត់រកឃុំដែលក្រីក្រ។

ក្នុងករណីវិនិយោគ ទៅលើសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច មន្ទីរគួរទទួលបានការអនុញ្ញាតិឱ្យមានភាពបត់បែនបានច្រើនទៅតាមកាលៈទេសៈ ហើយ គប្រ ត្រូវជ្រើសរើសទីតាំងដែលធានាឱ្យគំរោងទទួលបានជោគជ័យ និងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ។ ទោះជាយ៉ាងនេះក្តី បណ្តាមន្ទីរជំនាញនៅតែជាអ្នកទទួលខុសត្រូវក្នុងការបង្ហាញនូវហេតុផលដែលទីតាំងនេះត្រូវបានជ្រើសរើស ជាងទីតាំងដែលមានសក្តានុពលផ្សេងទៀតក្នុងខេត្ត។ ឧទា. មន្ទីរកសិកម្មរុក្ខា ប្រមាញ់ និងនេសាទខេត្តពោធិសាត់ ត្រូវពន្យល់ពីការជ្រើសរើសទីតាំងបឹងក្នុងឃុំត្នោតជុំ សំរាប់ការផ្តួចផ្តើមបង្កើតសមាគមន៍នេសាទ មុនទីតាំងដែលមានសក្តានុពលផ្សេងទៀតនៅក្នុងខេត្ត ឬមន្ទីរធារាសាស្ត្រ និងឧតុនិយមខេត្តព្រៃវែង ត្រូវពន្យល់នូវមូលហេតុ ដែលបានជ្រើសរើសឃុំបារាយណ៍ មុនឃុំដទៃទៀតក្នុងខេត្ត។ល។ ដើម្បីបង្កើនគុណភាពនៃការពិភាក្សា លើការសំរេច អំពីការជ្រើសរើសទីតាំង មន្ទីរគួរមានផែនទីខេត្ត(ផែនទីដែលមានច្រើនស្រទាប់) ជាជំនួយ ហើយជាពិសេសគួរតែអញ្ជើញអភិបាល ស្រុកចូលរួមដើម្បីផ្តល់ការយល់ឃើញ។

## អនុសាសន៍លើការកំណត់គំរោង

១. មន្ទីរជំនាញនានាគួរត្រូវបានហាមឃាត់ក្នុងការព្យាយាមផ្សព្វផ្សាយសេវាកម្មរបស់ខ្លួនជាមុន ដើម្បីអោយ ឃុំ-សង្កាត់ បញ្ចូលសេវាទាំងនោះទៅក្នុងបញ្ជីតំរូវការឃុំ។ មន្ទីរមិនត្រូវយល់ច្រលំថា ចំនួនកិច្ចព្រមព្រៀងបណ្តោះអាសន្នដែលត្រូវគ្នានឹងបញ្ជីអាទិភាពរបស់ឃុំ-សង្កាត់ គឺជាសូចនាករវាយតំលៃការងាររបមន្ទីរទេ ហើយតួលេខ បច្ចុប្បន្នដែលបង្ហាញថាមន្ទីរឆ្លើយតបបាន ៣០% នៃតំរូវការឃុំនោះមិនជាបញ្ហាអ្វីឡើយ។

២. បណ្តាមន្ទីរជំនាញខេត្ត-ក្រុង គួធ្វើយុត្តិកម្មសំរាប់ការជ្រើសរើសទីតាំងគំរោងរបស់ខ្លួន ដោយប្រើប្រាស់ផែនទីខេត្ត-ក្រុង ហើយអភិបាលស្រុកគួត្រូវបានអញ្ជើញឱ្យផ្តល់យោបល់ និងអនុសាសន៍ (ត្រូវកែសំរួលប្រកាស លេខ៦៨០ របស់ក្រសួងផែនការ)។

៣. ចំពោះសេវាសង្គមជាមូលដ្ឋាន លក្ខណៈវិនិច្ឆ័យដែលគួរប្រើសំរាប់ជ្រើសរើសទីតាំងគំរោងគឺ: ១) កំណត់រកឃុំ-សង្កាត់ទាំងឡាយដែលនៅមិនទាន់បានទទួលសេវាក្នុងកំរិតអប្បបរិមា។ ២) ជ្រើសរើសឃុំ-សង្កាត់ដែលក្រីក្រជាងគេក្នុងចំណោមនោះដើម្បីវិនិយោគ (ត្រូវកែសំរួលប្រកាស លេខ៦៨០របស់ក្រសួងផែនការ)។

៤. ក្រសួងផែនការគួកំណត់ទិន្នន័យសំរាប់ចាត់ថ្នាក់ភាពក្រីក្រឃុំ-សង្កាត់ ហើយធានាអោយមាន ទិន្នន័យទាំងនោះ ក្នុងទំរង់ជាផែនទី សំរាប់គ្រប់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌទាំងអស់។

៥. ក្នុងពេលកំណត់រកសកម្មភាពឆ្នាំថ្មី មន្ទីរជំនាញនានាគួរពិនិត្យឡើងវិញនូវ តារាងម៉ាទ្រិចនៃអាទិភាព ស្រុក-ខណ្ឌ (DPAM) កាលពីឆ្នាំកន្លងមក (ត្រូវកែសំរួលប្រកាសរបស់ក្រសួងផែនការ លេខ ៦៨០)។

៦. គួរផ្តល់ឱកាសក្នុងការពង្រឹងសមត្ថភាពដល់មន្ត្រីខេត្ត-ក្រុង ដើម្បីធ្វើការវាយតំលៃតាមបែបប្រៀបធៀបលើសក្តានុពលភាពក្នុងការកាត់បន្ថយភាពក្រីក្រ របស់ការវិនិយោគផ្សេងៗគ្នានៅក្នុងវិស័យទាំងនោះ (ឧទា: តាមរយៈកិច្ចពិភាក្សាតទល់ក្នុងវេទិកាអភិវឌ្ឍន៍ខេត្ត-ក្រុង)។

## ៣. ប្រសិទ្ធិភាពនៃគំរោង

*ប្រមើលមើលគុណភាពនៃគំរោងមូលនិធិវិនិយោគខេត្ត តើវាបានផលដល់អ្នកទទួលផលឬទេ? តើមានការជះឥទ្ធិពលអ្វីខ្លះដែលអាចមើលឃើញ? មាននិរន្តរភាពឬទេ? តើគំរោងទាំងនោះផ្តោតទៅរកការកាត់បន្ថយភាពក្រីក្រ និងស្របជាមួយយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឬទេ?*

### ការវាយតំលៃសកម្មភាពគំរោងមូលនិធិវិនិយោគខេត្ត

### ការទទួលខុសត្រូវសំរាប់វាយតំលៃ

មូលនិធិវិនិយោគខេត្ត គាំទ្រសកម្មភាពច្រើនប្រភេទ ទាំងធំនិងតូច រួមមានការផ្តល់សេវានានាតាមរយៈបណ្តាមន្ទីរជំនាញថ្នាក់ខេត្តនៅទូទាំងប្រទេសកម្ពុជា ដែលបំរើទិសដៅជារួមគឺរួមចំណែកកាត់បន្ថយភាពក្រីក្រ។ សំនួរដែលកើតឡើងភ្លាមៗគឺថា តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការវាយតំលៃ លើគុណភាព និងប្រសិទ្ធភាព វិនិយោគនៃមូលនិធិវិនិយោគខេត្ត។

ដោយហេតុថាកម្មវិធីសិលា ជាកម្មវិធីមួយប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តួចផ្តើមគំនិតអភិបាលកិច្ចវិមជ្ឈការ និងសហវិមជ្ឈការ សំនួរជាគន្លឹះនោះគឺ តើស្ថាប័នណាក្នុងរដ្ឋាភិបាលដែល គួរទទួលខុសត្រូវ និងមានសមត្ថភាពវាយតំលៃលើការវិនិយោគខេត្ត-ក្រុង (មិនគ្រាន់តែមូលនិធិវិនិយោគខេត្តបច្ចុប្បន្ននេះទេ តែអាចរួមទាំងការវិនិយោគដទៃទៀតដែលអនុវត្តដោយរដ្ឋអំណាចវិសហមជ្ឈការខេត្ត)? តើក្នុងករណីណាគួរមានការវាយតំលៃ "ផ្ទៃក្នុង"(អនុវត្តដោយមន្ទីរខ្លួនឯង)? ហើយក្នុងករណីណាគួរមានការវាយតំលៃពី "ក្រុមខាងក្រៅ" ឬ "ក្រុមឯករាជ្យ" ចាត់ចែងដោយរដ្ឋ (ឧទា. តាមរយៈស្ថាប័នថ្នាក់ជាតិជាអ្នករៀបចំការវាយតំលៃ ឬរៀបចំជាក្រុមដោយវិស័យឯកជន ឬជាមួយក្រុម "អតិថិជន" ឬ "សហគមន៍")?។

ចំលើយភ្លាមៗទៅនឹងសំនួរទាំងនេះមានដូចខាងក្រោមនេះ:

១. ប ណ្តាមន្ទីរជំនាញខេត្ត-ក្រុងត្រូវតែទទួលខុសត្រូវ និងមានសមត្ថភាពក្នុងការវាយតំលៃការងារ ផ្ទាល់ខ្លួន។

២. ក្នុងសភាពបច្ចុប្បន្ន មិនគួរពឹងលើអភិបាលខេត្ត-ក្រុង (តាមរយៈ គ អជខ/គប្រ) ឱ្យ លើសពីការតាមដានត្រួតពិនិត្យការអនុវត្តន៍ទៅតាមកិច្ចសន្យានោះឡើយ ទោះបីជាមានសក្តានុពលសំរាប់ គអជខ/គប្រ ក្នុងការពង្រឹងសមត្ថភាពក្នុងការតាមដានលទ្ធផល ឬផលប៉ះពាល់ មួយចំនួនឱ្យបានទាន់ ពេលក្តី។

៣. បណ្តាក្រសួងត្រូវតែទទួលខុសត្រូវ និងមានសមត្ថភាពដើម្បីវាយតំលៃការងារតាមបណ្តាមន្ទីរជំនាញថ្នាក់ខេត្ត រួមទាំងការដកស្រង់នូវបទពិសោធន៍ដោយការប្រៀបធៀបរវាងខេត្តនានា រវាងគំរោងដែលគាំទ្រដោយទីប្រឹក្សាផ្សេងគ្នា ឬដោយម្ចាស់ជំនួយដទៃពីគ្នា។ សមត្ថភាពនៃការវាយតំលៃបែបនេះ នឹងពាក់ពន្ធ័មិនត្រឹមតែការអភិវឌ្ឍន៍គោលនយោបាយរបស់សាម៉ីក្រសួងប៉ុណ្ណោះទេ តែនឹងជួយផ្តល់នូវពត៌មានសំរាប់ការជជែកអំពីគោលនយោបាយនៅថ្នាក់ផងដែរ (ឧទា. យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បើសិនបើការនេះក្លាយជាប្រធានបទមួយនៃការពិភាក្សាគោលនយោបាយជាតិ)។

ម៉្យាងវិញទៀត នៅពេលមានតំរូវការច្បាស់លាស់សំរាប់ការវាយតំលៃលើគុណភាព និងប្រសិទ្ធិភាពវិនិយោគនៃមូលនិធិវិនិយោគខេត្ត គេមិនគួរសន្និដ្ឋានថាវាជាការទទួលខុសត្រូវរបស់ អគ្គលេខាធិការដ្ឋាននៃ គ.ជ.ន.ស ទាំងស្រុងនោះឡើយ។ មានហេតុផលសមស្របជាច្រើន សំរាប់អគ្គលេខាធិការដ្ឋាន គ.ជ.ន.ស ក្នុងការបន្តពង្រឹងសមត្ថភាព បណ្តាខេត្ត-ក្រុង និងមួយផ្នែកទៀតត្រូវជួយជំរុញក្រសួងពាក់ពន្ធ័នានា ឱ្យបង្កើនសមត្ថភាពវាយតំលៃរបស់ខ្លួន។ ដោយចំពោះ កិច្ចការនេះត្រូវការផងដែរនូវការសំរបសំរួលពីម្ចាស់ជំនួយនិមួយៗ ព្រោះថា ជាជាងការធ្វើការវាយតំលៃគំរោងនិមួយៗដោយឡែកពីគ្នា បណ្តាក្រសួងគួរត្រូវបានគាំទ្រឱ្យធ្វើការ វាយតំលៃដោយប្រៀបធៀបរាល់សេវាដែលបានផ្តល់ដោយក្រសួងសាម៉ី ដើម្បីអាចរៀបចំនូវគោលនយោបាយអភិវឌ្ឍន៍ដែលមានលក្ខណៈម្ចាស់ការ និងគ្រប់ជ្រុងជ្រោយ។ ទាក់ទងនឹងធនធានមនុស្សលើបញ្ហានេះ ប្រហែលជាមិនពិបាកទេ ដោយសារក្រសួងនិមួយៗមាននាយកដ្ឋានផែនការ(ពេលនេះកម្ពុជាមានសេដ្ឋកិច្ចទីផ្សារជាជាងសេដ្ឋកិច្ចផែនការ) ដែលសមគួរនឹងតួនាទីវាយតំលៃ និងរៀបចំគោលនយោបាយ។

បន្ថែមលើសមត្ថភាពនិងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ម្ចាស់ជំនួយនានាក៏ត្រូវធានាផងដែរថា រាល់ថវិកាដែលផ្តោតឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ត្រូវបានចំណាយប្រកបដោយគតិបណ្ឌិត។ ចំពោះការវាយតំលៃដោយម្ចាស់ជំនួយ (ដូចជាការសិក្សានេះផ្ទាល់) បើចង់ឱ្យមានប្រសិទ្ធិភាព ចាំបាច់គួរមានពត៌មានអំពី គុណភាព និងប្រសិទ្ធិភាព ដែលប្រមូលនិងចងក្រងទុកស្រាប់ខ្លះ ដោយអគ្គលេខាធិការដ្ឋាន គ.ជ.ន.ស។

## ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលា

ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលា បានកត់ត្រានូវរាល់ពត៌មានស្តីពីការអនុវត្តន៍មូលនិធិវិនិយោគខេត្ត ដោយការកត់ត្រាទិន្នន័យលំអិតលើចំណូលមូលនិធិ សកម្មភាព និងលទ្ធផលនានា។ ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលាជាឧបករណ៍សំរាប់បំរើឱ្យការ ត្រួតពិនិត្យតាមដានជាជាងការវាយតំលៃ។ ពោលម៉្យាងទៀត ប្រព័ន្ធទិន្នន័យកិច្ចសន្យានេះអាចជួយមន្ត្រីថ្នាក់ជាតិ និង ម្ចាស់ជំនួយឱ្យមើលឃើញជារួមនូវអ្វីដែលបានអនុវត្តន៍រួចហើយ ប៉ុន្តែមិនផ្តល់នូវពត៌មានពីគុណភាព និងការជះឥទ្ធិពល របស់លទ្ធផលទាំងនោះ ឬក៏បទពិសោធន៍ផ្សេងៗពីការអនុវត្តន៍នោះទេ។ ការបញ្ចូលទិន្នន័យបែបបទខ្លះសំរាប់វាស់លទ្ធផល និងឱកាសសំរាប់ផ្តល់យោបល់លើគំរោងនានា ក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យា អាចជួយដល់ថ្នាក់ជាតិក្នុងការ ពិនិត្យលើប្រសិទ្ធភាពនៃគំរោងទូទាំងប្រទេសបាន។ ពត៌មានទាំងនេះមិនអាចផ្តល់ជាការសន្និដ្ឋានរួមបានទេ ប៉ុន្តែជួយតំរង់ទិសដើម្បីកំណត់រកបញ្ហា និងទីកន្លែង សំរាប់តាមដានបន្តទៅទៀត។

នៅថ្នាក់ខេត្តមានការវាយតំលៃបញ្ចប់គំរោងនានា ដែលមានសក្តានុពលភាពផ្តល់ពត៌មានជាច្រើនទៅលើគុណភាពគំរោង។ នៅថ្នាក់ជាតិនៅមិនទាន់មានយន្តការប្រមូលពត៌មានប្រភេទនេះនៅឡើយទេ។ បញ្ជីសំនួរ ដែលបានបញ្ជូនទៅគ្រប់ខេត្ត-ក្រុង គឺក្នុងគោលបំណងស្វែងរកនូវពត៌មានទាំងនេះ។

## ការវាយតំលៃបញ្ចប់គំរោងឆ្នាំ២០០៣ លទ្ធផលបញ្ជីសំនួរ

ខេត្ត-ក្រុងនីមួយៗ ត្រូវបានស្នើឱ្យពិនិត្យឡើងវិញនូវគំរោងទាំងអស់ ដែលប្រើប្រាស់មូលនិធិវិនិយោគខេត្ត ហើយដែលបានបញ្ចប់ទៅ និងបញ្ជាក់ថាតើមានធ្វើរបាយការណ៍វាយតំលៃគំរោងដែរឬទេ បើមានថាតើ គំរោងនោះត្រូវបានចាត់ថ្នាក់ដូចម្តេចៈ ពេញចិត្ត ឬ មិនពេញចិត្ត។ ខេត្ត-ក្រុងទាំង១២ដែលបាន ផ្តល់ចំលើយទៅនឹងសំនួរនេះ មានបួនរាយការណ៍ថាមានគំរោងមួយចំនួនត្រូវបានវាយតំលៃថាមិនពេញចិត្ត។ នេះបញ្ជាក់ថាដំណើរការវាយតំលៃមិនមែនគ្រាន់តែជាការ កត់សំគាល់ងាយៗថា តើគំរោងណាដែល បានបញ្ចប់ ឬមិនបានបញ្ចប់នោះទេ។

**តារាងទី ៦ៈ លទ្ធផលការវាយតំលៃតាមលើគំរោងនៃមូលនិធិវិនិយោគខេត្ត (មកពីបញ្ជីសំនួរ)**

| ខេត្ត-ក្រុង | ចំនួនគំរោង បានបញ្ចប់ | វាយតំលៃ ពេញចិត្ត | វាយតំលៃ មិនពេញចិត្ត | មិនមាន របាយការណ៍ |
|---|---|---|---|---|
| បាត់ដំបង | ២៤ | ២១(៨៧%) | 0 | ៣(១៣%) |
| កំពង់ចាម | ២៥ | ២៥(១០០%) | 0 | 0 |
| កំពង់ឆ្នាំង | ៧ | ៧(១០០%) | 0 | 0 |
| កំពង់ស្ពឺ | ១២ | ១២(១០០%) | 0 | 0 |

| | | | | |
|---|---|---|---|---|
| ភ្នំពេញ | ១០ | ១០(១០០%) | 0 | 0 |
| ព្រះវិហារ | ៣ | ៣(១០០%) | 0 | 0 |
| ព្រៃវែង | ៣ | ៣(១០០%) | 0 | 0 |
| ពោធិសាត់ | ១៨៨ | ១៨៨(១០០%) | 0 | 0 |
| រតនៈគីរី | ១០ | ១០(៧៧%) | ១(១៥%) | ២(១៥%) |
| សៀមរាប | ៣៤ | ២៧(៧៩%) | ២(១៥%) | ៥(១៥%) |
| តាកែវ | ៦៦ | ៦៦(៧០%) | ១៦(១៧%) | ១៤(១៥%) |
| ឧត្តរមានជ័យ | ៣០ | ៣០(៨១%) | ៧(១៩%) | ០(០%) |

ក្រុមសិក្សាបានទទួលពត៌មាននេះ នៅសប្តាហ៍ចុងក្រោយនៃបេសកកម្ម ហេតុដូចនេះហើយ យើងមិនអាចស្រាវជ្រាវបន្តឱ្យលំអិតជាងនេះទេ។ សំរាប់ដំណើរការប្រមូលពត៌មានវាយតំលៃទូទាំងប្រទេស ប្រព័ន្ធងាយៗស្រដៀងគ្នានេះ គួរត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលា។ ឧទាហរណ៍:

| **ការចាត់ថ្នាក់គុណភាពគំរោង** | **ការពន្យល់** |
|---|---|
| A=ល្អ B=ពេញចិត្ត C=មិនពេញចិត្ត<br>D= មិនបានវាយតំលៃ | |

ប្រការនេះ នឹងជួយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ (ដូចជាបណ្តាក្រសួង និងម្ចាស់ជំនួយនានា) ឱ្យអាចបូកសរុបពត៌មានទៅតាមប្រភេទវិស័យ ឬគំរោង ហើយកំណត់រកកត្តាសំខាន់ៗដែលជះឥទ្ធិពលទៅលើគុណភាព។ ពត៌មាននេះមិនអាចផ្តល់ការវាយតំលៃដោយជាក់លាក់ទេ ប៉ុន្តែវាជាជំហានសំខាន់ ដែលអាចធ្វើទៅមុខទៀតបាន ដោយថ្នាក់ជាតិនៅពេលនេះ។

ផ្តោតលើទស្សនៈពង្រឹងសមត្ថភាពនៃការវាយតំលៃដល់ខេត្ត-ក្រុង ខេត្តឧត្តមានជ័យ តាកែវ សៀមរាប និងរតនៈគីរី ហាក់កំពុងឈានមុខគេក្នុងកិច្ចការនេះ។ ដូច្នេះហើយការពង្រឹងសមត្ថភាព និងរៀបចំការវាយតំលៃថ្នាក់ខេត្តឱ្យទៅជាប្រពន្ធ័មួយពេញលេញ គួរផ្តែកលើបទពិសោធន៍របស់ខេត្តទាំងនោះ។ ជំហានបន្ទាប់ (ដែលយើងគួរធ្វើ និងដោយមានពេលគ្រប់គ្រាន់) គឺត្រូវសួរទៅខេត្តទាំងនោះអំពីមូលដ្ឋានដែលពួកគេវិនិច្ឆ័យគំរោងមួយថា មិនពេញចិត្ត និងថាតើបទពិសោធន៍ ដែលបានទទួលពីការវាយតំលៃនេះ ត្រូវបានយកទៅប្រើយ៉ាងដូចម្តេច ក្នុងការសំរេចចិត្តសំរាប់ មូលនិធិវិនិយោគខេត្ត ឆ្នាំ២០០៤។

**ករណីសិក្សាៈ របកគំហើញនិងបញ្ហា មកពីគំរោងស៤នៃមូលនិធិវិនិយោគខេត្ត**

ក្រុមសិក្សាអំពីមូលនិធិវិនិយោគខេត្តបានចុះទៅខេត្តប្រាំ ហើយក្នុងខេត្តនិមួយៗផ្តោតទៅលើមន្ទីរមួយ និងលើគំរោងមួយដែលគាំទ្រដោយមូលនិធិវិនិយោគខេត្ត នៅក្នុងឃុំមួយ។ សមាជិកទាំងបួនក្រុម បានចុះសិក្សារួមគ្នានៅខេត្តពោធិសាត់ ហើយបន្ទាប់មកក្រុមនិមួយៗបានចុះទៅ សិក្សានៅខេត្តមួយផ្សេងៗពីគ្នា[១៩]។

**សហគមន៍នេសាទ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់)**

ខេត្តពោធិសាត់បានទទួលមូលនិធិកំចីពី IFAD សំរាប់វិស័យកសិកម្ម ដែលផ្តល់តាមរយៈប្រព័ន្ធកម្មវិធីសិលា។ ជាទូទៅខេត្តដែលបានទទួលការគាំទ្រដោយកម្មវិធី IFAD មូលនិធិវិនិយោគខេត្តមិនត្រូវបានវិភាជន៍ សំរាប់គាំទ្រមន្ទីរកសិកម្មទេ។ ប៉ុន្តែក្នុងឆ្នាំ២០០៣ គប្រ ខេត្តពោធិសាត់បានសំរេចចិត្តវិភាជន៍ថវិកា PIF ឆ្នាំ២០០៤ ទៅឱ្យមន្ទីរកសិកម្មដែរ ដោយសារតែ IFAD មិនបានគាំទ្រដល់សកម្មភាពរុក្ខាប្រម៉ាញ់[២០] និងនេសាទ។ មានន័យថា (ខុសពីករណីបួនផ្សេងទៀត) ក្រុមបានចុះទៅសិក្សាអំពីគំរោងដែលកំពុងដំណើរការ មិនមែនងគំរោងដែលបានបញ្ចប់ ក្នុងឆ្នាំ២០០៣ឡើយ។

ក្រុមបានចុះសិក្សានៅឃុំត្នោតជុំក្នុងស្រុកក្រគរ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដំណើរការ ប្រើប្រាស់ថវិកា PIF ៤០០០ដុល្លាអាមេរិក ដើម្បីបង្កើតសមាគមន៍នេសាទមួយ។ កសិករនៅមូលដ្ឋានបានពន្យល់ថាបឹងធំនេះ (ទីតាំងបឹងនៅក្នុងផែនទីរដ្ឋបាលជាប់ទៅនឹងភូមិចំនួនបួននៅក្នុងឃុំ) ត្រូវបានប្រើប្រាស់ជាប្រភពត្រី សំរាប់សហគមន៍ក្នុងមូលដ្ឋាន។ ក៏ប៉ុន្តែ តាំងពីកងពលលេខ៨ នៃយោធាភូមិភាគទី៥ បានមកបោះទីតាំងនៅក្នុងតំបន់នេះ បរិមាណត្រីបានថយចុះស្ទើរតែអស់ ដោយសារការនេសាទដោយប្រើប្រាស់អាគុយម៉ូតូជាឧបករណ៍ឆក់។ ប្រជាជនបានពន្យល់ថា មានយោធាមួយចំនួនតូចប៉ុណ្ណោះ ដែលប្រើវិធីនេសាទបែបនេះ ហើយពេលខ្លះក៏មានប្រជាជននៅ មូលដ្ឋានផ្សេងទៀតបានប្រើវិធីនេះដែរ ដោយបន្លំខ្លួនស្លៀកពាក់ជាយោធា ដើម្បីជៀសវាងនឹង ការប្រឈមមុខផ្សេងៗ។

តាំងពីឆ្នាំ១៩៩៩មក មានអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ(ខុនសឺន) បានជួយសំរបសំរួល និងគាំទ្រគំរោងសហគមន៍ព្រៃឈើមួយនៅក្នុងតំបន់នេះ។ អ្នកភូមិបានឱ្យដឹងថា ការបង្កើតសហគមន៍ព្រៃឈើជាការងារដ៏លំបាកមួយ ដែលធ្វើឱ្យពួកគាត់រវល់ជាខ្លាំង។ សហគមន៍ព្រៃឈើជាសកម្មភាព មិនសូវមានប្រសិទ្ធិភាពទេ ប៉ុន្តែជាទូទៅ អ្នកភូមិចាត់ទុកថាមានជោគជ័យ និងមានប្រសិទ្ធិភាពក្នុងការការពារធនធានព្រៃឈើរបស់ពួកគាត់។ បទពិសោធន៍នេះ បានជួយឱ្យអ្នកភូមិយល់ពីសារប្រយោជន៍នៃការកសាងសហគមន៍ ដើម្បីការពារ និងថែរក្សាធនធានធម្មជាតិនៅមូលដ្ឋាន។ ដូចនេះហើយពួកគាត់បានស្នើដាក់ គំរោងបង្កើតសហគមន៍នេសាទ ជាអាទិភាពរបស់ឃុំ។

យោងតាមមន្ត្រីជលផលខេត្តដែលបានធ្វើដំណើរទៅជាមួយក្រុម បានឱ្យដឹងថាមន្ទីរបានដឹងរឿងបឹងនេះ តាំងពីមុនឃើញតារាងម៉ាទ្រិចនៃអាទិភាពតាមស្រុកម្លេះ។ ឆ្នាំមុនៗ មន្ទីរមានគំរោងដែលទាក់ទងការទិញកូនត្រី ពីខេត្ត

---

[១៩] មានសមាជិកក្នុងក្រុមស្នូលមួយបានដកទៅបំរើការងារក្នុងស្រុងវិញបន្ទាប់ពីសប្តាហ៍ទីមួយ។ នេះជាបញ្ហាដ៏ពិបាកសំរាប់ការងារវិភាគនៅចុងសប្តាហ៍ទីមួយ (ដែលជាញ្ហាសំខាន់ដើម្បីពង្រឹងសមត្ថភាពសំរាប់សប្តាហ៍ទីពីរ) ថែមទាំងបណ្តាឱ្យមានបង្កើតក្រុមដែលបានចុះទៅខេត្តកំពង់ឆ្នាំងមិនបានរួមបញ្ចូលនរណាម្នាក់បានបណ្តុះបណ្តាលឱ្យបាន ពេញលេញ។ ទោះជាមានគុណវិបត្តិណាមួយនៅពេលចុះសិក្សាស្រាវជ្រាវណាក៏ដោយ កត្តាដែលសំខាន់ពីមានសមត្ថភាពផ្ទាល់ខ្លួនគ្រប់គ្រាន់ ដើម្បីផ្តល់ការគាំទ្រដឹកនាំមុខ ទៅសិក្សាស្រាវជ្រាវ។

[២០] នៅពេលនេះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទជាផ្នែកមួយរបស់ក្រសួងកសិកម្មដែលកើតមានឡើងជាបន្តបន្ទាប់ ហើយក្លាយជាមន្ទីរឯករាជ្យ។

បាត់ដំបង យកមកលែងនៅបឹងនានានៅខេត្តពោធិ៍សាត់។ មន្ទីរបានចុះទៅសិក្សាគ្រប់បឹងសំខាន់ៗ នៅក្នុងខេត្ត ដើម្បីប្រមើលមើលតំរូវការសំរាប់បញ្ហានេះ។ នៅពេលនោះ អ្នកភូមិបានប្រាប់ដល់មន្ទីរថា ការស្តារប្រភពត្រីនៅបឹងនេះមិនមានប្រយោជន៍ទេ ដោយសារប្រជាជននេសាទដោយប្រើប្រាស់អាគុយសំរាប់ឆក់ត្រី។

អ្នកភូមិបានពន្យល់ថា មានសហគមន៍នេសាទអាចនឹងជួយដល់ពួកគាត់ដើម្បីថែរក្សាពូជត្រីនៅក្នុងបឹង។ អ្នកភូមិបាននិយាយថា ជាដំបូងសហគមន៍នេសាទត្រូវមានបទបញ្ជាច្បាស់លាស់ និងមានការទទួលស្គាល់ពីអាជ្ញាធរគ្រប់ថ្នាក់តាំងពីមូលដ្ឋានរហូតដល់ខេត្ត ហើយការិយាល័យជលផលត្រូវផ្តល់ឱ្យពួកគាត់នូវការជឿជាក់ក្នុងការធ្វើអន្តរាគមន៍ដោយផ្ទាល់ ក្នុងករណីប្រជាជនណាដែលនេសាទខុសច្បាស់នៅក្នុងបឹង។ អ្នកភូមិបានពន្យល់ បន្ថែមទៀតថាពួកគាត់នឹងប្រមែប្រមូលគ្នាឱ្យបានច្រើនសំរាប់តទល់ជាមួយអ្នកនេសាទខុសច្បាប់ ហើយបើសិនវិធីនេះមិនបានជោគជ័យ គាត់ជឿថាអាជ្ញាធរនឹងផ្តល់ការគាំទ្រ នៅពេលដែលសហគមន៍មានការទទួលស្គាល់ជាផ្លូវការ។

នៅពេលដែលក្រុមបានចុះទៅសិក្សា គណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវបានជ្រើសរើសរួចហើយ ប៉ុន្តែមិនទាន់បានទទួលការបណ្តុះបណ្តាល និងមិនទាន់រៀបចំលក្ខន្តិកៈផ្ទៃក្នុងនៅឡើយ។ តាមដែលអ្នកភូមិបានរៀបរាប់ដំណើរការបង្កើតសហគមន៍នេសាទ បានបញ្ចប់ជំហានទី៤ ហើយនឹងកំពុងបន្តជំហានជាបន្ទាប់រហូតដល់ជំហានទី៩ ឬ១០ (អាស្រ័យថា មានធនធានគ្រប់គ្រាន់ដើម្បីធ្វើទស្សនកិច្ចសិក្សា ទៅកាន់សហគមន៍នេសាទ ដែលបង្កើតរួចហើយមួយ ជាជំហានចុងក្រោយ)។

ប្រធានសហគមន៍ត្រូវបានជ្រើសរើស តាមរយៈការប្រជុំ ដែលបានជូនដំណឹងទៅភូមិទាំងបួនដែលមានព្រំប្រទល់ជាប់បឹង។ នៅពេលសួររំពីសមាជិក និងអ្នកដឹកនាំសហគមន៍នេសាទ បើពេទៅមន្ត្រីការិយាល័យជលផលហាក់មិនសូវដឹងច្បាស់។ នៅចុងបញ្ចប់អ្នកភូមិបានឆ្លើយតបថា គ្រប់គ្រួសាររស់នៅក្នុងភូមិទាំងបួនជាសមាជិកសហគមន៍ ប៉ុន្តែមានគ្រួសារមួយចំនួនមិនទាន់យល់ច្បាស់ពីការបង្កើតសហគមន៍នេះទេ។ ដោយពិតទៅ គេមិនអាចសន្និដ្ឋានបានថា ជំនាញក្នុងការរៀបចំសហគមន៍ នៅក្នុងមជ្ឈដ្ឋានអង្គការក្រៅរដ្ឋាភិបាល សុទ្ធតែល្អជានិច្ចទេ ប៉ុន្តែក្នុងករណីនេះ បញ្ហាចោទឡើងចំពោះ តួនាទីរបស់មន្ត្រីថ្នាក់ខេត្ត ក្នុងការកសាងសហគមន៍។

បញ្ហាយេនឌ័រក៏ត្រូវបានលើកមកពិភាក្សាផងដែរ។ សមាជិកគណៈកម្មការបានពន្យល់ថា ក្នុងគណៈកម្មការមានស្ត្រីដែលជាអ្នកទទួលខុសត្រូវខាងគណនេយ្យ ប៉ុន្តែនាងរវល់ក្នុងការរៀបចំទទួលបាយថ្ងៃត្រង់ដល់ក្រុម ស្រាវជ្រាវ និងគណៈកម្មការនៅផ្ទះរបស់នាង (នេះជាការបរាជ័យតូចមួយទៀតក្នុងសង្គ្រាមបញ្ហាយេនឌ័រ)។ ក្រុមស្រាវជ្រាវក៏បាន ពិភាក្សាលើការប្រៀបធៀបអត្ថប្រយោជន៍របស់ស្ត្រី ក្នុងការប្រឈមមុខជាមួយបុរសដែលជាអ្នកប្រព្រឹត្តិអំពើខុសច្បាប់ ដោយមិនប្រើអំពើហឹង្សា។ នេះជាគំនិតថ្មីសំរាប់សមាជិកទាំងអស់[២១]។ អ្នកខ្លះគិតថាវាអាចជាវិធីល្អ តែអ្នកខ្លះនៅតែយល់ថា ត្រូវតែប្រមូលគ្នាឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីតទល់នឹងពួកប្រព្រឹត្តល្មើស ដោយមិនគិតពីយេនឌ័រទេ។

---

[២១] សកម្មភាពតវ៉ាដោយអហឹង្សាដែលពាក់ព័ន្ធទៅនឹងបញ្ហាព្រៃឈើ ដី និងផលនេសាទនៅតាមសហគមន៍បានកើតរីកដុះដាលយ៉ាងឆាប់រហ័ស ដោយសារក្រុមស្ត្រីជាអ្នកនាំមុខ។

ពេលល្ងាចក្រុមស្រាវជ្រាវបានជួបប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាឃុំលើសកម្មភាពផ្សេងៗ ដែលគាំទ្រដោយមូលនិធិវិនិយោគខេត្តនៅក្នុងឃុំ។ ជាទូទៅសកម្មភាពទាំងនោះរួមមានៈ មន្ទីរធម្មការនិងសាសនា បានចលនាព្រះសង្ឃឱ្យចូលរួមក្នុងការថែរក្សាផ្លូវជនបទ (ជាលទ្ធផល ព្រះសង្ឃជាច្រើនបានក្លាយទៅជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងការថែទាំផ្លូវដោយផ្ទាល់ និងចេញមុខដឹកនាំសហគមន៍ក្នុងការងារនេះ)។ មន្ទីរអប់រំយុវជននិងកីឡា បានផ្តល់ការបណ្តុះបណ្តាលអក្ខរកម្មចំនួនពីរវគ្គ (ដែលអ្នកចូលរួមភាគច្រើនបានបញ្ចប់វគ្គសិក្សា)។ មន្ទីរអភិវឌ្ឍន៍ជនបទបានរៀបចំការពិសោធន៍រកជាតិអាសេននិចក្នុងទឹកអណ្តូង និងប្រជុំពីការងារថែទាំផ្លូវជនបទ។ មន្ទីរកិច្ចការនារី និងមន្ទីរសង្គមកិច្ចបានជួយគាំទ្រក្នុងការបញ្ជូនអ្នកភូមិ ទៅចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រុមប្រឹក្សាឃុំមិនដឹងច្បាស់ពីប្រសិទ្ធិភាពនៃសកម្មភាពដែលបាន គាំទ្រដោយមន្ទីរជំនាញផ្សេងៗទៀត ដូចជាមន្ទីរកសិកម្ម បានផ្តល់ការគាំទ្រប្រជាជន៩០គ្រួសារតាមរយៈកម្មវិធី IFAD (មិនមែនមូលនិធិវិនិយោគខេត្ត) និងមន្ទីរសុខាភិបាល បានផ្តល់ការគាំទ្រដល់មណ្ឌលសុខភាពនៅមូលដ្ឋាន។ មន្ទីររៀបចំដែនដី នគរូបនីយកម្មនិងសំណង់ បានបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ នូវគោលនយោបាយកំណែទំរង់ដីធ្លីដើម្បីកាត់បន្ថយភាពក្រីក្រ និងច្បាប់ភូមិបាលឆ្នាំ២០០១។ មេរៀនដ៏សំខាន់ដែលពួកគាត់នៅចងចាំបានច្បាស់ពីវគ្គនោះគឺ ប្រជាជនមិនត្រូវប្រើដីរដ្ឋ (ដីចំណីផ្លូវ) ដូចជាដីនៅសងខាងផ្លូវជាតិ ជាដើម។

## ការកើតឡើងនូវបញ្ហា

ក្រុមស្រាវជ្រាវបានចំណាយពេលមួយព្រឹកនៅក្នុងភូមិ ដោយមានការអមដំណើរពីអ្នកដឹកនាំសហគមន៍ ដែលទំនងជាមនុស្សមានឥទ្ធិពល និងមានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងភូមិ។ ប្រការនេះធ្វើឱ្យក្រុមស្រាវជ្រាវមិនហ៊ានសន្និភ្លាមថាទស្សនៈយោបល់និងពត៌មានដែលបានទទួលមកសុទ្ធតែឆ្លុះបញ្ចាំងពីស្ថានភាពពិតទាំងស្រុងទេ ជាពិសេសចំលើយពីប្រជាជនក្រីក្រនៅក្នុងសហគមន៍។ ប៉ុន្តែដោយសន្និថាការចាប់អារម្មណ៍ របស់ក្រុមស្រាវជ្រាវមានហេតុផលត្រឹមត្រូវនោះ យើងយល់ថាទស្សនៈដែលបានទទួលមក គឺជាការផ្តួចផ្តើមគំនិត ដ៏គួរទន្ទឹងរង់ចាំ។ ហេតុផលដែលនាំឱ្យសហគមន៍ចង់បានគំរោងនេះ និងមន្ទីរចង់ផ្តល់គំរោងនេះទៅឱ្យសហគមន៍ គឺគួរឱ្យយល់បាន ហើយវាជាឱកាសល្អមួយសំរាប់គំរោងជួយបង្កើនបរិមាណត្រីក្នុងបឹង ដែលនឹងជះឥទ្ធិពលដល់ករិតអាហារូបត្ថម្ភ និងភាពក្រីក្រក្នុងសហគមន៍។ មិនមានការប៉ុនប៉ងប្រមើលមើលពីតំលៃហិរញ្ញវត្ថុនៃលទ្ធផលដែលបានពីបរិមាណត្រីដែលកើនឡើង ដើម្បីធៀបនឹងទុនវិនិយោគដែលមានតំលៃ ៤០០០ ដុល្លាអាមេរិក នេះឡើយ (មើលការសិក្សាខេត្តព្រៃវែង)។

បញ្ហាសេសសល់ គឺការបារម្ភជាទូទៅ អំពីការពាក់ពន្ធ័របស់មន្ត្រីជលផល ជាអ្នកនាំមុខក្នុងការរៀបចំសហគមន៍នេះ។ នៅក្នុងវិវាទផលនេសាទនានា គេតែងឃើញសហគមន៍ និងមន្ត្រីជលផល ជាភាគីប្រឈមមុខគ្នា។ ការកាត់ចេញនូវឡូត៍នេសាទមួយចំនួននៅបឹងទន្លេសាប បានទំលាក់ដោយគំហុកនូវការគ្រប់គ្រងធនធានជលផល ទោឱ្យសហគមន៍ដែលមិនទាន់បានប្រុងប្រៀបខ្លួន ហើយព្រមគ្នានោះបានរុញច្រានមន្ត្រីជលផលចេញផុតពីភារកិច្ចដ៏មានតំលៃ ជាអ្នកចាត់ចែងការដេញថ្លៃឡូត៍ និងត្រួតមើល (ឬក៏មិនត្រួតមើលសោះ) ការអនុវត្តន៍ច្បាប់នេសាទ។ ក្នុងស្ថានភាពនេះវាអាចនឹងមានហេតុផលបង្កប់ ដែលមន្ត្រីជលផល ឈរមើលការបរាជ័យ នៃសហគមន៍នេសាទ។ តាមប្រវត្តិ ដែលកម្មវិធីសិលាព្យាយាមបង្កើនតុល្យភាពរវាងតួនាទីរបស់ រដ្ឋ និង សង្គមស៊ីវិល។ វាជាការសំខាន់ ដែលអ្នកពាក់ពន្ធ័ក្នុង

វិសយ័គ្រប់គ្រងធនធានធម្មជាតិ ត្រូវប្រុងប្រយត្ន័ជានិច្ចថា ជួនកាលការគាំទ្រឱ្យរដ្ឋាភិបាលលូកដៃចាត់ចែងដោយផ្ទាល់ក្នុងការរៀបចំសហគមន៍មិនសុទ្ធតែបានផលល្អជានិច្ចទេ តែអាចធ្វើឱ្យសហគមន៍ក្រីក្រទាំងនោះកាន់តែយ៉ាប់ជាងមុន។ ចំពោះវត្ថុផ្សព្វផ្សាយពីច្បាប់ដីធ្លី (ដែលគួរតែបញ្ជាក់អំពីសិទ្ធិរបស់អ្នកកាន់កាប់ដីដែលមិនមានក្រដាសស្នាម និងសិទ្ធិអ្នកដែលមិនកាន់កាប់ដី តែមានមធ្យោបាយទទួលបានលិខិតកាន់កាប់ ដែលជាចំនុចគន្លឹះជួយដល់អ្នកក្រនៅក្នុងច្បាប់) ក៏មានលេចឡើងនូវបញ្ហាស្រដៀងគ្នាថា តើត្រូវធ្វើបែបណាល្អ ដើម្បីរក្សាតុល្យភាពរវាង រដ្ឋ អាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិល ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

## បណ្តាញធារាសាស្រ្ត (មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង)

ឃុំបារាយណ៍មានទីតាំងប្រហែល ២គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង។ ប្រព័ន្ធធារាសាស្រ្តបានសាងសង់រួចហើយនៅសម័យប៉ុលពតក្នុងកំឡុងឆ្នាំ១៩៧៥-៧៩។ ខេត្តព្រៃវែងមានដីរាបស្មើ មានធនធានបន្តិចបន្តួច ជាមួយនឹងផ្ទៃដីដាំស្រូវដែលមានទិន្នផលទាប។ ខេត្តនេះងាយរងគ្រោះខ្លាំងដោយសារទឹកជំនន់ និងរាំងស្ងួត ប្រជាជនភាគច្រើន មានជីវភាពទាប អត្តខាត់ និងគ្មានសុវត្ថិភាព។ ដូច្នេះហើយ តែងតែមានតំរូវការយ៉ាងទទូចឱ្យមានការកសាង ប្រពន្ធ័ធារាសាស្រ្ត ដែលអាចជួយដល់កសិករក្នុងការដកលទឹកទុក ក្រោយពេលជំនន់ស្រកចុះ ដើម្បីឱ្យពួកគាត់អាចរក្សាបានការបង្កើនចំណូលពីដំណាំកសិកម្ម។

ក្នុងឆ្នាំ២០០៣ ខេត្តបានវិនិយោគមូលនិធិវិនិយោគខេត្តចំនួន ៤៣.៦០០ដុល្លា លើគំរោងជីកប្រឡាយ ដែលមានប្រវែង ៣.២៥០ម (៣៨.០៩៧ដុល្លា) និងបង្កើតក្រុមសហគមន៍អ្នកប្រើប្រាស់ទឹក[២២]។ ប្រឡាយប្រហែល ២គម (តំលៃប្រមាណ២៥.០០០ដុល្លាអាមេរិក) ស្ថិតនៅក្នុងឃុំបារាយណ៍។ នេះជាការការស្តារឡើងវិញ នូវប្រពន្ធ័ធារាសាស្រ្ត ដែលបានសាងសង់ក្នុងអំឡុងពេល១៩៧៥-៧៩ នៃរបបប៉ុលពត[២៣]។ ឃុំធ្លាប់បានទទួលការគាំទ្រដោយអង្គការ PRASAC លើគំរោងស្តារប្រឡាយមេនៅក្នុងប្រព័ន្ធនេះ និងទទួលបន្ថែមនូវមូលនិធិរបស់នាយករដ្ឋមន្ត្រី **សម្តេច ហ៊ុន សែន** ក្នុងការសាងសង់ប្រឡាយមួយខ្សែវែងនៅក្នុងឃុំ។ មេឃុំមិនបានដឹងពីតំលៃវិនិយោគទាំងនេះទេ[២៤]។ គំរោងមូលនិធិវិនិយោគខេត្តរួមបញ្ចូលទាំងការរៀបចំក្រុមអ្នកប្រើប្រាស់ទឹកផងដែរ។ យើងបានជួបសមាជិកគណកម្មការ៤រូប សមាជិកធម្មតា៥រូប និងមេឃុំ (ដែលសុទ្ធតែជាបុរស និងស្ថិតក្នុងមជ្ឈិមវ័យឡើង)។

ឃុំមានភូមិតែចំនួនពីរប៉ុណ្ណោះ។ ភូមិដែលមានប្រឡាយឆ្លងកាត់មានប្រជាជនចំនួន ៦៧៥គ្រួសារ ក្នុងនោះមាន៦២គ្រួសារ ដែលមានដីស្រែជាប់នឹងប្រឡាយ (ចំនួនសរុប១៧០ហត)។ ចំនួនសរុប៩៧គ្រួសារនៅក្នុងភូមិសង្ឃឹមថានឹងបានទទួលផលប្រយោជន៍ពីប្រឡាយ (៣៥គ្រួសារត្រូវប្រើម៉ាស៊ីនបូមទឹកយកទៅដាក់ស្រែ)។ មិនមានពត៌មាន

---

[២២] ស្រុកបន្តជីករណ្តូងក្នុងឆ្នាំ ២០០៤ ជាមួយការចាប់ផ្តើមវិភាជន៍មូលនិធិវិនិយោគខេត្តព្រៃវែងមានទឹកប្រាក់ ៦០០០០ ដុល្លារអាមេរិកដើម្បីជីកប្រឡាយដូចក្នុងប្រព័ន្ធ។ ថែមទាំងរួមបញ្ចូល ៦០០ម៉ែត្រនៅក្នុងឃុំបារាយណ៍ មានអ្នកទទួលផលចំនួន ២៣ គ្រួសារដែលមានដីស្រែចំនួនសរុប ១០ ហិកតា ដែលជាប់ទៅនឹងប្រឡាយ។

[២៣] ខ្ញុំមិនមានជំនាញបច្ចេកទេសខាងផ្នែកធារាសាស្រ្ត។ ទិប្រឹក្សា PLG ដែលមានជំនាញខាងវិស្វកម្ម និងហេដ្ឋារចនាសម្ព័ន្ធ មានការស្រពិចស្រពិលចំពោះគុណភាពនៃការរៀបចំគ្រោងការណ៍ដោយលើកឡើងជាពិសេសនូវភាពខ្វះខាតការផ្គត់ផ្គង់ទឹក និងភាពខ្វះខាតដៃប្រឡាយដ៏ទៃទៀតដើម្បីបង្ហូលទឹកបញ្ចូលស្រែដែលនៅឆ្ងាយពីប្រឡាយដែលបានជីកដោយគាំទ្រពីមូលនិធិវិនិយោគខេត្ត (ការឆ្លើយឆ្លងពី Julian Abrams ដោយផ្ទាល់នៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០០៤)។

[២៤] សូមមើលការពិភាក្សាបន្ថែមពី CSF-PIF នៅខាងក្រោម

ច្បាស់ទេអំពីស្ថានភាពនៃអ្នកមាន និងមិនមានកម្មសិទ្ធិដីធ្លីនៅក្នុងភូមិ។ ក្រោយមកមានការបញ្ជាក់ថា ពីដំបូង គ្រួសារទាំងអស់ដែលនៅក្នុងភូមិ (ពីឆ្នាំ១៩៧៩) បានទទួលការចែកដីធ្លីពីរដ្ឋអំណាចគ្រប់គ្នាទាំងអស់ តែក្រោយមកមានគ្រួសារមួយចំនួនបានលក់ដីអស់ ហើយមានគ្រួសារចំណូលស្រុកថ្មីខ្លះទៀតគ្មានដីធ្លីទេ។ ដូចនេះអាចសន្និដ្ឋានបានថា មានគ្រួសារតិចជាង១៥%នៅក្នុងភូមិ ដែលទទួលផលដោយផ្ទាល់ពីគំរោង តែនៅមិនច្បាស់លាស់ត្រង់ថាតើ គ្រួសារទាំងនោះ ធូរធា ឬក្រីក្រ ក៏វិតណាធៀបទៅនឹងស្ថានភាពទូទៅក្នុងភូមិ។

នៅឆ្នាំនេះជាឆ្នាំដំបូង ដែលគេគ្រោងដើម្បីទទួលផលពីស្រែប្រាំង ដោយការប្រើប្រព័ន្ធធារាសាស្រ្តថ្មីនេះ។ ជាលទ្ធផលមានកសិករភាគច្រើនខាតទុន។ តំណាងក្រុមអ្នកប្រើប្រាស់ទឹកបានឱ្យដឹងថា ស្រែល្អបង្គួរ ហើយកសិករអាចនឹងទទួលបានផលចំណេញ ប៉ុន្តែហ្វូងកណ្ដុរបានបំផ្លាញប្រមាណជាពាក់កណ្ដាលនៃផលដំណាំ។ កសិករបាននិយាយឆ្នាំនេះជាឆ្នាំមិនល្អ ហើយពួកគាត់សង្ឃឹមថា នៅឆ្នាំក្រោយៗទៀតបញ្ហានឹងមិនធ្ងន់ធ្ងរប៉ុន្មានទេ[២៥]។

ទោះជាមានការខាតបង់ផលជាទូទៅក្នុងឆ្នាំនេះ កសិករនៅជឿជាក់មានហេតុផលដែលពួកគាត់សង្ឃឹមអាចទទួលបានផលចំណេញពី២០-៣០លានរៀល (៥.០០០-៧.៥០០ដុល្លាអាមេរិក) ក្នុង១ឆ្នាំ ពីប្រព័ន្ធធារាសាស្ត្រថ្មីនេះ។

ក្រុមអ្នកប្រើប្រាស់ទឹកមានផែនការអង្គាសស្រូវ ៣០តក្រ (តំលៃប្រហែល៩.០០០រៀលឬ២.២៥ដុល្លា) ពីការប្រមូលផលស្រូវឆ្នាំមុន។ បើសិនបានអនុវត្តនូវផែនការនេះ គាត់នឹងទទួលបានប្រហែល១.៥លានរៀល (៣៧៥ ដុល្លា) ដើម្បីទុកថែទាំប្រព័ន្ធធារាសាស្ត្រនេះ។ ដោយសារផលស្រូវមិនល្អ ការរៃអង្គាសក៏បានមកសមាមាត្រទៅតាមនោះ គឺមានចំនួនសរុប៣៧០.០០០រៀល (៩២.៥ ដុល្លាអាមេរិក) ប៉ុណ្ណោះ។

យោងទៅតាមក្រុមអ្នកប្រើប្រាស់ទឹក ការខូចខាតដោយសារទឹកជំនន់ឆ្នាំមុន ត្រូវជួសជុលអស់ប្រមាណជា ៣-៤ លានរៀល (ឡើងដល់ ១០០០ដុល្លាអាមេរិក)។ ពួកគាត់បានវិនិច្ឆ័យថាការសាងសង់មានគុណភាពល្អ ហើយការខូចខាតនេះជា ករិតសីករិចរិលធម្មតាប៉ុណ្ណោះ។ នេះមានន័យថា ការថែទាំប្រឡាយប្រចាំឆ្នាំត្រូវការប្រមាណជា ១០%ទៅ២០%នៃប្រាក់ចំណេញប៉ាន់ស្មាន។ តួលេខទាំងអស់នេះ ត្រូវប៉ាន់ស្មានដោយមេឃុំ និងក្រុមអ្នកប្រើប្រាស់ទឹក។ ក្នុងចំណោមអ្នកទាំងនេះមិនមានអ្នកណាយល់ដឹងពីការសិក្សា ឬគណនាតាមបែបបច្ចេកទេស ដែលគេបានប្រើប្រាស់ ក្នុងការសិក្សាលទ្ធភាពសំណង់នេះទេ។

ទាំងគណៈកម្មការ និងមេឃុំមិនបានដឹងពីតំលៃសាងសង់ប្រឡាយនេះទេ ហើយមន្ត្រីមន្ទីរធនធានទឹក បាននិយាយថា រឿងនេះមិនមែនជាទាទីរបស់គណៈកម្មការនិងមេឃុំនោះទេ។ មេឃុំ និងក្រុមអ្នកប្រើប្រាស់ទឹក មិនត្រូវបានឱ្យចូលរួមប្រជុំដេញថ្លៃ មិនបានឃើញទំហំបច្ចេកទេស និងបញ្ជីសំភារៈនិងតំលៃ និងមិនមានតួនាទីសំរេចការទូទាត់ប្រាក់ឱ្យអ្នកម៉ៅការឡើយ។ មេឃុំ បារាយណ៍បានដឹងពីប្រវែងប្រឡាយ តែមិនដឹងពីជំរៅ និងទំហំទទឹង ដែលត្រូវសាងសង់ទេ គាត់ចង់បានតំលាភាពច្រើននៅត្រង់ចំនុចនេះ។

---

[២៥] បញ្ហានេះ (ខ្ញុំសន្និដ្ឋានថា) បានដឹងថាដីស្រូវនៅរដូវប្រាំងដែលទទួលបានទិន្នផលតិច ជាពិសេសរងគ្រោះដោយចាប់ផ្តើមកណ្តុរបំផ្លេចបំផ្លាញដែលគ្មានជំរើសសំរាប់ចំណើរបស់ ពួកវា។ បើសិន មានគ្រួសារជាច្រើនអាចធ្វើស្រែនៅរដូវប្រាំង និងដាំដំណាំរួបផ្សំនៅពេលជាមួយគ្នាវាអាចកាត់បន្ថយនូវការលំបាកបាន។ ដូចដែរយើងបានដឹងថា ការធ្វើស្រែនៅរដូវប្រាំងបានជួបប្រទះការលំបាកដ៏ច្រើន ដោយសារតំលៃសំភារៈខ្ពស់ (បូមទឹកដាក់ស្រែ ចំនាយបន្ថែមលើជី និងថ្នាំបំផ្លាញសត្វល្អិតជាដើម)។

នៅថ្នាក់ខេត្ត តំណាងមន្ទីរធនធានទឹក ដែលក្រុមស្រាវជ្រាវបានជួប ជឿជាក់ថាមិនមានការ សិក្សាអំពីប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់សំណង់នេះទេ។ អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទបានពន្យល់ថា រាល់ការសិក្សាបច្ចេកទេស សេដ្ឋកិច្ច និងសង្គមកិច្ច ដែលពាក់ពន្ធ័ត្រូវបានអនុវត្តដោយវិស្វករនៃអង្គការ PRASAC ហើយគំរោងនេះត្រូវបានគេរៀបចំពេញលេញទុកជាមុនហើយ។ ប៉ុន្តែ នៅពេលដែលយើងសួររកឯកសារនេះ គាត់បានពន្យល់ថា គេរៀបចំវានៅក្នុងកុំព្យូទ័រ ហើយពេលនេះមិនមាននៅសល់ទេ[២៦]។

ថ្នាក់ឃុំមិនមានទទួលការវិនិយោគផ្សេងទៀត ពីមូលនិធិ វិនិយោគខេត្តទេ ក្រៅពីការកសាងប្រឡាយបន្តមួយកង់ទៀត តាមរយៈមូលនិធិវិនិយោគខេត្តក្នុងឆ្នាំ ២០០៤។

## ការលេចឡើងនូវបញ្ហា

នៅដំណាក់ដំបូងនេះ ការវិនិយោគមិនមានផលចំណេញ ហើយថែមទាំងគ្មានចិរភាពទៀតផង។ ប៉ុន្តែដោយផ្តល់ប្រភពទឹកប្រសើរជាងមុន នោះអាចនឹងផ្តល់ផលចំណេញនៅពេលខាងមុខ។ ហើយបើសិនជាអត្រានៃការរៃអង្គាសថវិកាសំរាប់ថែទាំប្រឡាយកើនឡើងនោះ ក៏អាចមានចិរភាពដែរ។

នៅពេលនោះ ប្រហែលជាគេអាច ប្រមើលមើល ផលប៉ះពាល់នៃការកាត់បន្ថយភាពក្រីក្រឱ្យបានទូលំទូលាយដោយការពិនិត្យមើលផលប៉ះពាល់ដោយ ប្រយោល (តើភាពធូរធាររបស់៩៧គ្រួសារ ដែលទទួលផលផ្ទាល់ពីប្រឡាយជួយឱ្យប្រជាជនក្រីក្រផ្សេងទៀត មាន ឱកាសរកប្រាក់ប្រចាំថ្ងៃ ដោយការលក់ពលកម្ម ឬធ្វើមុខជំនួញតូចតាច ឬទេ? តើមានការប្រែប្រួលលើការកាន់កាប់ ដីស្រែ ដោយអ្នកដែលបានផលចំណេញច្រើន មានដីកាន់តែច្រើន ឬទេ?)[២៧]។

ដោយមិនចាំបាច់ចោទថា គំរោងនេះមានភាពខុសឆ្គង ដោយមិនបានផ្តោតលើការកាត់បន្ថយភាពក្រីក្រព្រោះផ្តោតតែទៅលើកសិករមិនសូវក្រមួយក្រុមតូច ក្នុងស្រុកមួយដ៏ធូរធារ ដែលស្ថិតចំងាយតែពីរគីឡូម៉ែត្រពីទីរួមខេត្ត។ បើសិនការវិនិយោគនេះអាចតំរង់ទិស ដែលផ្តល់ផលចំណេញខ្ពស់ និងមាននិរន្តរភាព នៅពេលនោះអាចនឹងទទួលបានយុត្តិកម្ម ខ្លះមកវិញ។ ទោះយ៉ាងណាក្តី គំរោងនេះបានទាត់ចោលសារៈសំខាន់ របស់មន្ទីរជំនាញខេត្ត ដែលត្រូវមានលទ្ធភាពផ្តល់យុត្តិកម្ម លើការជ្រើសរើសទីតាំងគំរោង ដោយធៀបទៅនឹង ជំរើសផ្សេងៗទៀតនៅទូទាំងខេត្ត មិនមែនគ្រាន់តែផ្អែកលើលក្ខខ័ណ្ឌផ្ទាល់ខ្លួននោះទេ (សូមមើលផ្នែក ១៩ ខាងលើស្តីពីការវិភាជន៍ថវិកាដោយ គ.អ.ជ.ខ /គប្រ)។

ការមិនបានសិក្សាលើប្រសិទ្ធិភាពសេដ្ឋកិច្ចជាមូលដ្ឋាន ជាប្រការគួរឱ្យបារម្ភ។ ជាការសំខាន់ ដែលការវិនិយោគលើគំរោងមានលក្ខណៈសេដ្ឋកិច្ច ត្រូវប៉ាន់តំលៃដោយផ្អែកតាម ប្រសិទ្ធភាពតំលៃនិងផលប្រយោជន៍រំពឹង

---

[២៦] មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែងមិនមានទាំងអេឡិច្រូនិច និងបច្ចេកទេសធ្វើរបាយការណ៍លើការសិក្សាសំរាប់អ្នកសំណូមពរ។ ប៉ុន្តែ អនុប្រធានបាននិយាយថា អង្គការ PRASAC បានសិក្សាយ៉ាងឆាប់រហ័សតាំងពីគ្រោងការណ៍ចាស់ និងគ្រោងថ្មី ហើយក៏ចាប់ផ្តើមសាងសង់ភ្លាម។ ឯកសារសិក្សាបានរៀបចំទុកក្នុងកុំព្យូទ័រដោយ អង្គការ PRASAC និងសំណាងអាក្រក់កម្មវិធីកុំព្យូទ័រត្រូវបានតំលើងសារជាថ្មីដោយសារប្រព័ន្ធប្រតិបត្តិ ហើយនៅពេលបញ្ចូល file ក៏បាត់អស់ (ការទំនាក់ទំនងឯក ជនជាមួយលោក ជន វ៉ាន់ណាជា SPPA ខេត្តព្រៃវែង នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤)។

[២៧] ទាក់ទងទៅនឹងគ្រួសារក្រីក្រដែលមិនអាចអត់ទ្រាំបានក្នុងឆ្នាំអាក្រក់ ហើយក៏បង្ខំចិត្តលក់ស្រូវតំលៃទាបទៅឱ្យប្រជាជននៅក្រៅភូមិ (ជាពិសេសដែលបានផ្តល់នូវគ្រោះថ្នាក់មកជិតទីរួមខេត្ត) ដែលនៅពេលនោះគ្រួសារក្រីក្រអាចមានកាលានុវត្តភាពដើម្បីប្រមើលមើលក្នុងរយៈពេលវែងក្នុងការសំរេចលើគំរោងធារាសាស្ត្រខ្លួនឯង។

ទុករបស់វា។ តាមទស្សនៈនេះ ការរំពឹងទុក (អំពីតំលៃដើម ទិន្នផល ថ្លៃទីផ្សារ តំលៃរំលោះ) ត្រូវគណនាទុកជាមុន ហើយនៅពេលនោះ ការអនុវត្តគំរោងអាចវាយតំលៃបានដោយធៀបទៅនឹងការគណនានោះ។ នៅដំណាក់នេះ វាហាក់មិនសូវសំខាន់ទេ ថាការព្យាករណ៍របស់គំរោងនេះត្រឹមត្រូវឬទេ។ វានៅសំខាន់តែត្រង់ថា គំរោងបានធ្វើរួចហើយ ត្រូវប្រើប្រាស់វាដូចម្តេច ដើម្បីយកជាបទពិសោធន៍នៅពេលគំរោងមិនបានទទួលជោគជ័យ។ និយាយម្យ៉ាងទៀតគឺ បើសិនការវិនិយោគ ៤០.០០០ដុល្លា នៅតែមិនមាននិរន្តរភាព និងមិនមានផលចំណេញ ក៏មិនមានន័យថា វាជាគំរោងមិនល្អនោះទេ។ វាអាចជាការវិនិយោគល្អមួយ ប្រសិនបើបទពិសោធន៍មកពីបរាជ័យរបស់វា ត្រូវបានយកទៅប្រើប្រាស់ដើម្បីចៀសវាងការបរាជ័យសំរាប់អនុវត្តគំរោងស្រដៀងគ្នានាអនាគត (មន្ត្រីធនធានទឹកខេត្តបានផ្តល់តួលេខប៉ាន់ស្មានថានៅឆ្នាំ២០០៣ មានការវិនិយោគសរុបចំនួន១.០០០.០០០ដុល្លា លើការកសាងធារាសាស្ត្រក្នុងខេត្តចរិកាដែលបានប្រគល់មកវិញមានចំនួន ៤០.០០០ដុល្លា តាមរយៈសកម្មភាពស្រាវជ្រាវ ប្រហែលជាមិនពិបាកទេ)។

**បង្គន់អនាម័យគ្រួសារ (មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបន្ទាយមានជ័យ)**

ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បានទទួលមូលនិធិគាំទ្រជាសំភារៈសំរាប់សាងសង់បង្គន់អនាម័យដល់៣០គ្រួសារនៅក្នុងឃុំ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានពន្យល់ថា នៅពេលមុន១មន្ទីរ ធ ានសាកល្បងណែនាំឱ្យសង់បង្គន់អនាម័យដើម្បីប្រើប្រាស់រួមគ្នា ប៉ុន្តែវិធីនេះមិនបានជោគជ័យទេ ព្រោះបង្គន់ទាំងនោះមិនត្រូវបានថែទាំឡើយ។

គេអាចដឹងច្បាស់ថាឃុំរហាលមានតំរូវការបង្គន់អនាម័យ ដោយហេតុថាមានគ្រួសារមួយចំនួនតូចប៉ុណ្ណោះដែលមានបង្គន់គ្រួសារ តែគេមិនអាចដឹងច្បាស់ថា ហេតុអ្វីបានជាឃុំនេះត្រូវបានជ្រើសរើសឱ្យទទួលយកបង្គន់អនាម័យច្រើនជាងឃុំដ៏ទៃ និងហេតុអ្វីឃុំចំនួន៦ ក្នុងទូទាំងខេត្តត្រូវបានជ្រើសរើសឱ្យទទួលគំរោងនេះ។ អភិបាលស្រុក បានពន្យល់ថាបើប្រៀបធៀបទៅឃុំផ្សេងៗទៀតក្នុងស្រុក ឃុំរហាល ជាឃុំធុនមធ្យម មិនក្រមិនមាន។ មន្ត្រីខេត្តមិនបាននិយាយដល់គោលនយោបាយក្រសួង ស្តីពីការជួយឧបត្ថម្ភបង្គន់គ្រួសារឡើយ[២៨]។

ដំណើរការជ្រើសរើសអ្នកទទួលបង្គន់អនាម័យ គឺចំនួនបង្គន់ដែលមាន ត្រូវបានប្រកាសជូនដំណឹងក្នុងអង្គប្រជុំសាធារណៈ ហើយអ្នកភូមិត្រូវបានអនុញ្ញាតិឱ្យដាក់ពាក្យសុំទៅមេភូមិ។ គ្រួសារនិមួយៗ ត្រូវចូលរួមទុនជាសាច់ប្រាក់ ៥០.០០០រៀល (១២.៥ដុល្លាអាមេរិក) និងតំរូវឱ្យសង់ជញ្ជាំងនិងដំបូលបង្គន់ ដោយខ្លួនឯង។ កត្តាពីរនេះបានផាត់ចេញជាស្រេចនូវលទ្ធភាពចូលរួមពីគ្រួសារក្រីក្រ[២៩]។

ក្នុងចំណោមបង្គន់អនាម័យ៣០ ដែលបានផ្តល់ទៅឱ្យឃុំ ជាក់ស្តែងមាន២៥បង្គន់ដែលបានសាងសង់រួច ឯបង្គន់៥ទៀត បានចែកចាយទៅឱ្យគ្រួសារហើយ តែត្រូវទុកចោលនៅលើដី ទីធ្លាផ្ទះ មិនទាន់បានសាងសង់នៅឡើយ។ បង្គន់ទាំងនេះត្រូវបានចែកតាំងពី៦ខែ មុនក្រុមស្រាវជ្រាវចុះទៅសិក្សា។ មើលទំនង បង្គន់ទាំងនេះនឹងមិនត្រូវបានប្រើទេ។

---

[២៨] មានចំនុចខ្សោយមួយដែលខ្ញុំមិនបាន (មិនទាន់) រៀបចំក្នុងពេលការស្រាវជ្រាវ ដូចជាគោលនយោបាយ។

[២៩] ជាទូទៅដើម្បីគណនាគ្រួសារដែលរស់នៅលំបាក: តាមបទពិសោធន៍របស់ខ្ញុំមានបច្ចេកទេសមួយដែលដឹងពីគ្រួសារក្រីក្រដោយគិតទៅនឹងអ្នករកបានចំណូលមួយឬពីរដែលបានចំណូលបានប្រហែល ៣០០០រៀលក្នុងមួយថ្ងៃ ហើយតែងតែបានចំណាយនៅថ្ងៃដូចគ្នាដើម្បីនឹងទិញចំណីអាហារសំរាប់គ្រួសារ។ ដូចជាគ្រួសារដែលអាចជំពាក់បំណុលគេរួចជាស្រេច ហើយអាចកើនឡើងពី៥០០០០រៀលឬច្រើនជាងនេះ ការរកស៊ីចិញ្ចឹមជីវិតមិនទៀងទាត់ ជំពាក់បំណុល។

## ការលើកឡើងនូវបញ្ហា

ប្រសិទ្ធភាពនៃបង្គន់អនាម័យឯកជន នៅក្នុងវិធានការកាត់បន្ថយភាពក្រីក្រ ត្រូវតែយកមកពិភាក្សាជាថ្មី។ វាអាចនឹងមានសក្តានុពលក្នុងការកាត់បន្ថយជំងឺឆ្លង ប៉ុន្តែបើមានតែគ្រួសារមួយចំនួនតូចក្នុងភូមិ ដែលមានបង្គន់អនាម័យ នោះពិបាកនឹងជឿថាអាចបានផលណាស់។ អាចជាយុទ្ធសាស្ត្រ សំដៅអោយមានប្រសិទ្ធភាព ដោយចាប់ផ្តើមគ្រាន់តែជាការបង្ហាញ ដើម្បីគ្រួសារផ្សេងៗទៀតបានឃើញ និងសន្សំប្រាក់ដើម្បីទិញសំភារៈសាងសង់បង្គន់អនាម័យផ្ទាល់ខ្លួន។ នេះអាចជាករណីចាប់ផ្តើមមួយ ប៉ុន្តែ អាចឃើញមានប្រសិទ្ធភាពជាង ដោយការចែកបង្គន់ ទៅឱ្យគ្រួសារក្រីក្រជាងគេ ព្រោះពួកគេមិនអាចមានថវិកាដើម្បីសាងសង់ដោយខ្លួនឯង រីឯគ្រួសារដែលបានចូលរួម ទឹកប្រាក់៥០.០០០រៀល គួរតែជាគ្រួសារដែលអាចត្រូវបានបញ្ចុះបញ្ចូល តាមរយៈការបង្ហាញនូវផលប្រយោជន៍បង្គន់ហើយ នឹងអាចកសាងបង្គន់អនាម័យផ្ទាល់ខ្លួនទាំងស្រុង ដោយមិនចាំបាច់មានការឧបត្ថម្ភពីរដ្ឋទេ។

វិធីបង្ហាញមួយទៀតដែលមានឥទ្ធិពលជាង គឺតាមរយៈការផ្តល់បង្គន់អនាម័យទៅឱ្យគ្រប់គ្រួសារ នៅក្នុងភូមិមួយ និងធ្វើការតាមដានត្រួតពិនិត្យកំរិតជំងឺ (ហើយជាពិសេសកំរិតចំណាយលើសុខភាព) ដើម្បីបង្ហាញថាបើភូមិមួយអាចគ្រប់គ្រងអនាម័យក្នុងភូមិបានល្អ ភូមិនោះនឹងមានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចប្រសើរជាងមុន។ ការអនុវត្តន៍បែបនេះ នឹងលុបចោលស្ទើរតែទាំងអស់ នូវការចូលរួមវិភាគទានពីម្ចាស់បង្គន់ផ្ទាល់[៣០]។

នៅថ្នាក់ជាតិ សកម្មភាព និងលទ្ធផលនៃគំរោងត្រូវបានកត់ត្រាថាបានបញ្ចប់ទាំងស្រុង។ មានកូឡោនមួយសំរាប់សរសេរកំណត់សំគាល់ផ្សេងៗ តែមិនឃើញមានការអធិប្បាយអ្វីអំពី បង្គន់អនាម័យ១៦.៦% ដែលមិនទាន់បានសាងសង់នោះទេ។ ពិនិត្យឱ្យល្អទៅ បើលទ្ធផលនៃគំរោងគឺជា "សំភារៈបង្គន់ត្រូវបានផ្តល់" នោះអាចចាត់ទុកថារបាយការណ៍នេះត្រឹមត្រូវហើយ។ ប៉ុន្តែ បើសិនរបាយការណ៍នេះ ត្រូវប្រើសំរាប់ជួយដល់ការវាយតំលៃជាមូលដ្ឋាន និងស្រង់រកបទពិសោធន៍ នោះត្រូវមានពត៌មានជាច្រើនថែមទៀតទើបគ្រប់គ្រាន់។ នេះជាករណីមួយដែលងាយសង្កេត និងត្រួតពិនិត្យ ព្រោះ "លទ្ធផល" របស់វាគឺ ជា "បង្គន់អនាម័យត្រូវបានសាងសង់រួច និងប្រើប្រាស់"។

"ជំរុញការសាងសង់បង្គន់អនាម័យគ្រួសារ" គឺជាសកម្មភាពមួយដែលមាននៅក្នុង NPRS និងដែលបានដាក់បញ្ចូលទៅក្នុងសេចក្តីណែនាំលេខ៦៨០ របស់ក្រសួងផែនការ។ ប៉ុន្តែ មានភាពមិនច្បាស់ត្រង់ថា ការផ្តល់បង្គន់មួយចំនួនតូចទៅឱ្យគ្រួសារក្នុងភូមិដែលជាគ្រួសារមួយក្រុមតូច គឺជាវិធីមួយដែលមានប្រសិទ្ធភាព ដើម្បីពង្រឹងអនាម័យនៅក្នុងភូមិ និងចូលរួមកាត់បន្ថយភាពក្រីក្រដែរឬទេ។

បើសិនគំរោងមានតំរូវឱ្យមាន "ការចូលរួមវិភាគទានពីមូលដ្ឋាន" នោះការមាន ឬមិនមានការចូលរួមវិភាគទាន គួរតែជាចំនុចសំខាន់មួយនៃរបាយការណ៍គំរោង (ទោះបីជាគំរោងត្រូវបានបញ្ចប់តាមផែនការ ឬក៏ទេក្តី) ទោះបីជាការសាងសង់បង្គន់ទាំងនេះអាចជា លទ្ធផល ឬក៏ជាប្រសិទ្ធផលនៃគំរោងក្តី។

---

[៣០] ខ្ញុំបានទៅដល់កន្លែងកម្មវិធី NVDP នៅក្នុងភូមិបានពង្រីកការផ្តល់បង្គន់ទៅឱ្យគ្រប់គ្រួសារ តែតំរូវឱ្យចូលរួមវិភាគទានពីមូលដ្ឋាន។ ជាលទ្ធផលមានគ្រួសារក្រីក្រ ១០ % មិនបានចូលរួមវិភាគទាន ហើយក៏មិនបានទទួលសំភារៈបង្គន់ដែរ។ ទាំងនេះត្រូវតែសំរបសំរួលផលប្រយោជន៍សុខភាព និងអនាម័យ។

## សេវាសុខភាពជាមូលដ្ឋាននៅថ្នាក់ឃុំ (មន្ទីរសុខាភិបាល ខេត្តបាត់ដំបង)

នៅឃុំចែងមានជ័យ ស្រុកបាណន់ ក្រុមសិក្សាបានចុះទៅស្រាវជ្រាវប្រសិទ្ធិផល នៃសកម្មភាពអប់រំសុខភាព ដែលខេត្តបានផ្តល់តាមរយៈកិច្ចសន្យាឆ្នាំ ២០០៣។ សកម្មភាពទាំងនោះរួមមាន:

១. ចាក់ ថ្នាំបង្ការជំងឺ៦មុខ

២. ការផ្សព្វផ្សាយអំពីជំងឺ អេដ៍/ហ៊ីវ

៣. ផ្តល់គ្រាប់ថ្នាំវិតាមីន អា និងថ្នាំទំលាក់ព្រូនដល់កុមារ និងម្តាយ (ទាំង៧ភូមិ)

៤. អប់រំសុខភាពបឋមតាមរយៈភ្នាក់ងារដែលធ្វើការក្នុងមណ្ឌលសុខភាព

៥. សកម្មភាពពន្យារកំណើត

៦. ការបង្ការជំងឺឆ្លង (គ្រុនចាញ់?)

សេវាទាំងនេះគួរតែជាផ្នែកមួយនៃការផ្តល់សេវាជាមូលដ្ឋាន តាមរយៈមណ្ឌលសុខភាពឃុំ ដែលបានសាងសង់ឡើងក្រោមការផ្តល់មូលនិធិពីអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ទស្សនៈពិភពលោក។ ជាភ័ព្វមិនល្អ មានការផ្លាស់ប្តូរព្រំប្រទល់ស្រុកប្រតិបត្តិសុខាភិបាល នៃស្រុកបាត់ដំបង និងការផ្លាស់ប្តូរបុគ្គលិកដែលជា "ជនបង្គោល" សំរាប់ការផ្តល់សេវាសុខាភិបាលតាមរយៈកម្មវិធីសិលានៅស្រុកបាណន់។ ជាលទ្ធផលនៃការប្រែប្រួលនេះ អនុកិច្ចសន្យានៃមន្ទីរសុខាភិបាលត្រូវ បានធ្វើវិសោធនកម្ម ដោយលែងឱ្យមានការគ្រប់គ្រងមូលនិធិវិនិយោគខេត្ត លើសេវាសុខភាពនៅថ្នាក់ស្រុក។ ការផ្លាស់ប្តូរនេះមិនបានបង្ហាញនៅក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលាទេ ដូច្នេះហើយ ក្រុមសិក្សាដែលបានចុះទៅដល់ឃុំ មិនអាចសិក្សាប្រសិទ្ធិភាពនៃសកម្មភាពដែលមិនបានបញ្ចប់នោះឡើយ។

ជំនួសឱ្យកិច្ចការនេះ ក្រុមស្រាវជ្រាវបានរៀបចំការចុះអង្កេតមួយ ដើម្បីស្វែងយល់ពីការប្រេប្រាស់មូលនិធិដែលត្រូវបង្វែរចេញពីឃុំចែងមានជ័យនោះ និងចុះទៅសិក្សាឃុំពីរផ្សេងទៀតដែលត្រូវទទួលសេវាដូចគ្នានេះដែរ។ ក្រុមបានរកឃើញថាថវិកាដែលបានបង្វែរពីឃុំចែងមានជ័យ ត្រូវបានវិភាជន៍ឡើងវិញ ដោយមានការចំណាយសល់ប្រាក់ចំនួន៩៩២ដុល្លា ត្រូវសងវិញទៅឱ្យ គ.ជ.ន.ស វិញ។ ពេលនោះមន្ទីរសុខាភិបាលខេត្តបានស្នើសុំប្រើថវិកានេះ ដើម្បី ទិញកុំព្យូទ័រ សំរាប់គាំទ្រ សកម្មភាពឆ្នាំ ២០០៤ ហើយសំណើនេះកំពុងស្ថិតនៅក្នុងដំណើរការលទ្ធកម្មរបស់ គ.ជ.ន.ស ។

នៅពេលក្រុមចុះទៅសិក្សា នៅឃុំព្រែកជីក និងកំពង់ព្រះ បានរកឃើញថាសកម្មភាពទាំងអស់ដែលគ្រោងទុក ត្រូវបានអនុវត្ត ដោយមានសកម្មភាពខ្លះមិនមែនគាំទ្រដោយ មូលនិធិវិនិយោគខេត្តទេ។

| ប្រភពមូលនិធិ | សកម្មភាពក្នុងឃុំព្រែកជីក | បញ្ចប់សកម្មភាព | តំលៃ |
|---|---|---|---|
| ADB-2003 | ចាក់ថ្នាំបង្ការជំងឺ ៦មុខ | បញ្ចប់ | មិនដឹង |
| PIF-2003 | អប់រំផ្សព្វផ្សាយជំងឺអេដស៍/ហ៊ីវ | បញ្ចប់ | មិនដឹង |
| ABD&WB 2003 (អភិវឌ្ឍន៍ភូមិភាគពាយ័ព្យ) | សាងសង់មណ្ឌលសុខភាពមួយ | បញ្ចប់ | មិនដឹង |
| PIF-2003 | អប់រំពីជំងឺគ្រុនចាញ់ និងផ្តល់ថ្នាំជ្រលក់មុង | បញ្ចប់ | មិនដឹង |

| PIF-2003 | ផ្តល់គ្រាប់ថ្នាំវីតាមិន អា | បញ្ចប់ | មិនដឹង |
|---|---|---|---|
| **ប្រភពមូលនិធិ** | **សកម្មភាពក្នុងឃុំព្រែកកំពង់ព្រះ** | **បញ្ចប់សកម្មភាព** | **តំលៃ** |
| PIF-2003 | តាមដាននិងពង្រឹងគណៈកម្មការមណ្ឌល សុខភាព លើការគ្រប់គ្រងដំណើរការ ហិរញ្ញប្បទាន | បញ្ចប់ | មិនដឹង |
| ADB-2003 | ចាក់ថ្នាំបង្ការជំងឺ ៦មុខ | បញ្ចប់ | មិនដឹង |
| PIF-2003 | អប់រំផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការ ថែរក្សាសុខភាពបឋម | បញ្ចប់ | មិនដឹង |
| PIF-2003 | អប់រំផ្សព្វផ្សាយជំងឺអេដស៍/ហ៊ីវ | បញ្ចប់ | មិនដឹង |
| PIF-2003 | ប្រជុំតាមដានប្រចាំខែ លើសេវា MPA | បញ្ចប់ | មិនដឹង |

(ប្រភពទិន្នន័យមកពីមន្ទីរសុខាភិបាល)

ការយល់ច្រឡំពីដំបូង ចំពោះថវិកាដែលបានគ្រោងចំណាយទៅលើឃុំចែងមានជ័យ គួបផ្សំនឹងកង្វះតំលាភាពនៅថ្នាក់មណ្ឌលសុខភាពអំពីតំលៃនៃសកម្មភាពនិមួយៗ ជាឧបសគ្គធ្វើឱ្យក្រុមស្រាវជ្រាវ មិនអាចស្វែងយល់បានអំពីការប្រើប្រាស់ថវិកាមូលនិធិវិនិយោគខេត្តក្នុងគំរោងនេះទេ ហើយក៏មិនអាចដឹងបានថាសកម្មភាពដែលធ្វើរួចទាំងនោះសក្តិសមនឹងទំហំថវិកាដែរឬទេ។ អ្វីដែលក្រុមស្រាវជ្រាវអាចដឹងបាននោះ នៅត្រឹមថា សេវាដែលបានផ្តល់នៅក្នុងឃុំនិមួយៗ មានគុណភាពតាមបទដ្ឋានត្រឹមត្រូវ។

## ការលើកឡើងនូវបញ្ហា

នេះជាការពិបាកក្នុងការវិនិច្ឆ័យលើប្រសិទ្ធិភាពនៃការវិនិយោគ ក្នុងស្ថានភាពដែលទុនត្រូវបានយកទៅប្រើចំរុះគ្នាជាមួយនឹងទុនវិនិយោគផ្សេងៗទៀត។ កិច្ចប្រឹងប្រែងរបស់ក្រុមស្រាវជ្រាវ ត្រូវបានរាំងស្ទះដោយការមិនអាចយល់បានថាតើ មូលនិធិណាគាំទ្រសកម្មភាពមួយណា ហើយយើងពិតជាមិនអាចសំរេចបានលើបញ្ហានោះឡើយ។ ជាលទ្ធផល គឺយើងពិបាកនឹងទាញចេញនូវសេចក្តីសន្និដ្ឋានអំពីប្រសិទ្ធិភាពវិនិយោគ នៃគំរោងនេះ។ យើងមិនអាចនិយាយដោយជាក់លាក់ថា គំរោងនេះខ្វះតម្លាភាពក្នុងការគាំទ្រសកម្មភាព ឬក៏ថាមានភាពខុសគ្នារវាងសកម្មភាពដែលបានចុះកិច្ចសន្យា និងការអនុវត្តជាក់ស្តែង។

ក្នុងទស្សនៈនៃការតាមដានត្រួតពិនិត្យពីថ្នាក់ជាតិ មានសារសំខាន់ណាស់ដែលថា ការធ្វើវិសោធនកម្មលើកិច្ចសន្យា ត្រូវស្ថិតក្នុងពេលសមស្រប និងក្នុងគំរិយាបទច្បាស់លាស់ របស់ថ្នាក់ខេត្ត ហើយវិសោធនកម្មត្រូវមានបញ្ចូលទៅក្នុង ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលាដែលបានផ្តល់ទៅថ្នាក់ជាតិ។

## ការពង្រឹងគណៈកម្មាធិការគាំទ្រសាលា (មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង)

ក្នុងឆ្នាំ២០០៣ ការវិភាជន៍មូលនិធិវិនិយោគខេត្តសំរាប់វិស័យអប់រំនៅខេត្តកំពង់ឆ្នាំង មានទឹកប្រាក់សរុប ១៦.៤៣៦ដុល្លា។ ក្នុងនោះរួមមាន ១០.០០០ដុល្លា សំរាប់កសាងបណ្ណាល័យក្នុងទីរួមខេត្ត ៤.០៩៤ដុល្លា សំរាប់ពង្រឹង

សមត្ថភាពគណៈកម្មការកំរងសាលារៀន( ៧សិក្ខាសាលាដែលគ្របដណ្តប់៨ស្រុក) និង ១.៣៨២ដុល្លា សំរាប់ផ្តល់គ្រឿងសង្ហារឹមដល់សាលារៀនបឋមសិក្សាមួយ។

ក្រុមស្រាវជ្រាវបានចុះទៅស្រុកសាមគ្គីមានជ័យ ដើម្បីសិក្សាពីប្រសិទ្ធិផល នៃការពង្រឹងសមត្ថភាពគណៈកម្មការកំរងសាលារៀននៅទីនោះ ដែលមានទាំងការធ្វើសិក្ខាសាលាមួយព្រឹក ដោយចំណាយអស់ ៤៨៦.៥០ ដុល្លា ផងដែរ។

| តំលៃសំរាប់សិក្ខាសាលាដើម្បីពង្រឹងគណៈកម្មាធិការកំរងសាលារៀនក្នុងស្រុកសាមគ្គីមានជ័យ ២០០៣ | | | | |
|---|---|---|---|---|
| Act B.1.5 រៀបចំសិក្ខាសាលាក្នុងស្រុកសាមគ្គីមានជ័យ | | | | |
| DSA សំរាប់អ្នកចូលរួម | នាក់/ថ្ងៃ | 110 | US$ 3,50 | US$ 385,00 |
| សំភារៈបណ្តុះបណ្តាល | Lumsum | 1 | US$ 23,50 | US$ 23,50 |
| ហ្វូតូកូបពី/ឯកសារ | Copy | 110 | US$ 0,20 | US$ 22,00 |
| អាហារសំរន់ | នាក់/ថ្ងៃ | 112 | US$ 0,50 | US$ 56,00 |
| សរុប Act B. 1.5 | | | | US$ 486,50 |

( ប្រភពៈ ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលា)

មានសាលារៀន១២ នៅក្នុងកំរងដែលក្រុមបានចុះទៅសិក្សា។ កំរងសាលានេះត្រូវបានកសាងឡើងនៅឆ្នាំ ១៩៩៩ ហើយគណៈកម្មាការរួមមាននាយកសាលានានា( មានម្នាក់ជាប្រធានគណៈកម្មការ) ប្រធានសមាគមមាតាបិតាសិស្សមកពីសាលានិមួយៗ និងតំណាងរដ្ឋអំណាចមូលដ្ឋាន។ កំរងសាលាក៏បានទទួលមូលនិធិផងដែរ ពីកម្មវិធីសកម្មភាពជាអាទិភាពរបស់រដ្ឋាភិបាល។

ក្រុមបានរកឃើញថា សមាជិកគណៈកម្មការកំរងសាលា មានការពេញចិត្តនឹងរបៀបធ្វើការនៃ គណៈកម្មការនេះ ព្រោះមានកំណត់តួនាទីនិងការទទួលខុសត្រូវច្បាស់លាស់ក្នុងគណៈកម្មការ ព្រមទាំងមានផែនការការងារ និងថវិកាច្បាស់លាស់។ សមាជិកបានរាយការណ៍ថា កំរងសាលាបានធ្វើឱ្យងាយស្រួលការគ្រប់គ្រងសាលា ជួយឱ្យប្រជាជនមានទំនាក់ទំនងជាមួយសាលាផ្សេងៗដើម្បីផ្លាស់ប្តូរបទពិសោធន៍ ធ្វើឱ្យមានភាពស្អាតនិងអនាម័យ នៅជុំវិញសាលា ជួយឱ្យកំរងសាលាងាយស្រួលទាក់ទាញការគាំទ្រពីរដ្ឋាភិបាល និងភ្នាក់ងារអន្តរជាតិ។

យោងទៅតាមអ្នកឱ្យការណ៍ មិនមានកិច្ចសន្យាបណ្តោះអាសន្នបានធ្វើជាមួយឃុំទេ ( អាចសន្មតិថាគំរោងនេះត្រូវបានអនុម័តនិងគាំទ្រពីថវិកា ២០%នៃមូលនិធិវិនិយោគដែលបានវិភាជន៍ក្រោយការធ្វើសមារណកម្មថ្នាក់ស្រុក)។

សំណាងមិនល្អ ក្រុមមិនអាចរកបាននូវពត៌មានស្តីពីលទ្ធផលសិក្ខាសាលា ឬត្រួតពិនិត្យឯកសារដ៏ទៃទៀតដែលពាក់ពន្ធ័ឡើយ។ ដូច្នេះនៅតែមានភាពមិនច្បាស់ទេថាមូលនិធិវិនិយោគខេត្តត្រូវបានចំណាយទៅលើអ្វីខ្លះ។

ការសាងសង់បណ្ណាល័យនៅទីរួមខេត្ត ត្រូវបានអនុមត័ ដើម្បីជួយសំរួលដល់ មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូដែលតាំងនៅក្បែរនោះ ហើយដែលនិស្សិតជាច្រើនបានត្អូញត្អែថាខ្វះសៀវភៅសំរាប់អាន។ គំរោងនេះមិនស្ថិតក្នុងកម្មវត្ថុនៃក្រុមសិក្សាទេ (ដូច្នេះហើយយើងមិនព្យាយាមសិក្សាទេថា តើបណ្ណាល័យត្រូវបានគ្រប់គ្រងដូចម្តេច មាន

អ្នកចូលរួមបានឬទេ។ល។) តែវាជាប្រការគួរឱ្យចាប់អារម្មណ៍ត្រង់ថា គំរោងនេះមានលក្ខណៈច្បាស់លាស់ជាគំរោងរបស់ថ្នាក់ខេត្ត។ ឬថាម៉្យាងទៀត គំរោងនេះសំដៅលើកកំពស់គុណភាពអប់រំទូទាំងខេត្ត តាមរយៈការពង្រឹងគុណភាពអប់រំគ្រូបង្រៀន វាមិនមែនប្រភេទគំរោងដែលត្រូវស្នើសុំដោយថ្នាក់ឃុំឡើយ។

## ការលើកឡើងនូវបញ្ហា

ការមិនអាចស្វែងរកឃើញនូវគោលបំណង និងមាតិកា នៃសិក្ខាសាលាពង្រឹងសមត្ថភាពសាលាកំរង គឺជាផ្នែកមួយនៃការលំបាកដែលក្រុមស្រាវជ្រាវត្រូវប្រឈម (ការពិបាកទាក់ទងទៅនឹង ការខ្វះពត៌មានពីអ្វីដែលបានកើតឡើងក្នុងអង្គប្រជុំ)។ ប្រព័ន្ធទិន្នន័យកិច្ចសន្យានៃកម្មវិធីសិលា បានចាត់លទ្ធផលនៃសិក្ខាសាលានេះជា "ការពង្រឹងសមត្ថភាពសំរាប់គណៈកម្មការសាលារៀន"។ ប្រព័ន្ធនេះអាចជួយសំរាប់គោលបំណងត្រួតពិនិត្យតាមដាន និងវាយតំលៃ (ហើយក៏អាចបញ្ជាក់ផងដែរពីគោលបំណងនៃសកម្មភាព) បើសិនវាកំណត់កំណត់លទ្ធផលជាក់លាក់ជាងនេះ។

## អនុសាសន៍លើប្រសិទ្ធភាពគំរោង

១. ការវាយតំលៃការបញ្ចប់អនុគំរោងនៃមូលនិធិវិនិយោគខេត្ត-ក្រុង គួរមានបញ្ចូលការវាយតំលៃរួមនៃ គំរោង (ល្អ/បង្គួរ/មិនអាចទទួលយកបាន) ដោយអធិប្បាយយ៉ាងសង្ខេបសំរាប់បញ្ចូលក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យាសិលា (SCD) នៅ គ.ជ.ន.ស។

២. គ.ជ.ន.ស គួរបញ្ចុះបញ្ចូលឱ្យគ្រប់បណ្តាក្រសួងរៀបចំបង្កើតអង្គភាពវាយតំលៃ និងគោលនយោបាយ ដែលត្រូវទទួលខុសត្រូវលើការវាយតំលៃរាល់គំរោងនៅក្រោមវិស័យខ្លួន (ជាពិសេសការវាយតំលៃ ប្រៀបធៀបគំរោងដែលគាំទ្រដោយម្ចាស់ជំនួយផ្សេងគ្នា) ដើម្បីកសាងគោលនយោបាយវិស័យ ដែលប្រកប ដោយភាពចុះសំរុង និងគ្រប់ជ្រុងជ្រោយ។

៣. គ.ជ.ន.ស គួរផ្អែកលើបទពិសោធន៍ខេត្ត-ក្រុង ដែលបានអនុវត្តការវាយតំលៃគំរោងឆ្នាំ២០០៣រួចហើយ ដើម្បីពង្រីកសមត្ថភាពការវាយតំលៃប្រសិទ្ធិភាពគំរោង ដល់គ្រប់ខេត្ត-ក្រុងទាំងអស់។

៤. កិច្ចសន្យាសំរាប់គំរោងនានា ដែលផ្តោតលើការអភិវឌ្ឍន៍សេដ្ឋកិច្ច គួររួមបញ្ចូលនូវការសិក្សាសាមញ្ញ អំពីប្រសិទ្ធិភាពសេដ្ឋកិច្ច។ ការសិក្សានេះអាចគិតក្នុងក៏រិតប្រហាក់ប្រហែលដោយមានទាំងការប៉ាន់ស្មានតំលៃ និងផលប្រយោជន៍ (តំលៃវិនិយោគ ទិន្នផល ថ្លៃទីផ្សារ តំលៃប្រតិបត្តិការ និងការរំលោះ) សំរាប់ជាមូលដ្ឋានដល់ការវាយតំលៃ និងដកពិសោធន៍ (ត្រូវកែសំរួល ប្រកាសលេខ៦៨០ របស់ក្រសួងផែនការ)។

៥. គ.ជ.ន.ស គួរពិនិត្យរកកាលានុវត្តភាពក្នុងការផ្តួចផ្តើមសិក្សាស្រាវជ្រាវឯករាជ្យមួយក្នុងការកសាង ជាសេចក្តីណែនាំអំពីកាលវេលាសមស្របសំរាប់មន្ត្រីខេត្ត-ក្រុង ចេញមុខដឹកនាំសំរបសំរួលរៀបចំ សហគមន៍មូលដ្ឋាន ដើម្បីការពារសិទ្ធរបស់ប្រជាពលរដ្ឋក្រីក្រទៅលើធនធានធម្មជាតិ។

៦. គប្រ នៃ គអជខ គួរបានទទួលការគាំទ្រតទៅទៀត ដើម្បីកែសំរួលឈ្មោះលទ្ធផលកិច្ចសន្យាអោយ មានលក្ខណៈច្បាស់លាស់ និងអាចវាស់បាន (ឧទាៈ សង្ខេបចំណេះដឹងឬជំនាញសំខាន់ៗដែលត្រូវផ្ទេរ ជាជាងការសរសេរមិនច្បាស់ "កសាងសមត្ថភាពលើ.........")។

## ៤. ការអនុវត្តលើកិច្ចសន្យាបណ្តោះអាសន្ន

*សិក្សាការវិនិយោគនៃមូលនិធិវិនិយោគខេត្ត និងជាពិសេសកិច្ចសន្យាបណ្តោះអាសន្ន ដែលកើតឡើងក្នុងពេលធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក តើកិច្ចសន្យាទាំងនេះបានអនុវត្តតាមផែនការឬទេ? បើគ្មានតើមានមូលហេតុអ្វីខ្លះ?*

### លទ្ធផលមកពីប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

ប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់បានកត់ត្រាគ្រប់កិច្ចសន្យាបណ្តោះអាសន្ន ដែលបានធ្វើឡើងជាមួយ ឃុំ-សង្កាត់និមួយៗ ក្នុងពេលធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក។ ប្រព័ន្ធនេះបានរក្សាទុកនូវមូលដ្ឋានទិន្នន័យបច្ចុប្បន្នភាព តាមរបាយការណ៍ត្រីមាសមកពីបណ្តាឃុំ-សង្កាត់ និងខេត្ត-ក្រុង ដែលនឹងផ្តល់ជាកំណត់ត្រា ថាតើកិច្ចសន្យាបណ្តោះអាសន្ន ត្រូវបានអនុវត្តន៍ដែរឬទេ។

មូលដ្ឋានទិន្នន័យ មានកត់ពត៌មានគ្រប់កិច្ចសន្យាបណ្តោះអាសន្នដែលបានចុះហត្ថលេខាក្នុងឆ្នាំ២០០៣ សំរាប់អនុវត្តឆ្នាំ២០០៤។ ដូច្នេះនៅចុងឆ្នាំ២០០៤ គួរផ្តល់នូវការវាយតំលៃជាទូទៅមួយស្តីពី កិច្ចសន្យាបណ្តោះអាសន្នណាបានអនុវត្តរួច និងមិនបានអនុវត្ត។ នៅពេលបច្ចុប្បន្ននេះ ពត៌មានប្រភេទនេះមិនទាន់អាចប្រើប្រាស់បាននៅឡើយ។

### លទ្ធផលមកពីបញ្ជីសំនួរ

បញ្ជីសំនួរត្រូវបានបញ្ជូនទៅមន្ទីរផែនការខេត្ត-ក្រុងនិមួយៗ។ ក្នុងនោះរួមមានសំនួរអំពីការតាមពិនិត្យលើការអនុវត្តន៍នៃកិច្ចសន្យាបណ្តោះអាសន្ន ដែលបានចុះហត្ថលេខាឆ្នាំ២០០២ សំរាប់អនុវត្តឆ្នាំ២០០៣។ ខេត្តនិមួយៗត្រូវបានសួរ ថាតើគេមានទិន្នន័យគ្រប់គ្រាន់នៅថ្នាក់ខេត្តដែរឬទេ[៣១] ហើយបើមិនមានទេសូមឱ្យផ្តល់ចំលើយដែលប្រហាក់ប្រហែល។ ខេត្តត្រូវបានស្នើឱ្យផ្តល់យោបល់ផងដែរ ទៅលើមូលហេតុដែលកិច្ចសន្យាបណ្តោះអាសន្ន មិនបានអនុវត្តតាមគំរោង (សូមមើលឧបសម្ព័ន្ធ ២សំរាប់លទ្ធផលលំអិត)។ មានតែខេត្ត៥ ដែលបានផ្តល់ពត៌មានច្បាស់លាស់អំពីចំនួនកិច្ចសន្យាបណ្តោះអាសន្ន និងចំនួនកិច្ចសន្យាបណ្តោះអាសន្នដែលបានអនុវត្តន៍រួច។

**តារាង ៧: ការតាមដានបន្តលើកិច្ចសន្យាបណ្តោះអាសន្ន**

| ឈ្មោះខេត្ត | ចំនួនកិច្ចសន្យាបណ្តោះអាសន្ន | ចំនួនដែលបានអនុវត្ត |
|---|---|---|
| កំពង់ឆ្នាំង | ១១៦០ | ៨៩៤ (៨០%) |
| ព្រះវិហារ | ៨៨០ | ៣៧៤ (៤០%) |
| ព្រៃវែង | ១៧៦៧ | ៨១៩ (៤៦%) |
| ស្វាយរៀង | ១០៣៧ | ៥៥០ (៥៣%) |
| ឧត្តរមានជ័យ | ៦៦៥ | ៥៣១ (៨១%) |

(មកពីបញ្ជីសំនួរ-ខេត្តដែលបានកត់ត្រាលំអិត)

[៣១] ពត៌មានគួរជាទ្រឹស្តីដែលអាចប្រើប្រាស់បានមកពីការចងក្រងលទ្ធផលរបាយការណ៍សមាហរណកម្មផែនការថ្នាក់ស្រុក ដោយរួមបញ្ចូលទាំងទិន្នន័យលើការតាមដានវាយតំលៃបន្តគ្រប់កិច្ចសន្យាបណ្តោះអាសន្នមកពីឆ្នាំមុនៗ។

ក្នុងខេត្តនិមួយៗ មន្ត្រីខេត្តត្រូវបានស្នើឱ្យប្រមូលទិន្នន័យពីឃុំមួយ[៣២] ស្តីពីកិច្ចសន្យាបណ្ដោះអាសន្ន ដែលបានចុះហត្ថលេខាក្នុងឆ្នាំ២០០២ សំរាប់អនុវត្តក្នុងឆ្នាំ២០០៣។ កិច្ចសន្យាបណ្ដោះអាសន្ននិមួយៗ អាចរួមបញ្ចូលសកម្មភាពជាច្រើន។ ប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ បានកត់ត្រាការអនុវត្តន៍រួចជាភាគរយ ពីបើមាន៤ ត្រូវបានអនុវត្តក្នុងចំណោម៨សកម្មភាព នឹងត្រូវចាត់ទុកថាបញ្ចប់កិច្ចសន្យាបណ្ដោះអាសន្នបាន៥០%។ ក្នុងតារាងខាងក្រោម ចំនួនទាំងពីរនេះ ត្រូវបានបង្ហាញលដាច់ដោយឡែកពីគ្នា:

**តារាង៨: ការតាមដានលើកិច្ចសន្យាបណ្ដោះអាសន្ន: មួយឃុំក្នុងខេត្ត-ក្រុង**

| ឈ្មោះឃុំ | ឈ្មោះខេត្ត | ចំនួនកិច្ចសន្យាបណ្ដោះអាសន្ន ២០០២-០៣ (ចំនួនសកម្មភាព) | ចំនួនដែលមិនបាន អនុវត្ត |
|---|---|---|---|
| មានជ័យ | បាត់ដំបង | ៨ (២៦) | ៣ (៦) |
| វាលម្លូស | កំពង់ចាម | ៧ (២៦) | ២ (២) |
| ឈូក ស | កំពង់ឆ្នាំង | ៦ (២៤) | ០ (០) |
| រកាធំ | កំពង់ស្ពឺ | ១០ (២៩) | ៥ (៧) |
| ក្ដីដូង | កំពង់ធំ | ៧ (១៨) | ២ (២) |
| លំហាច | កណ្ដាល | NR | NR |
| មនោរម្យ | មណ្ឌលគិរី[៣៣] | ២ (១២) | ២ (១១) |
| ព្រៃតាសេក | ភ្នំពេញ | ៩ (១៥) | ០ (០) |
| កំពង់ត្រាណាក់ | ព្រះវិហារ | ៩ (១៣) | ៦ (១០) |
| រោងដំរី | ព្រៃវែង | ៥ (២៣) | ១ (១៣) |
| បឹងកន្ទួច | ពោធិ៍សាត់ | ១០ (៦៣) | ២ (២) |
| ?កាជូន | រតនៈគិរី | ៤ (១៣) | ២ (៣) |
| ត្បែង | សៀមរាប | ៨ (១៤) | ១ (១) |
| ? | ព្រះសីហនុ | NR | NR |
| ?ស្វាយចេក | ស្វាយរៀង | ៥ (១៣) | ២ (៥) |
| ?សំរោង | តាកែវ | ៩ (៨) | ១ (២) |
| សំរោង | ឧត្ដរមានជ័យ | ១១ (១៦) | ០ (០) |
| ព្រៃធំ | កែប | ១៣ (៥៣) | ១២ (៣៦) |

[៣២] បានជ្រើសរើសឃុំដោយផ្អែកទៅលើមូលដ្ឋានទិន្នន័យដែលមានប្រហែលជា ៣០ កិច្ចសន្យាបណ្ដោះអាសន្នដែលបានចុះហត្ថលេខាក្នុងឆ្នាំ ២០០២ សំរាប់អនុវត្តក្នុងឆ្នាំ ២០០៣។ សំណាងអាក្រក់ ដោយសារមានការយល់ច្រឡំរវាងក្រុមស្រាវជ្រាវ និងអ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ បានជ្រើសរើសឃុំដោយប្រើប្រាស់ទិន្នន័យលើកិច្ចសន្យាបណ្ដោះអាសន្នដែលបានចុះហត្ថលេខាក្នុងឆ្នាំ ២០០៣ សំរាប់អនុវត្តក្នុងឆ្នាំ ២០០៤។ ទាំងនេះជាមធ្យោបាយដែលបានសង្ឃឹមថាការធ្វើប្រៀបធៀបរវាងអ្វីដែលបានជួយក្នុង មូលដ្ឋានទិន្នន័យ និងអ្វីដែលមានក្នុងការឆ្លើយតបតាមបញ្ជីរសំនួរក៏មិនងាយស្រួល។

[៣៣] ខេត្តមណ្ឌលគិរីបានសួរឱ្យផ្ដល់ទិន្នន័យមកពីឃុំរបៀនាក្នុងស្រុកសែនមនោរម្យ។ យើងមិនដឹងមូលហេតុថា ពត៌មានមកពីឃុំទាំងបីនេះបានប្រគល់ជូនដោយជំនួសវិញ តែពត៌មាននេះមានរួមបញ្ចូលក្នុងតារាងផ្សេងទៀត។

| សរុប | ១៦៦ (៥៤២) | ៨៧ (២០២) |
|---|---|---|

(ប្រភព: បញ្ជីសំនួរសិក្សាមូលនិធិវិនិយោគខេត្ត ២០០៤, សូមមើលឧបសម្ព័ន្ធ ២ ក្នុងឯកសារភាសារអង់គ្លេស)

ក្នុងឃុំដែលបានជ្រើសរើសទាំងនេះ មាន៨៧គំរោងក្នុងចំណោម១៦៦ (៥២%) កិច្ចសន្យាបណ្តោះអាសន្ន មិនត្រូវបានអនុវត្តន៍ (ឬម៉្យាងទៀត មាន២០២សកម្មភាព ក្នុងចំណោម៥៤២ "៣៧%" សកម្មភាព)។ ហេតុផលដែលប្រមូលបានមានដូចក្នុងតារាងខាងក្រោម។

**តារាង៩: ការតាមដានបន្តលើកិច្ចសន្យាបណ្តោះអាសន្ន**

| ល.រ | មូលហេតុ | ភាពញឹកញាប់ XX (X%) |
|---|---|---|
| ១ | មិនបានផ្តល់មូលហេតុ | ២៣ (១២%) |
| ២ | ការវិភាជន៍ឡើងវិញទៅអោយតំបន់គោលដៅផ្សេងទៀត | ២ |
| ៣ | (ខ្វះ) ថវិការដ្ឋ | ៥ (៣%) |
| ៤ | ឃុំមិនបានបញ្ជូនអ្នកណាម្នាក់ទៅរៀនសូត្រ | ១ |
| ៥ | ខ្វះមូលនិធិ | ១៤២ (៧១%) |
| ៦ | ពួកគេនិយាយថា មិនដឹងពីមូលហេតុ | ៧ (៤%) |
| ៧ | មន្ទីរបានផ្លាស់ប្តូរយុទ្ធសាស្ត្រ | ២ |
| ៨ | មិនមានមន្ត្រីគ្រប់គ្រាន់ដើម្បីអនុវត្តការងារ | ១ |
| ៩ | មិនទាន់មានកម្មវិធីសិលា | ១០ (៥%)[៣៨] |
| ១០ | ការវាយតំលៃគំរោងមកពីឆ្នាំមុនៗ មិនសូវល្អ | ១ |
| ១១ | អង្គភាពដែលបានគាំទ្រការងារមិនបានមក | ៥ (៣%) |
| សរុប | | ១៩៩ |

(មកពីបញ្ជីសំនួរ)

"ការខ្វះមូលនិធិ" ឆ្លុះបញ្ចាំងនូវអ្វីដែល ក្រុមស្រាវជ្រាវបានរកឃើញក្នុងឃុំដែលមានករណីសិក្សា តែអាចកត់សំគាល់បានថា ភាគច្រើននៃគំរោងដែលគាំទ្រដោយមូលនិធិវិនិយោគខេត្ត ត្រូវបានអនុវត្តន៍តាមការសន្យា។ ការខកខានមិនបានអនុវត្តន៍ការសន្យា ហាក់ជានិន្នាការក្នុងចំណោមគំរោងអង្គការក្រៅរដ្ឋាភិបាលនិងម្ចាស់ជំនួយផ្សេងទៀត។ មានការកត់សំគាល់ថា នៅកន្លែងដែលដំណើរការសមាហរណកម្មស្រុក ត្រូវបានគេស្គាល់ច្បាស់ នោះអង្គការមិនមែនរដ្ឋាភិបាលមានការប្រុងប្រយ័ត្នច្រើនលើអ្វីដែលគេធ្វើការសន្យា តែចំពោះអង្គការដែលទើបតែចូលរួមថ្មីៗ ពួកគេហាក់ចូលចិត្តធ្វើការសន្យាដែលមិនសូវពិតប្រាកដ។ មានកត្តាផ្សេងទៀត ដែលអាជ្ញាធរខេត្តបានកត់សំគាល់ឃើញគឺ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ប្រើប្រាស់កិច្ចសន្យាបណ្តោះអាសន្នជាឧបករណ៍សំរាប់ ដើរស្វែងរកមូលនិធិ។ ដូច្នេះគេធ្វើកិច្ចសន្យាជាមួយឃុំ ហើយបន្ទាប់មកប្រើប្រាស់កិច្ចសន្យា នេះដើម្បីព្យាយាមទាក់ទាញមូលនិធិ ពីម្ចាស់ជំនួយនានា។

[៣៨] រាល់ការឆ្លើយតបទាំងអស់នេះមកពីឃុំមួយក្នុងខេត្តបណ្តាលឥរី។

បើសិនការធ្វើបែបនេះ ត្រូវបានឃុំដឹងនិងយល់ស្របជាមួយនោះ អាចជាយុទ្ធសាស្ត្រមួយស្របច្បាប់ ប៉ុន្តែវានឹងធ្វើឱ្យយើងត្រូវប្រុងប្រយ័ត្នជាងមុន នៅពេលធ្វើការសន្និដ្ឋាន អំពីអត្ថន័យនៃចំនួនកិច្ចសន្យា ដ៏ច្រើនដែលមិនបានអនុវត្ត ។

## លទ្ធផលមកពីការចុះទៅសិក្សាស្រាវជ្រាវនៅខេត្តថ្មី

តំរូវការពតិមាននៅក្នុងអំឡុងពេលចុះទៅស្រាវជ្រាវ អាចជួយឱ្យមានការត្រួតពិនិត្យម៉ត់ចត់ជាងមុន នូវសកម្មភាពដែលបានអនុវត្តរួច និងហេតុអ្វីបានជាអនុវត្តន៍/មិនអនុវត្តន៍ ។ សំនួរត្រូវបានសួរទាំងថ្នាក់ឃុំ និងស្រុក ហើយមាន សេចក្តីសង្ខេបនៃចំលើយកោនដូចក្នុងតារាងខាងក្រោមនេះ:

### តារាង១០: ការតាមដានលើកិច្ចសន្យាបណ្តោះអាសន្ន ក្នុងឃុំនិងស្រុកដែលបានជ្រើសរើស

| ឈ្មោះខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ[៣៩] |
|---|---|---|
| ពោធិ៍សាត់ | សរុបមាន២១៦ TAs និងមិនបានអនុវត្ត ១៩។ មានបញ្ចូល ទាំងកិច្ចសន្យាបណ្តោះអាសន្នផ្នែកសុខាភិបាល៣ និងPDLM នៃមូលនិធិវិនិយោគខេត្ត២ បានអនុវត្តទាំងពីរផ្នែក (មើលអត្ថបទ) ។ | មាន២១៥TAs មិនបានអនុវត្ត៣ ក្នុងនោះមាន កិច្ចសន្យារបស់NGOs១ ដែលមិនមានមូលនិធិ សំរាប់បណ្តុះបណ្តាល ។ មានគំរោងនៃមូលនិធិ វិនិយោគខេត្តចំនួនពីរដែលបានបញ្ចប់ (ផ្នែកសុខាភិបាល និង PDLM) ។ |
| បាត់ដំបង | មាន៤៦TAs មិនបានអនុវត្ត២ ។ NGOs តែមួយក្នុងករណីទាំងពីរ ។ | មាន៨TAs ។ មាន១មិនបានអនុវត្តន៍ NGOs បានជូន ដំណឹងទៅឃុំ ។ |
| ព្រៃវែង | មាន១៦៥សកម្មភាព ៩៨មិនបានអនុវត្ត មានរួមបញ្ចូលប្រហែល៨០សកម្មភាពក្នុង/ឃុំ ដែលបានដោយអង្គការPRASAC មុនពេលបញ្ចប់ ។ មានតែសកម្មភាពធារាសាស្ត្រនៃមូលនិធិវិនិយោគខេត្ត តែមួយគត់ដែល បានអនុវត្តតាមរយ:PDWRM ។ | មាន៦TAs ។ មាន១មិនបានអនុវត្តន៍ ការផ្សព្វផ្សាយ ជំងឺអ៊ីស៍/ហ៊ីវ មកពីNGOs ។ |
| បន្ទាយមានជ័យ | មាន៧៥TAs. ១២មិនបានអនុវត្ត: មានគំរោង PDWRM ដែលមិនបានអនុវត្ត ហើយនឹងគំរោង PDE ដែលបានប្តូរទៅស្រុក ផ្សេងទៀត ។ | មាន៧TAs ។ មាន ១ មិនបាន អនុវត្ត ដោយសារតែ NGOs បាន ចេញពីតំបន់នេះ ។ |
| កំពង់ឆ្នាំង | | មាន១០ TAs ។ាន១មិនបានអនុវត្តន៍ NGOs ។ |

មានសកម្មភាពនៃមូលនិធិវិនិយោគខេត្តដែលមិនបានអនុវត្តមានតែ មន្ទីរសុខាភិបាល និង មន្ទីររៀបចំដែនដី និងនគរូបនីយកម្មនៅក្នុងខេត្តពោធិសាត់ ហើយនឹងមន្ទីរអប់រំ និងគ្រប់គ្រងធនធានទឹកនៅ ក្នុងខេត្តបន្ទាយមានជ័យ ។ ក្នុងករណីមន្ទីររៀបចំដែនដីនៅក្នុងខេត្តពោធិសាត់គួរឱ្យចាប់អារម្មណ៍ ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តបានចុះហត្ថលេខាយល់ព្រមជាមួយមេឃុំត្នោតជុំ ដើម្បីផ្តល់សេវាបីដូចខាងក្រោម:

១. ប ណ្តុះបណ្តាលគោលនយោបាយកាត់បន្ថភាពក្រីក្រ នៃក្រុមប្រឹក្សាកំណែទំរង់ដីធ្លី

[៣៩] ចំពោះគ្រប់ខេត្តទាំងអស់លើកលែងតែការសិក្សាករណីឃុំដែលមានទីតាំងនៅក្នុងស្រុកក្នុងខេត្តពោធិ៍សាត់ ។

២. បណ្ដុះបណ្ដាលច្បាប់ដីធ្លី ឆ្នាំ២០០៤

៣. ចេញលិខិតបញ្ជាក់កម្មសិទ្ធដីធ្លីចំនួន ១០

សកម្មភាពទី១ និង២ មានដាក់បញ្ចូលក្នុងអនុកិច្ចសន្យារបស់មន្ទីររៀបចំដែនដី ជាមួយ គអជខ/គប្រខេត្តពោធិសាត់។ សកម្មភាពទាំងនេះគាំទ្រដោយមូលនិធិវិនិយោគខេត្តនៃកម្មវិធីសិលា ហើយបានអនុវត្តចប់តាមផែនការ។ សកម្មភាពទីបីមិនទាន់បានអនុវត្តនៅឡើយ ហើយក្រុមប្រឹក្សាឃុំមិនយល់ថាហេតុអ្វី។ ពេលដែលយើងជួបជាមួយមន្ត្រីរៀបចំដែនដីខេត្ត គាត់បានពន្យល់ថា មូលនិធិវិនិយោគខេត្តមិនបានគាំទ្រដល់ការចេញសំបុត្រកម្មសិទ្ធដីធ្លីដល់ប្រជាជននោះទេ សកម្មភាពនេះអនុវត្តទៅបានលុះត្រាតែអ្នកភូមិមានព្រមចំណាយ ចំពោះការធ្វើសំបុត្រកម្មសិទ្ធដីធ្លីនោះ។

មានដំណោះស្រាយពីរដែលបានកើតឡើងមកពីបញ្ហានេះ:

១. កិច្ចសន្យាផ្ដល់លទ្ធផលជាក់លាក់ គួរចុះហត្ថលេខាតែក្នុងករណីមានមូលនិធិច្បាស់លាស់អនុវត្តន៍។

២. មន្ទីររៀបចំដែនដីនគរូបនីយកម្មបានប្រើប្រាស់ DIW ក្នុងការផ្សព្វផ្សាយសេវា ដែលខ្លួនអាចផ្ដល់ឱ្យប្រជាជនបាន។ នេះបង្ហាញឱ្យឃើញនូវសក្ដានុពលសមស្របនៃការធ្វើសិក្ខាសាលាសមាហរណកម្ម ផែនការថ្នាក់ស្រុក តែត្រូវបង្ការកុំឱ្យមានការភន្ដ័ច្រឡំជាមួយនឹង កិច្ចសន្យាសំរាប់សកម្មភាព និងលទ្ធផលជាក់លាក់។

## ការពិភាក្សា

ជាទូទៅ ដោយយោងទៅរកការតាមដានលើកិច្ចសន្យាបណ្ដោះអាសន្ន មូលនិធិវិនិយោគខេត្ត ទទួលបានការប្រព្រឹត្តិយ៉ាងប្រសើរ។ មានកិច្ចព្រមព្រៀងមួយចំនួនតូចប៉ុណ្ណោះ ដែលបានធ្វើដោយផ្អែកលើមូលនិធិវិនិយោគខេត្ត ហើយមិនត្រូវបានអនុវត្តន៍។ ដូច្នេះ ការពិភាក្សាខាងក្រោមនេះ ទាក់ទងច្រើនអ្វីដែលក្រុមបានសិក្សាអំពី បទពិសោធន៍ និងតួនាទីដែលមេឃុំ បានចូលរួមក្នុងសមាហរណកម្មផែនការថ្នាក់ស្រុក។

សមាហរណកម្មផែនការថ្នាក់ស្រុកមានតួនាទីពីរទូលំទូលាយ:

១. ដើម្បីវាយតំលៃលើការអនុវត្តនៃអ្នកផ្ដល់សេវា លើអ្វីដែលពួកគេបានសន្យាផ្ដល់ក្នុងឆ្នាំមុន។

២. ដើម្បីធ្វើកិច្ចព្រមព្រៀងរវាងអ្នកផ្ដល់សេវា និងក្រុមប្រឹក្សាឃុំ លើសេវាដែលនឹងត្រូវផ្ដល់ទៅឆ្នាំក្រោយ។

## ការវាយតំលៃលើការអនុវត្ត/មិនអនុវត្តនៅឆ្នាំមុន

មានបញ្ហាមួយបានកើតឡើងនៅក្នុងចំណោមខេត្តនានា ជាពិសេសបាត់ដំបង ពោធិ៍សាត់ និងព្រៃវែង ដែលជួនកាលមានភាពខុសគ្នារវាង ពត៌មានដែលមេឃុំទទួលបានពីអ្វីដែលអនុវត្តរួច ទៅនឹងអ្វីដែលមន្ទីរជំនាញរាយការណ៍ថាបានអនុវត្ត។ តាមដែលយើងអាចវិនិច្ឆ័យបាន បញ្ហានេះកើតឡើងដោយសារសកម្មភាពត្រូវបានអនុវត្តរួច តែមេឃុំមិនបានដឹង ឬបានដឹងហើយតែភ្លេច។ ការមិនបានដឹងអាចកើនឡើង ដោយសារតែ មន្ត្រីខេត្តចុះទៅអនុវត្តន៍ការងារក្នុងឃុំដោយមិនបានជូនដំណឹងទៅក្រុមប្រឹក្សាឃុំ ឬបានជូនដំណឹងដល់នរណាម្នាក់ ក្នុងក្រុមប្រឹក្សាឃុំ (ប្រហែលជាស្មៀនឃុំ) តែគាត់មិនបានប្រាប់មេឃុំ។

ចាំបាច់ត្រូវតែរកវិធីណាមួយ ដើម្បីអោយក្រុមប្រឹក្សាឃុំ អាចគ្រប់គ្រងបានល្អលើពត៌មានដែលទាក់ទង ទៅនឹងការអនុវត្តគំរោងនានានៅក្នុងមូលដ្ឋានរបស់ខ្លួន។ មានវិធីមួយដែលអាចជួយសំរួលបញ្ហានេះបាន គឺត្រូវបន្ថែមកូឡោនមួយ នៅក្នុងទំរង់កិច្ចសន្យាបណ្តោះអាសន្ន សំរាប់តំណាងអ្នកផ្តល់សេវាបំពេញនៅពេលគំរោងត្រូវបានបញ្ចប់ ឬត្រូវលប់ចោល។

មានការមិនស្រុះស្រួលគ្នាផ្សេងទៀត នៅក្នុងការសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកក្នុងឆ្នាំបន្ទាប់។ នៅខេត្តបន្ទាយមានជ័យ ប្រធានឃុំបានរអ៊ូរទាំថា ពួកគាត់មិនដឹងហេតុអ្វីមន្ទីរធនធានទឹក មិនបានបំពេញកិច្ចសន្យាបណ្តោះអាសន្នដែលមន្ទីរបានធ្វើ ហើយថាតំណាងមន្ទីរដែលទៅចូលរួម DIW ក៏មិនអាចឆ្លើយបាន។ ផ្ទុយទៅវិញមន្ត្រីខេត្តបានថ្លែងថា ពួកគាត់បានចូលរួមហើយបានបកស្រាយយ៉ាងច្បាស់លាស់នូវស្ថានភាពនោះ តែក្រុមប្រឹក្សាមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីស្វែងយល់លើបញ្ហានេះ។ មានស្ថានភាពដូចគ្នានៅក្នុងខេត្តព្រៃវែង ត្រូវបានលើកឡើងដោយអនុប្រធានមន្ទីរផែនការ។ គាត់បាននិយាយថា នៅពេលធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក មេឃុំទាំងអស់បានឡើងធ្វើរបាយការណ៍ម្តងម្នាក់ លើគំរោងដែលមិនបានអនុវត្ត ហើយនៅពេលពួកគាត់បានបញ្ចប់ ក៏ដល់ពេលអ្នកផ្តល់សេវាឡើងមកបកស្រាយពន្យល់ម្តង។ អនុប្រធានមន្ទីរក៏មានការសង្ស័យ នៅពេលដែលអ្នកផ្តល់សេវា ឡើងបញ្ជាក់ក្នុងអង្គប្រជុំ ប្រធានឃុំអាចមិនយល់ថាជាការឡើងផ្តល់ចំលើយ ដោយត្រង់ទៅនឹងសំនួររបស់គាត់ទេ។ បញ្ហាយល់ច្រឡំនិងមិនស្រុះស្រួលនេះ អាចកាត់បន្ថយបានតាមរយៈការតំរូវឱ្យបណ្តាមន្ទីរខេត្ត ត្រូវទៅកាន់សាលាឃុំ ហើយសរសេរបន្ថែមលើកិច្ចសន្យាបណ្តោះអាសន្ន នូវគំរោងដែលត្រូវបានលប់ចោល។

លទ្ធផលដែលយើងរកឃើញនេះ ផ្អែកលើការពិភាក្សាជាមួយអភិបាលស្រុក និងមេឃុំដែលប្រាប់យើងអំពីការធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក កាលពី៨ខែមុននេះ។ វាមានការផ្ទុយគ្នាធំ១ខ្លះ ជាមួយនឹងរបកគំហើញរបស់មន្ត្រីថ្នាក់ជាតិមួយចំនួន និងទីប្រឹក្សាដែលបានសង្កេតការដោយផ្ទាល់ក្នុងពេលធ្វើ សមាហរណកម្ម ផែនការថ្នាក់ស្រុក។

អ្នកសង្កេតការណ៍បានឱ្យយោបល់ថា វាមិនមែនជាបញ្ហាប្លែកទេ ដែលមេឃុំតែងតែតវ៉ាជាមួយនឹងអ្នកផ្តល់សេវា យ៉ាងផុសផុលនិងជក់ចិត្ត ពីសកម្មភាពដែលមានបញ្ចូលទៅក្នុងកិច្ចសន្យាបណ្តោះអាសន្ន ហើយមិនបានអនុវត្ត។ ផ្ទុយទៅវិញមានមេឃុំជាច្រើនទៀត ដែលយើងបានជួបបានបង្ហាញការភ្ញាក់ផ្អើល ដែលថាពួកគាត់មានតួនាទី ឬការទទួលខុសត្រូវ ទាមទារការពន្យល់ពីបណ្តាមន្ទីរជំនាញ។

## កិច្ចព្រមព្រៀង និងផែនការ សំរាប់អនាគត

នៅក្នុងការបរិយាយរបស់យើង មានភាពច្បាស់លាស់គ្រប់គ្រាន់ ដែលថាអ្នកផ្តល់សេវា បានសំរេចទុករួចជាមុន ហើយនូវសេវាដែលត្រូវផ្តល់ភាគច្រើន មុនពេលធ្វើសមារណហកម្មផែនការថ្នាក់ស្រុក។ មេឃុំមិនយល់ថាខ្លួនមានឱកាស (ដោយបានចូលរួមក្នុងអង្គប្រជុំ) ក្នុងការអូសទាញអ្នកទាំងនោះឱ្យប្តូរចិត្តទេ។ អភិបាលស្រុកក៏គិតដូច្នេះដែរ។ ពួកគាត់ឃើញថាមានតំបន់ខ្លះ ត្រូវបានគេយកចិត្តទុកដាក់ជាពិសេស និងតំបន់ខ្លះទៀតត្រូវគេមិនអើពើ។ ប៉ុន្តែពួកគាត់ មិនមានឱកាសក្នុងការព្យាយាមដោះស្រាយបញ្ហានេះទេ ដោយសារតែការសំរេចចិត្តបានធ្វើរួចទៅហើយ។

**អនុសាសន៍លើការតាមដានកិច្ចព្រមព្រៀងបណ្ដោះអាសន្ន**

១. អ្នកផ្ដល់សេវាចាំបាច់ត្រូវតែផ្ដល់ពត៌មានជាលាយលក្ខណ៍អក្សរទៅដល់មេឃុំ-ចៅសង្កាត់ ពីការបានអនុវត្តចប់ ឬនិរាករណ៍កិច្ចព្រមព្រៀង។ កិច្ចព្រមព្រៀងបណ្ដោះអាសន្នគួរមានកូឡោនបន្ថែម សំរាប់អ្នកផ្ដល់សេវា បំពេញពត៌មានថែមនៅពេលក្រោយ។

២. គួរបញ្ជាក់ឱ្យមេឃុំ-ចៅសង្កាត់ យល់ច្បាស់ថា សិក្ខាសាលាសមាហរណកម្មផែនការស្រុក គឺជាឱកាស សំរាប់ពួកគាត់ទាក់ទាញអ្នកផ្ដល់សេវានានាឱ្យទទួលខុសត្រូវ ហើយបញ្ច្រាបទៅក្នុងការគិតគូររបស់ពួកគេ នូវគំនិតសំរាប់រយៈពេលវែង និងការសំរេចចិត្តផ្ដល់គំរោង (មិនគួរសន្និតថា មេឃុំ-ចៅសង្កាត់ សុទ្ធតែ យល់ដឹងប្រការទាំងនេះរួចហើយនោះទេ ព្រោះមានមេឃុំមួយចំនួនគឺ មិនដឹងទាល់តែសោះ)។

## ៥. ចំនុចបន្ថែមទៅលើមូលនិធិវិនិយោគខេត្ត និងមូលនិធិឃុំ-សង្កាត់[៣៦]

*ប្រមើលមើល និងផ្ដល់អនុសាសន៍លើវិធានការណ៍ ដែលគួរធ្វើដើម្បីជំរុញ ការបំពេញឱ្យគ្នារវាង មូលនិធិ វិនិយោគខេត្ត និងមូលនិធិឃុំ-សង្កាត់ឱ្យកាន់ប្រសើរ។*

**ការផ្ដល់មូលនិធិឃុំ-សង្កាត់លើហេដ្ឋារចនាសម្ព័ន្ធ**

នៅដំណាក់កាលដំបូងនៃដំណើរការកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា មានការផ្ដោតខ្លាំងទៅលើ ការកសាងសមត្ថភាពតាមរយៈការផ្ដល់សេវាកម្ម និងអភិបាលកិច្ចល្អ។ នៅមិនទាន់មានចក្ខុវិស័យច្បាស់លាស់នៅ ឡើយ អំពីតួនាទីនិងអំណាចអ្វីខ្លះដែលនឹងត្រូវផ្ទេរ ហើយផ្ទេរឱ្យដល់ថ្នាក់ណា។ ដើម្បីអាចកសាងបាននូវលទ្ធផល ជាក់ស្ដែង និងផ្ដោតទៅលើការិតជំនាញដ៏តិចតួចរបស់ខ្លួន ថ្នាក់ឃុំបានប្រើមូលនិធិដែលទទួលបានតាមរយៈមូលនិធិ ឃុំ-សង្កាត់ ភាគច្រើនក្នុងការអនុវត្តគំរោងហេដ្ឋារចនាសម្ព័ន្ធ។ ទស្សនៈនេះ ហាក់ចុះសំរុងគ្នាល្អទៅនឹងនិន្នាការ អភិវឌ្ឍន៍ដោយមានការចូលរួម តាមរយៈផែនការឃុំ-សង្កាត់។ ជាទូទៅជាគំនិតរបស់អ្នកភូមិកម្ពុជាភាគច្រើន សំរាប់ កិច្ចអភិវឌ្ឍន៍គឺ ការស្ថាបនាជារូបវន្ត ដូច្នេះហើយការយកមូលនិធិឃុំ-សង្កាត់ ផ្ដោតលើហេដ្ឋារចនាសម្ព័ន្ធ ជាចំលើយដ៏ សមស្រប ទៅនឹងប្រភេទគំរោង ដែលអ្នកភូមិ តែងតែចង់បាន។

សេចក្ដីណែនាំរបស់ក្រសួងផែនការលេខ៦៨០ សំរាប់រៀបចំដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក មិន បានបញ្ជាក់ទេថាមូលនិធិវិនិយោគខេត្ត អាចប្រើប្រាស់សំរាប់គំរោងប្រភេទណាក៏បាន។ ប៉ុន្តែ ការពិភាក្សាជាមួយ ទីប្រឹក្សាPLG ជាពិសេសប្រធានទីប្រឹក្សាតាមខេត្ត (SPPA) បានបកស្រាយយ៉ាងច្បាស់ថា មូលនិធិវិនិយោគខេត្ត ត្រូវបានរំពឹងទុកសំរាប់ការកសាងសមត្ថភាព និងការផ្សព្វផ្សាយនានា។ ជាការសន្និតថែមទៀតថា ការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានានៅតាមឃុំ-សង្កាត់ នឹងទាមទារឱ្យមាននូវគំរោង "ផ្នែកទន់" ដើម្បីបំពេញបន្ថែម និង ធានាប្រសិទ្ធិផលបានល្អ។ គំរោងទាំងប្រាំដែលយើងចុះទៅសិក្សា ហាក់មិនឆ្លើយតបទៅនឹងទស្សនៈនេះទេ មិនតែ ប៉ុណ្ណោះ ក្នុងចំណោមនោះមានគំរោងពីរជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ប៉ុន្តែ យើងក៏បានឃើញមានករណីដែលមូលនិធិ

[៣៦] កិច្ចដំណោះស្រាយនៃទំនាក់ទំនងរវាងមូលនិធិវិនិយោគខេត្ត និងកម្មវិធីវិនិយោគឃុំ ផែនការឃុំ និងអាទិភាពបានពិភាក្សាជាទូទៅនៅក្នុងផ្នែកទី ២ ខាងលើស្ដីពី ការវាយតំលៃគំរោង។

វិនិយោគខេត្តត្រូវបានប្រើចំតាមគំនិតនេះដែរ។ ដូចជានៅខេត្តពោធិ៍សាត់ មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរកិច្ចការសាសនា បានផ្តួចផ្តើមគំនិត ក្នុងការពង្រឹងសមត្ថភាពសហគមន៍លើការគ្រប់គ្រង និងថែទាំផ្លូវលំជនបទ។

នៅពេលពិភាក្សាមេឃុំបានលើឡើងនូវចំនុចមួយ ដែលអាចជាការបំពេញឱ្យគ្នារវាង មូលនិធិទាំងពីរនេះ។ មូលនិធិឃុំ-សង្កាត់ នាពេលបច្ចុប្បន្នមានចំនួនតិចតួចណាស់ មិនអាចយកទៅកសាងធ្វើអ្វីមួយឱ្យមានផលប្រយោជន៍ធំដុំឡើយ។ មូលហេតុនេះបានបើកចំហរលទ្ធភាពនៃការប្រើប្រាស់មូលនិធិវិនិយោគខេត្តសំរាប់គំរោង ហេដ្ឋារចនាសម្ព័ន្ធធំៗ ទោះបីជាមធ្យោបាយនេះ នឹងធ្វើឱ្យឃុំភាគច្រើន មិនបានទទួលអ្វីសោះពីមូលនិធិវិនិយោគខេត្ត ក្នុងរយៈជាច្រើនឆ្នាំក៏ដោយ។ ទស្សនៈនេះ មានលក្ខណៈត្រឹមត្រូវ និងគួរឱ្យយល់បាន។ បើសិនថ្នាក់ខេត្តត្រូវបានសង្ឃឹមថាជាអ្នកបំពេញបង្គ្រប់ និងផ្តល់បន្ថែម ដល់ថ្នាក់មូលដ្ឋាន នេះលក្ខខណ្ឌដំបូងគឺ នៅថ្នាក់មូលដ្ឋានត្រូវមានធនធានល្អ និងគ្រប់គ្រាន់ដើម្បីទទួលរ៉ាប់រងឱ្យ មានប្រសិទ្ធភាព។

## នរណាជាអ្នកសំរេច ហើយផ្អែកលើមូលដ្ឋានអ្វី?

ការអះអាងឱ្យប្រើប្រាស់មូលនិធិវិនិយោគខេត្តសំរាប់តែ "ផ្នែកទន់" ដូចជាកសាងសមត្ថភាព និងអប់រំ/ផ្សព្វផ្សាយ ដើម្បីបំពេញបន្ថែមដល់មូលនិធិឃុំ-សង្កាត់ (ក៏ដូចជាប្រភពផ្សេងទៀត ទាំងជំនួយការអភិវឌ្ឍន៍ផ្លូវការ និងអំណោយឯកជននានា ដែលផ្តោតអាទិភាពលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តផងដែរ) អាចត្រូវតែចំពោះវិស័យខ្លះប៉ុណ្ណោះ។ ប៉ុន្តែវាចោទជាបញ្ហាផងដែរអំពីសកម្មភាពជាអាទិភាពនានា ដែលគួរកំនត់តាមរយៈគោលនយោបាយក្រសួង។ ដូចជាក្រសួងអភិវឌ្ឍន៍ជនបទ គួរមានជំនាញបច្ចេកទេសក្នុងការផ្តល់យោបល់ដល់ខេត្ត ថាតើការបណ្តុះបណ្តាល និងរៀបចំសហគមន៍ប៉ុន្មាន ដើម្បីធានាឱ្យអណ្តូងនិងបង្គន់ អាចផ្តល់ប្រយោជន៍សុខភាព និងអនាម័យជាអតិបរិមា។ តួនាទីរបស់ STFSនិងPLG ក្នុងទិដ្ឋភាពនេះ មិនមែនជំរុញឬបញ្ចៀសបណ្តាមន្ទីរជំនាញខេត្ត ពីគំរោងហេដ្ឋានរចនាសម្ព័ន្ធទេ តែគួរធានាឱ្យមានការពាក់ពន្ធ័រវាងមន្ទីរជំនាញខេត្ត និងក្រសួងថ្នាក់ជាតិ ដើម្បីឱ្យបទពិសោធន៍ថ្នាក់ខេត្តបានដឹងដល់ថ្នាក់គោលនយោបាយក្រសួង ហើយគោលនយោបាយក្រសួងនៅថ្នាក់ជាតិ នៅពេលនោះបានជ្រួតជ្រាបក្នុង ការសំរេចចិត្តនានារបស់បណ្តាមន្ទីរ ជំនាញថ្នាក់ខេត្ត។

ក្នុងករណីដែលកម្មវិធីសិលាអាចមានសិទ្ធធ្វើអន្តរាគមន៍ស្របច្បាប់ជាងមុន បញ្ហាមួយផ្សេងគឺ តើមូលនិធិវិនិយោគខេត្ត ត្រូវផ្តល់ឱ្យតាមមន្ទីរវិស័យក្នុងកំរិតណា សំរាប់ឆ្លើយតបទៅនឹងតំរូវការដែលលេចចេញពី សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក។ ក្នុងបរិបទនេះ ដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក អាចជួយឱ្យមន្ទីរបានឆ្លើយតប និងជួយបំពេញបន្ថែមលើគំរោង ដែលជាអាទិភាពអភិវឌ្ឍន៍ឃុំ។ ដូចគ្នាដែរ ដំណើរការនេះបានជួយឱ្យឃុំចេះធ្វើទំនាក់ទំនង និងផ្តល់គំនិតផ្សេងៗ ជាមួយមន្ទីរជំនាញខេត្ត។ ក្នុងពេលបច្ចុប្បន្ន ការអនុវត្តន៍បែបនេះត្រូវបានធ្វើជាមួយនឹងមូលនិធិយ៉ាងតិចតួចបំផុត ដោយសារបណ្តាមន្ទីរជំនាញមិនសូវបានទទួលថវិកាវិនិយោគ ដែលអាចដឹងចំនួនមុនច្បាស់លាស់ទេ ទាំងពីថវិកាជាតិ ឬម្ចាស់ជំនួយផ្សេងទៀត។ ដូច្នេះហើយមន្ទីរមិនអាចមានអ្វី យកទៅឆ្លើយតបនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ក្រៅពីមូលនិធិវិនិយោគខេត្តនេះឡើយ។

ដូច្នេះ ក្នុងស្ថានភាពនេះ STFS គួរដើរតួយ៉ាងស្របច្បាប់ ក្នុងការធ្វើសេចក្តីណែនាំដល់បណ្តាខេត្ត-ក្រុង សំដៅធានាឱ្យមានការវិភាជន៍ថវិកាដល់មន្ទីរភាគច្រើន និងគ្រប់ស្រុកក្នុងខេត្ត ដើម្បីឱ្យដំណើរការសមាហរណកម្ម នៅរក្សាបាននូវស្ថានភាពជាយន្តការដ៏មានសារសំខាន់មួយ។ មានការផ្លោះប្តូររវាងគោលការណ៍ពីរ នៅក្នុងកម្មវិធីសិលាៈ មួយគឺ អនុញ្ញាតឱ្យរដ្ឋអំណាចវិសហមជ្ឈការថ្នាក់ខេត្ត ប្រើឥន្ទានុសិទ្ធសំរេចនូវយុទ្ធសាស្ត្រដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រក្នុងខេត្ត (ដូចជាការប្រមូលផ្តុំធនធានចូលក្នុងសកម្មភាពតែមួយឬពីរ) ទីពីរគឺប្រើប្រាស់ថវិកាវិនិយោគចំនួនតិច ដើម្បីកសាងសមត្ថភាពសំរាប់សំរបសំរួល និងសមាហរណផែនការនិងថវិកាខេត្ត ជាមួយផែនការឃុំ។

យោងតាមសំណូមពរ ឱ្យគ្រប់មន្ទីរជំនាញដែលពាក់ពន្ធ័នឹងការចូលរួមកាត់បន្ថយភាពក្រីក្រ គួរបានទទួលការវិភាជន៍ថវិកាពីមូលនិធិវិនិយោគខេត្ត និងតាមសំណើឱ្យគ្រប់ស្រុកនៅក្នុងខេត្ត គួរតែបានទទួលគំរោងមួយចំនួនដែលផ្តល់ដោយខេត្ត (រាប់ទាំងមូលនិធិវិនិយោគខេត្តរបស់PLG និងមូលនិធិUNICEF និងIFAD ដែលបានផ្តល់តាមរយៈដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក) នោះSTFS ត្រូវធានាឱ្យមានមូលនិធិ សំរាប់គាំទ្រការធ្វើសមាហរណកម្មផែនការដ៏មានសារប្រយោជន៍នេះ ធានាឱ្យគ្រប់មន្ទីរជំនាញទាំងអស់មានទំលាប់ឆ្លើយតបនិងពាក់ពន្ធ័ការងារជាមួយក្រុមប្រឹក្សាឃុំ ហើយនិងធានាឱ្យ គ.អ.ជ.ខ/គប្រ បន្តការពិចារណានិងផ្តោតធនធានរបស់ខ្លួនទៅលើគំរោងធំៗខ្លះ។ មិនមែនជាប្រការគួរឱ្យចង់បាន និងងាយធ្វើទេ ដែលទាមទារឱ្យបណ្តាមន្ទីរទាំងអស់ត្រូវផ្តល់គំរោងដល់គ្រប់ស្រុកនោះ ព្រោះវានឹងធ្វើឱ្យថវិកាសំរាប់គំរោងនិមួយៗកាន់តែតូច និងបង្អាក់មិនឱ្យ គប្រ/គ.អ.ជ.ខ អាចធ្វើការសំរេចលើការវិនិយោគ ធំៗនិងមានសារសំខាន់បាន។ ចំនុចគន្លឹះនោះគឺគ្រាន់តែការពារកុំឱ្យមានការវិភាជន៍មូលនិធិសំរាប់តែមន្ទីរ៣-៤ ឬស្រុកតែ៣-៤ កើតឡើង ព្រោះវានឹងធ្វើឱ្យឃុំ ស្រុក និងមន្ទីរភាគច្រើនមិនបានទទួលបទពិសោធន៍និងសមត្ថភាព ក្នុងការសំរបសំរួលនិងគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ហើយខ្វះការត្រៀមលក្ខណៈសំរាប់ទទួលការផ្តល់ហិរញ្ញប្បទានកំរិតខ្ពស់ ដែលរំពឹងថានឹងត្រូវផ្តល់តាមប្រព័ន្ធវិសហមជ្ឈការនាអនាគត។

**ឃុំទទួលយកការទទួលខុសត្រូវ**

សមិទ្ធផលដំបូងដែលសំរេចបានអំពីកំណែទំរង់វិមជ្ឈការ និងមូលនិធិឃុំ-សង្កាត់ គឺការកើតឡើងនូវករណីដែល មន្ត្រីមូលដ្ឋានមួយចំនួន ចាប់យកការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ដោយការតាមពិនិត្យនិងធានាគុណភាពនៃសេវាដែលត្រូវបានផ្តល់ ហើយមានជោគជ័យក្នុងការទទួលបានសេវាដែលមានគុណភាពជាង និងមានប្រសិទ្ធិភាពជាង។ សមិទ្ធិផលបែបនេះ ពុំមែនកើតឡើងនៅគ្រប់ទីកន្លែងនោះទេ វារីកចំរើនយឺតៗនិងមិនប្រាកដប្រជា។ ជាការពិតដែល ករណីបែបនេះ បានកើតមាននៅទីកន្លែងមួយចំនួន ដែលពុំធ្លាប់មានពីមុនមក ហើយអាចជាមូលដ្ឋានគ្រឹះសំរាប់ការបង្កើនថែមទៀតនូវ រដ្ឋបាលសាធារណៈមួយក្នុងប្រទេសកម្ពុជា ដែលមានគណនេយ្យភាព និងផ្តោតលើការផ្តល់សេវា។

សមាសភាគសំខាន់នៃការ បំពេញគ្នារវាង CSF និងPIF អាចជាការព្យាយាមគាំពារឱ្យមានឥរិយាបទបែបនេះ កាន់តែច្រើនក្នុងចំណោមក្រុមប្រឹក្សាឃុំ ចំពោះការវិនិយោគ PIF ដូចដែលពួកគាត់បានអនុវត្តចំពោះ ការ

វិនិយោគ CSF។ ពោលគឺ ត្រូវបង្កើតកាលានុវត្តភាពអោយបានច្រើនសំរាប់ក្រុមប្រឹក្សាឃុំ ដើម្បីអនុវត្តតួនាទីក្នុងការជួយធានាគុណភាព និង ប្រសិទ្ធភាពនៃសេវាដែលខេត្តផ្តល់អោយ ។

គំរូទំរង់កិច្ចព្រមព្រៀងបណ្តោះអាសន្នដែលមាននៅក្នុង សេចក្តីណែនាំរបស់ក្រសួងផែនការលេខ៦៨០ មានតារាងបញ្ជរមួយដែលបង្ហាញតម្លៃប៉ាន់ស្មាននៃសកម្មភាពនីមួយៗ។ មានតែខេត្តពោធិ៍សាត់មួយប៉ុណ្ណោះ ដែលបានព្យាយាមបំពេញពត៌មាននេះ។ នៅក្នុងខេត្តផ្សេងទៀត គំរូទំរង់មួយផ្សេងត្រូវបានយកមកប្រើជំនួសដោយ ពុំមានដាក់បញ្ចូលតម្លៃឡើយ។ ពត៌មានអំពីតម្លៃអាចជាឧបករណ៍ដ៏មានប្រយោជន៍មួយសំរាប់ក្រុមប្រឹក្សាឃុំ ដើម្បីធ្វើការវិនិច្ឆ័យអំពីគុណភាព និង ប្រសិទ្ធភាពនៃសេវាកម្ម។ នៅឃុំបារាយណ៍ ក្នុងខេត្តព្រៃវែងបានទទួលការគាំទ្រសំរាប់ការសាងសង់ប្រព័ន្ធធារាសាស្ត្រ ពី សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ពីគំរោងប្រាសាក់ និងពីមូលនិធិអភិវឌ្ឍន៍ខេត្ត (ពីរលើក)។ ក្នុងករណីទាំងនេះ មេឃុំ ពុំបានដឹងអំពីតម្លៃរបស់ប្រឡាយឡើយ (រហូតដល់ពេលដែលក្រុមស្រាវជ្រាវយើងមកដល់ ហើយប្រាប់គាត់អំពីតម្លៃប្រឡាយដែលហិរញ្ញប្បទានដោយ PIF)។ យើងបានសួរនាំមេឃុំ ថាតើការដឹងពីតម្លៃរបស់គំរោងទាំង៤ មានសារៈសំខាន់ និងគួរឱ្យចាប់អារម្មណ៍ចំពោះគាត់ឬទេអំពី ដើម្បីអាចធ្វើការប្រៀបធៀបគ្នា។ គាត់បានឆ្លើយ" បាទ" និងបានលើកបញ្ហានេះដោយខ្លួនគាត់ផ្ទាល់នៅក្នុងអង្គប្រជុំមួយជាមួយ មេឃុំទាំងអស់ និងចៅហ្វាយស្រុកនៅក្នុងការិយាល័យស្រុកនៅថ្ងៃរសៀលនោះ។ ម្យ៉ាងវិញទៀត ពត៌មានស្តីពីតម្លៃដែលត្រូវបានផ្តល់នៅក្នុងខេត្តពោធិសាត់ ក្រុមប្រឹក្សាឃុំពុំបានយកចិត្តទុកដាក់ខ្លាំងក្លាទេ។ ចំណុចសំខាន់ពុំមែនគ្រាន់តែផ្តល់ពត៌មានដល់ឃុំទេ ប៉ុន្តែក៏ធានាថាពួកគាត់យល់ថាពួកគាត់មាន សិទ្ធិ និងមានការទទួលខុសត្រូវចំពោះការប្រើប្រាស់ PIF។

បញ្ហាដូចគ្នានេះដែរ ពាក់ពន្ធ័ដំណើរការដេញថ្លៃ។ ដំណើរការដេញថ្លៃដែលមន្ទីរខេត្តបានប្រើប្រាស់ PIF សំរាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធគឺ ប្រហាក់ប្រហែលនឹងដំណើរការដែលបានប្រើដោយក្រុមប្រឹក្សាឃុំនៅពេលជ្រើសរើស អ្នកទទួលការសំរាប់គំរោង CSF របស់ខ្លួនផ្ទាល់ដែរ។ នៅក្នុងឃុំបារាយណ៍ មេឃុំពុំបានដឹងថាមានការដេញថ្លៃ និងពុំបានចូលរួមទេ។ តាមការសិក្សានេះ អភិបាលខេត្តបានប្រកាសថាគ្មានសមាជិកក្រុមប្រឹក្សាឃុំណាម្នាក់បានចូលរួម ក្នុងដំណើរការ ដេញថ្លៃនេះទេ ព្រោះពួកគាត់ពុំត្រូវបានអញ្ជើញអោយចូលរួមទេ ប៉ុន្តែនាពេលអនាគត ក្នុងការដេញថ្លៃសំរាប់គំរោង PIF មេឃុំនៃឃុំដែលមានគំរោងអនុវត្ត នឹងត្រូវបានអញ្ជើញអោយចូលរួមក្នុងដំណើរការដេញថ្លៃផងដែរ។

នៅពេលបញ្ចប់នៃការវាយតំលៃគំរោង គួរតែមានតំណាងក្រុមប្រឹក្សាឃុំចូលរួម។ ការបណ្តុះបណ្តាលជាមូលដ្ឋានក្នុងការតាមដាននិងវាយតំលៃ (M&E) ត្រូវបានផ្តល់ចំពោះក្រុមប្រឹក្សាឃុំ (ជាពិសេសជនបង្គោល M&E នៃក្រុមប្រឹក្សាឃុំ) ក្នុងអំឡុងឆ្នាំ២០០៤។ ការងារនេះអាចរំពឹងថាទទួលបានលទ្ធផលខ្លះ ទៅក្នុងការជំរុញតួនាទីរបស់ឃុំចំពោះ PIF។ យោង តាមរបៀបដំណើរការនៃការវាយតំលៃបញ្ចប់គំរោងឆ្នាំ២០០៤ អាចមានជំរើសមួយក្នុងការបញ្ចូលការវាយតម្លៃឯករាជ្យ ដោយក្រុមប្រឹក្សាឃុំ រំពឹគុណភាពនៃគំរោង (ប្រើជាថ្មីម្តងទៀតនូវចំណោត់ថ្នាក់រោយ១ ដូចជា ល្អ/ពេញចិត្ត /មិនពេញចិត្ត ជាមួយនិងការពន្យល់ពីរឬបីឃ្លា)។ ចំណុចនេះពុំមានន័យថា ឃុំគឺជាអ្នកសំរេច

ចុងក្រោយបង្អស់ ក្នុងការវាយតំលៃគំរោងទេ តែ គឺជាមធ្យោបាយមួយ ដើម្បីធានាឱ្យ ក្រុមប្រឹក្សាឃុំខ្លួនឯងផ្ទាល់ និងតំណាងមន្ទីរខេត្ត ទទួលស្គាល់ភាពស្របច្បាប់នៃទស្សនៈរបស់ក្រុមប្រឹក្សាដែលជ្រើសរើសដោយការបោះឆ្នោតនៅមូលដ្ឋាន ។

**អនុសាសន៍ស្ដីពីការពង្រឹងទំនាក់ទំនង CSF-PIF**

១. គ.ជ.ន.ស ពុំគួរស្វះស្វែងជំរុញការបំពេញឱ្យគ្នារវាងការវិនិយោគ CSF និង PIF ហើយក៏ពុំគួរទាមទារអោយ PIF ត្រូវបានប្រើប្រាស់សំរាប់តែគោលបំណងពុំមែនហេដ្ឋារចនាសម្ព័ន្ធនោះទេ។ ជាងនេះទៅទៀត គ.ជ.ន.ស ត្រូវធ្វើការងារ ដើម្បី ធានាថាក្រសួងផ្ដល់ការណែនាំអំពីគោលនយោបាយពាក់ព័ន្ធដល់មន្ទីរខេត្ត។

២. គ្រប់បណ្ដាមន្ទីរខេត្ត ដែលមានសក្ដានុពលក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ គួរទទួលបាន PIF រៀងរាល់ឆ្នាំ (លើកលែងតែមន្ទីរណាដែលបានទទួលហិរញ្ញប្បទានរួចហើយ ដូចជាហិរញ្ញប្បទានពីកម្មវិធី IFAD ឬកម្មវិធីសិទ្ធិកុមាររបស់ UNICEF)។

៣. គ្រប់ស្រុកក្នុងខេត្តទាំងអស់គួរទទួលបានគំរោង PIF ខ្លះរៀងរាល់ឆ្នាំ ក្នុងគោលបំណងដើម្បីធានាអោយឃុំ និងស្រុក ទាំងអស់អភិវឌ្ឍន៍សមត្ថភាពដើម្បីសំរបសំរួល និងចេះលើកឡើងនូវតំរូវការជាមួយមន្ទីរខេត្តនានា ។

៤. ក្រុមប្រឹក្សាឃុំ គួរត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់ថា ខ្លួនមានសិទ្ធិ និងការទទួលខុសត្រូវក្នុងការធានាគុណភាព នៃការវិនិយោគ PIF សំរាប់ផ្នែកផ្សេងទៀត (ឧទា. ពង្រីកថែមនូវតំរិយាបទដែលកំណែទំរង់វិមជ្ឈការ ស្វះស្វែង ដើម្បីជំរុញ ចំពោះការអនុវត្តន៍គំរោងដែលពុំមែនគ្រប់គ្រងដោយឃុំ)។

៥. យន្តការសំរាប់ក្រុមប្រឹក្សាឃុំមានឥទ្ធិពលគ្របដណ្ដប់លើការអនុវត្តន៍ PIF ត្រូវតែពង្រឹងៈ ក្រុមប្រឹក្សាគួរត្រូវបាន អញ្ជើញចូលរួមក្នុងដំណើរការដេញថ្លៃគ្រប់ការងារពាក់ពន្ធ័នឹងPIF តំលៃប៉ាន់ស្មានត្រូវកត់ត្រានៅលើកិច្ចព្រមព្រៀងបណ្ដោះអាសន្នទាំងអស់ ផែនការការងារនិងថវិកាចេញពីអនុកិច្ចសន្យាទាំងអស់របស់ PRDC ExCom ត្រូវបានថត ចលងជូនក្រុមប្រឹក្សាពាក់ពន្ធ័ជាបន្ទាន់ក្រោយពេលចុះហត្ថលេខារួច ក្រុមប្រឹក្សាឃុំត្រូវមានភារកិច្ចច្បាស់លាស់នៅក្នុងការ វាយតំលៃបញ្ចប់គំរោងនានាសំរាប់គំរោង PIF ។

## ៦. ទំនាក់ទំនងការផ្ដោតនៃភាពក្រីក្រ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

*វិភាគនិងផ្ដល់អនុសាសន៍ ទៅលើការពាក់ព័ន្ធប្រកបដោយប្រសិទ្ធិភាព រវាងដំណើការនៃការរៀបចំកម្មវិធីតាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដើម្បីបង្កើនការផ្ដោតលើភាពក្រីក្រ របស់ PIF និងការវិនិយោគផ្សេងៗទៀត។ ការងារនេះនឹងត្រូវបានអនុវត្តដោយសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយនឹង ការរៀបចំយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ កម្មវិធីសីលា។*

**មូលនិធិវិនិយោគខេត្ត (PIF) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ**

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គឺជាឯកសារសំយោគដ៏ល្អបំផុតមួយ។ យុទ្ធសាស្ត្រទាំងនេះគឺជាគំនិតផ្ដួចផ្ដើម របស់ធនាគារពិភពលោកក្នុងគោលបំណងធានាថា រដ្ឋាភិបាលនានាដែលទទួលប្រាក់កំចីពីធនាគាពិភពលោក

ត្រូវតែមានគោលនយោបាយ ការរៀបចំថវិកា និងការចំណាយ ដែលមានយុត្តិកម្មរឹងមាំក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ក្នុងពេលជាមួយគ្នានេះដែរ យុទ្ធសាស្ត្រទាំងអស់នេះមានចរិតលក្ខណៈជាតិ និងមានភាពជាម្ចាស់ដោយថ្នាក់ជាតិផងដែរ។ បទពិសោធន៍នៃឆ្នាំដំបូងៗរបស់កម្មវិធីសីលា និងការដាក់ឱ្យប្រើប្រាស់ នូវមូលនិធិអភិវឌ្ឍន៍មូលដ្ឋាននៅកម្ពុជាបានបង្ហាញថាគំនិតផ្តួចផ្តើមដែលមានលក្ខណៈជាអន្តរជាតិនេះ អាចត្រូវយកមកបំលែងឱ្យមានអត្តសញ្ញាណជាតិបាន។ ទោះជាយ៉ាងណាក្តី ក្នុងដំណាក់ណាលនេះ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជាយើងគឺហាក់ដូចជានៅថ្មីនៅឡើយហើយការសរសេរឯកសារទៀតសោតបានឆ្លុះបញ្ចាំងពីប្រភពឯកសាររបស់ធនាគារពិភពលោកច្រើនជាងគោលនយោបាយនានាដែលបានពិភាក្សាក្នុងរង្វង់អ្នកដឹកនាំកម្ពុជានានា។ ចំនុចដែលខ្សោយរបស់ឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រនៅពេលបច្ចុប្បន្ននេះ គឺថាឯកសារនេះមិនបានដើរតួនាទីជាឯកសារយុទ្ធសាស្ត្រនៅឡើយទេ។ ម្យ៉ាងទៀត ឯកសារនេះ បានបង្ហាញបញ្ជីសកម្មភាពទូទៅពេក ដោយមិនមានចាត់អាទិភាព ហើយក៏មិនបានបង្ហាញក្នុងលក្ខណៈដែលអាចជួយដល់អ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រងឱ្យកំណត់អាទិភាពបាននៅពេលដែលពួកគេធ្វើការសំរេចចិត្តអំពីការ ប្រើប្រាស់ធនធានដែលមានកំរិត។

ដូច្នេះនៅក្នុងដំណាក់កាលនេះ មានការពិបាកថា តើយើងអាចយកយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រមកធ្វើជា បង្អែកក្នុងការពង្រឹងការប្រើប្រាស់មូលនិធិវិនិយោគខេត្ត ឬជួយដល់ការសំរេចចិត្តថ្នាក់ខេត្តដើម្បីផ្តោតលើអ្នកក្រីក្របាន យ៉ាងដូចម្តេច។

ប្រកាសលេខ៦៨០របស់ក្រសួងផែនការ បានបញ្ចូលជាឧបសម្ព័ន្ធនូវតារាងម៉ាទ្រីកសកម្មភាពមួយ ដែលស្រង់ចេញពីឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងត្រូវចាត់ទុកថាជាមូលដ្ឋានសំរាប់ការអនុវត្តន៍នៅថ្នាក់ក្រោម។ ប្រការនេះ បានបើកចំហរ ដល់ថ្នាក់ខេត្តអោយធ្វើការងារ ដោយយោងតាមគោលនយោបាយជាតិយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ប្រសិនបើ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក្លាយជាឧបករណ៍កាន់តែសំខាន់ដែលត្រូវតែធ្វើតាមនោះ មូលនិធិវិនិយោគខេត្តគឺត្រូវបានរៀបចំជាស្រេច អោយឆ្លើយតបទៅនឹងបំរែបំរួលគោលនយោបាយដែលដាក់ចេញនៅថ្នាក់ជាតិ។

ប្រសិនបើយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រត្រូវបានគេកែលំអអោយកាន់តែមានលក្ខណៈជាតិ ចាំបាច់ត្រូវមាន ការពិភាក្សាកាន់តែម៉ត់ចត់ និងទូលំទូលាយ ដោយជនកម្ពុជាដែលមានបទពិសោធន៍ពេញលេញនៅក្នុងការងារកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ភាពជោគជ័យ និងការបរាជ័យរបស់មូលនិធិវិនិយោគខេត្ត អាចជាផ្នែកមួយដ៏មានតំលៃនៃបទពិសោធន៍ទាំងនោះ។ ទោះបីជាយ៉ាងណាក្តី ដូចដែលបានបង្ហាញនូវទស្សីករណ៍ខាងលើរួចមកហើយអគ្គលេខាធិការដ្ឋាន នៃគណកម្មាធិការដឹកនាំការងារនៃកម្មវិធីសីលាមិនគួរព្យាយាម ទទួលខុសត្រូវវាយតំលៃលើការងាររបស់មន្ទីរជំនាញ និងទាញយកមេរៀនពិសោធន៍ពី ការងារនេះដោយខ្លួនឯងផ្ទាល់នោះទេ។ ប្រសិនបើមានការរីកចំរើនខ្លះក្នុងការពង្រឹងអង្គភាពគោលនយោបាយ និងវាយតំលៃនៅក្នុងក្រសួងជំនាញនានា ប្រធានអង្គភាពទាំងនេះគួរតែជាមន្ត្រីបង្គោល ដែលសក្តិសមក្នុងការចូលរួម ពីភាក្សាការងារជាមួយអង្គភាព វាយតំលៃភាពក្រីក្រនៃ

ក្រសួងផែនការ ដែលទទួលខុសត្រូវ លើយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ ការបង្កើតអោយមានគណៈកម្មាធិការអន្តរក្រសួង គឺជារឿងការងាយស្រួលនិង សាមញ្ញ ប៉ុន្តែវាពិតជាលំបាកក្នុងការធ្វើអោយគណៈកម្មាធិការនោះ ដំណើរការបានទៀងទាត់ក្នុងនាទីរបស់សាមីក្រសួង ជាជាងការខ្ចីមន្ត្រីបង្គោលម្នាក់ដែលមានការទាក់ទងតិចតួចក្នុងការដឹកនាំក្រសួង នៅពេលដែលពួកគេត្រឡប់ទៅក្រសួងវិញ។ លេខាធិការដ្ឋាននៃកម្មវិធីសិលា (ដែលធ្លាប់មានបទពិសោធន៍និងបានយល់យ៉ាងច្បាស់លើបញ្ហាទាំងនេះ) គួរតែធ្វើការតាមដាននិងទាក់ទាញរកការគាំទ្រ ដើម្បីធានាអោយមានកិច្ចពិភាក្សាថ្នាក់ជាតិ ជុំវិញយុទ្ធសាស្ត្រជាតិកាត់បន្ថយ ភាពក្រីក្រនិងគោលនយោបាយនានា ដែល ពាក់ពន្ធ័ទៅនឹងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយគុណភាពខ្ពស់ និងចំតាមតួនាទី (ផ្អែកលើបទពិសោធន៍ និងការសិក្សាស្រាវជ្រាវ)។

## ការធ្វើឱ្យមន្ត្រីអាចបំពេញការងារតាមតួនាទីទទួលខុសត្រូវ

ការងាររបស់កម្មវិធីសិលា គឺផ្តោតជាសំខាន់ទៅលើការកាត់បន្ថយភាពក្រីក្រ ដោយពឹងផ្អែកទៅលើសមត្ថភាពរបស់ខ្លួន ដើម្បីជះឥទ្ធិពលទៅលើការរៀបចំវិស័យសាធារណៈមួយ ដែលមានប្រសិទ្ធិភាព និងឆ្លើយតបតាមតំរូវការ។ ពោលគឺ កម្មវិធីសិលាអាចចូលរួមចំណែកផងដែរក្នុងការធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ច និងកែលំអនូវការិយាធិបតេយ្យ ដោយការបែងចែកមុខងារប្រកបដោយវិចារណៈកម្ម ដែលនឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើនប្រសិទ្ធិភាព និងភាពរលូនក្នុងការប្រើប្រាស់ថវិការបស់រដ្ឋាភិបាល ក៏ដូចជាម្ចាស់ជំនួយអន្តរជាតិនានាផងដែរ។

សមិទ្ធិផលដែលប្រកបដោយសក្តានុពលរបស់កម្មវិធីសិលា នឹងត្រូវពឹងផ្អែកទាំងស្រុងទៅលើកំណែទំរង់សេវាមន្ត្រីរាជការស៊ីវិល និងការគ្រប់គ្រងចំណាយសាធារណៈ។ ដូចនេះវាជាប្រការចាំបាច់ ដែលកម្មវិធីសិលា ត្រូវបន្តកៀងគរអោយមានការជួយជំរុញដំណើរការកែទំរង់ទាំងនេះឱ្យវិវឌ្ឍន៏កាន់តែលឿនទៅមុខ។ សក្តានុពលភាពរបស់កម្មវិធីសិលា គឺជា វេទិកាគាំទ្រដល់កំណែទំរង់វិស័យសាធារណៈ ហើយមិនគ្រាន់តែពាក់ព័ន្ធដល់អ្នកដឹកនាំរបស់កម្មវិធីប៉ុណ្ណោះទេ ប៉ុន្តែពាក់ពន្ធ័ ទាំងមន្ត្រីរាជការស៊ីវិលជាច្រើននៅថ្នាក់ខេត្ត (រាប់បញ្ចូលទាំងអភិបាល/អភិបាលរងខេត្តដែលចាត់តាំងដោយនយោបាយ) មន្ត្រីស្រុក និងឃុំ ព្រមទាំងក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលចង់អោយមានការផ្លាស់ប្តូរ។

នៅក្នុងអភិក្រមរបស់កម្មវិធីសិលាមានគោលបំណងធានាឱ្យបានថា កម្មវិធីនេះគឺជាយន្តការមួយដើម្បីឱ្យមន្ត្រីរាជការមានសមត្ថភាព បំពេញការងារទៅតាមអាណត្តិរបស់ខ្លួន ជាជាងការខ្ចីមន្ត្រីក្នុងក្របខ័ណ្ឌរាជការ ឱ្យជួយធ្វើការនៅក្នុងគំរោង។ គេអាចនឹងធ្វើអោយអភិក្រមនេះកាន់តែមានភាពជាក់លាក់បាន ដោយការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធនានារបស់កម្មវិធីសិលា និងការពិនិត្យមើលលើបុគ្គលិក (ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត) ដែលជាមន្ត្រីបង្គោលរបស់កម្មវិធីសិលា ដើម្បីធានាថាមន្ត្រីដែលមានលក្ខណៈសម្បត្តិសមស្របត្រូវបានអោយបំរើការងារ ហើយការធ្វើបែបនេះអាចចាត់ទុកថាជាការធ្វើកំណែទំរង់បណ្តើរៗ។ ដោយប្រធានបទនេះមិនមែនជាកម្មវត្ថុនៃការសិក្សារបស់យើងទេនោះ យើងគ្រាន់តែចាប់អារម្មណ៏ថា រចនាសម្ព័ន្ធរបស់កម្មវិធីសិលាមិនទាន់មានច្រើនទេ ហើយ

ការងាររបស់មន្ត្រីបង្គោលកម្មវិធីសិលា និងក្រុមការងារកម្មវិធីសិលានៅតាមបណ្តាក្រសួងត្រូវបានយកមកពិចារណាយ៉ាងល្អិតល្អន់។ ម៉្យាងវិញទៀត យោងតាមមន្ត្រីបង្គោលរបស់កម្មវិធីសិលានៅតាមបណ្តាមន្ទីរជំនាញខេត្តខ្លះ បានយល់ថាកម្មវិធីសិលាអាចត្រូវគេមើលឃើញថា ជាគំរោងដោយឡែក១ពីគ្នា ហើយត្រូវបានប្រគល់អោយមន្ត្រីម្នាក់ ឬច្រើនការអនុវត្តន៍ ជាជាងយន្តការមួយសំរាប់បង្កលក្ខណៈអោយមន្ទីរជំនាញនៅតាមខេត្តបំពេញនាទីភារកិច្ចប្រកបដោយភាពរលូន ។

## មូលនិធិវិនិយោគខេត្តនិងកំណែទំរង់ការគ្រប់គ្រងចំណាយសាធារណៈ

មន្ត្រីថ្នាក់ជាតិបានធ្វើការបដិសេធទៅលើអត្រានៃការបញ្ចេញសាច់ប្រាក់ ដែលមូលនិធិវិនិយោគខេត្តសំរេចបាន (សូមមើលលក្ខខ័ណ្ឌយោង) ជាទូទៅលើស៩០% ធៀបទៅនឹងអត្រាដែលសំរេចបានដោយរតនាគារលើការគ្រប់គ្រង ថវិកាជាតិ។ បទពិសោធន៍របស់កម្មវិធីសីលានៅថ្នាក់ឃុំបាននាំទៅដល់ការធ្វើ សហហិរញ្ញប្បទានរវាងម្ចាស់ជំនួយ និងរដ្ឋាភិបាល នៅក្នុងមូលនិធិឃុំ/សង្កាត់ ហើយបានបង្កអោយមានសម្ពាធ/ការលើកទឹកចិត្ត (ទាំងខាងរដ្ឋាភិបាល និងម្ចាស់ ជំនួយ) ក្នុងការកែលំអប្រតិបត្តិការរបស់រតនាគារនៅក្នុងការបញ្ចេញសាច់ប្រាក់របស់មូលនិធិឃុំ/សង្កាត់។ ព្រមជាមួយគ្នានេះដែរ មូលនិធិវិនិយោគខេត្តគួរតែត្រូវបានគេរៀបចំបញ្ចូលទៅក្នុងប្រព័ន្ធរបស់រដ្ឋាភិបាលតែមួយ។ គេគួរតែរក្សាមូលនិធិវិនិយោគខេត្តអោយដាច់ដោយឡែក ហើយប្រើប្រាស់វាជាគំរូធៀបមួយវាអាចមានប្រយោជន៍ ក្នុងការរួមចំណែកដល់សុខដុមនីយកម្មនៃវិនិយោគសាធារណៈ ជាងការដាក់មូលនិធិវិនិយោគខេត្តទៅក្នុងប្រព័ន្ធរតនាគារជាតិ ។

## ការពាក់ពន្ធ័របស់ក្រសួងក្នុងដំណើរការមូលនិធិវិនិយោគខេត្ត

ដូចដែលបានបញ្ជាក់ច្រើនដងក្នុងរបាយការណ៍នេះស្រាប់ អគ្គលេខាធិការដ្ឋាននៃកម្មវិធីសិលាមិនគួរប្រើឥទ្ធិពលរបស់ខ្លួនទៅលើគំរោងដែលគេបានជ្រើសរើសសំរាប់មូលនិធិវិនិយោគខេត្តនៅថ្នាក់ខេត្តឡើយ។ ក្នុងករិតដែលថ្នាក់ជាតិត្រូវដើរតួ នៅពេលនេះគឺធ្វើជាអ្នកប្រតិបត្តិដែលអាចលូកដៃដោយស្របច្បាប់លើការវិភាជន៍ធនធានដល់មន្ទីរជំនាញនានា ហើយក្រសួងជំនាញនានា អាចធ្វើអន្តរាគមន៍តាមច្បាប់ទៅលើការចាត់អាទិភាព និងប្រភេទគំរោង ដែលធ្វើដោយមន្ទីរជំនាញ។ ការរួមចំណែករបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា គឺត្រូវឆក់ឳកាសពង្រឹងទំនាក់ទំនងរវាងការរៀបចំគោលនយោបាយថ្នាក់ក្រសួងជាមួយនិងការអនុវត្តន៍គោលនយោបាយនៅថ្នាក់ខេត្ត។ ជាការពិតណាស់ថា ក្រសួងមិនសូវបានដើរតួនាទី ជាស្ថាប័នរៀបចំគោលនយោបាយទេ ប៉ុន្តែអាចធ្វើជាអ្នកទទួលការអនុវត្តន៍កិច្ចសន្យា ដែលត្រូវដើរតាមគោលនយោបាយ របស់អ្នកណាដែលផ្តល់កិច្ចសន្យាឱ្យខ្លួនដែលពេលខ្លះអាចមានការខ្វាស់គ្នា។ អ្វី១ផ្សេងទៀតដែលលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាអាចធ្វើបាន ដើម្បីជួយសំរបសំរួលដល់ក្រសួងជំនាញ ចាប់យកមកវិញនូវតួនាទីដឹកនាំ គឺត្រូវជួយធ្វើអោយប្រសើរឡើងទាំងប្រសិទ្ធិភាព និងគុណភាពជាតិ នៃគំនិតផ្តួចផ្តើមក្នុងការកាត់បន្ថយភាពក្រីក្រ។

តួនាទីដែលគេរំពឹងថាក្រសួងត្រូវទទួលយក នៅក្នុងទំនាក់ទំនងជាមួយមូលនិធិវិនិយោគខេត្ត គឺធ្វើអ្នកស្ថាបនាគោលនយោបាយ ជាទីប្រឹក្សា និងជាអ្នកតាមដានវាយតំលៃ។ ប៉ុន្តែបច្ចុប្បន្ននេះ មន្ត្រីរបស់ក្រសួងជាច្រើន

ហាក់មិនទាន់ស្គាល់ដំណើរការមូលនិធិវិនិយោគខេត្តច្បាស់នៅឡើយ។ ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត បានឱ្យចំលើយ ដូចគ្នាថា បណ្តាក្រសួងនានាមិនសូវដឹងពីថវិកាដែលមន្ទីរជំនាញខេត្តរបស់ពួកគេបានទទួល ពីការបែងចែករបស់មូលនិធិវិនិយោគខេត្តឡើយ។ នេះជាប្រការអាចយល់បាន នៅពេលដែលគេឃើញថាចំនួនថវិកាមូលនិធិវិនិយោគខេត្តសំរាប់មន្ទីរផ្សេងៗ ក្នុងខេត្តនិមួយៗនោះវាតិចតួចពេក។ ទោះជាយ៉ាងក្តី បើប្រភេទនៃការចាត់ចែងថវិកា វិសហមជ្ឈការនេះនឹងត្រូវ គ្របដណ្តប់ប្រទេសកម្ពុជា វាមានសារៈ សំខាន់ដែលក្រសួងត្រូវសិក្សាដើម្បី ផ្សារភ្ជាប់ជាមួយវា។

គំនិតផ្តួចផ្តើមមួយដែលអាចធ្វើទៅរួចដើម្បីបង្កើននូវការយល់ដឹង និងការយកចិត្តទុកដាក់របស់ក្រសួងទៅលើដំណើរការ គឺត្រូវជ្រើសរើសខេត្តមួយ ហើយអញ្ជើញតំណាងពីក្រសួងដើម្បីចូលរួមក្នុងដំណើរការទាំងមូល។ តួនាទីរបស់ពួកគេគួរត្រូវសង្កេតការ និងត្រូវផ្តល់ការណែនាំដល់មន្ទីរពាក់ព័ន្ធ។ ដូចនេះដំណើរការប្រតិបត្តិត្រូវ លើកយកមកពិភាក្សានៅក្នុងអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញ (បើអាចទៅរួចគឺដឹកនាំ និងសំរបសំរួល ដោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល) និងពិភាក្សា លើទំនាក់ទំនងក្នុងការកែទំរង់នាពេលអនាគត។ ជាពិសេស គំនិតផ្តួចផ្តើមទាំងនេះគួរត្រូវផ្តោតលើការយកចិត្តទុកដាក់នៃមូលនិធិវិនិយោគខេត្ត ក្នុងន័យព្យាយាមផ្សាភ្ជាប់មន្ត្រីជាន់ខ្ពស់របស់ ក្រសួង និងមន្ត្រីដែលមានឋានៈកណ្តាលដែលមិនមែនជាមន្ត្រីបង្គោលរបស់កម្មវិធីសិលា និងអ្នកដែលមិនទាន់ថ្មីកជាមួយដំណើរការ។ មន្ត្រីជើវតួនាទី ធ្វើផែនការ និងកសាងគោលនយោបាយ គួរជាកម្មវត្ថុនៃការងារនេះ។

**ការកំណត់មុខងារ**

រឿងមួយដែលគួរអោយភ្ញាក់ផ្អើលក្នុងកំឡុងពេលសិក្សាស្រាវជ្រាវ គឺមានសេវាខ្លះបានផ្តល់ដោយក្រសួងលើសពីមួយ។ ឧទាហរណ៍ដូចជា មន្ទីរបរិស្ថាន និងមន្ទីរកសិកម្មកំពុងផ្តល់ការគាំទ្រដល់ការបង្កើតសហគមន៍ព្រៃឈើ ហើយ មន្ទីរកិច្ចការនារី និងមន្ទីរសង្គមកិច្ចកំពុងជួយគាំទ្រការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ការធ្វើសនិទានកម្មនៃមុខងាររបស់ក្រសួងក្នុងរយៈពេលវែង និងការធានាថាការទទួលខុសត្រូវនៃបណ្តាក្រសួងផ្សេងៗគ្នា ត្រូវបានគូសព្រាងយ៉ាងហ្មត់ចត់ នោះវានឹងផ្តល់នូវវិភាគទានភាពចំណេញកាន់តែច្រើនដល់វិស័យសាធារណៈ។ នេះមិនទំនងជាអាទិភាពរយៈពេលខ្លី តែវាមានសារៈប្រយោជន៍ដោយកត់សំគាល់ថា ទិន្នន័យបំព្រួញរបស់កម្មវិធីសិលា និងទិន្នន័យផែនការអភិវឌ្ឍន៍ភូមិ ឃុំ អាចជាឧបករណ៍មានប្រយោជន៍សំរាប់ក្រុមប្រឹក្សារដ្ឋមន្ត្រី ឬក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលពេលដែលដាក់ចេញនូវការងារនេះព្រោះថា វាផ្តល់នូវប្រភេទសកម្មភាពទូទៅដែលល្អ និងដែលខុសប្លែកពីវិធី ដែលក្រសួង បន្ទីរដែលកំពុងរបាន។

**អ្វីដែលលេខាធិការដ្ឋានដឹកនាំកម្មវិធីសិលាត្រូវវាយតំលៃ**

យើងបានផ្តល់ទស្សនៈលើរបាយការណ៍នេះថា លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាមិនគួរព្យាយាមវាយតំលៃលើប្រសិទ្ធិភាព នៃគ្រប់មូលនិធិវិនិយោគខេត្តទេ។ សមត្ថភាព និងការទទួលខុសត្រូវទាំងនេះ គួរដាក់បន្ទុកលើក្រសួងជំនាញ។ ទោះជាយ៉ាងនេះក៏ដោយ វាមានកត្តាផ្សេងៗនៃកម្មវិធីសិលាដែលអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាត្រូវស្វែងរក ដើម្បីវាយតំលៃ។ នេះគឺជាការគូសបញ្ជាក់យ៉ាងទូលំទូលាយ ទៅលើការបង្កើនគុណភាពអភិបាលកិច្ចតាមរយៈវិស័យសាធារណៈ ជាមួយនិងការគូស

បញ្ជាក់យ៉ាងច្បាស់លាស់លើវិសហមជ្ឈការ និងទ្រង់ទ្រាយសហវិមជ្ឈការនៃអភិបាលកិច្ច។ ការវាយតំលៃរបស់កម្មវិធីសិលាត្រូវប្រមូលនូវប្រភេទពត៌មានដែលអាចអោយអ្នកស្ថាបនាគោលនយោបាយ និងម្ចាស់ជំនួយអាចជឿទុកចិត្តបានថាទាំងនេះ គឺពិតជាទិដ្ឋភាពជាក់ស្ដែងនៃកម្មវិធីសិលា ហើយទិដ្ឋភាពនេះពិតជាជួយគាំទ្រដល់ជនក្រីក្រ។

ទាក់ទងទៅនឹងមូលនិធិវិនិយោគខេត្ត ដូច្នេះហើយការខិតខំប្រឹងប្រែងវាយតំលៃរបស់កម្មវិធីសិលាត្រូវផ្ដោតលើគុណភាពទំនាក់ទំនងស្ថាប័ន។ តើនៅកំរិតណាដែលមានតំលាភាព គណនេយ្យភាព បង្កើនកិច្ចសំរបសំរួលនៅថ្នាក់ខេត្ត និងមានការបំភ្លឺដែលគួរទុកចិត្តបាន និងដោយមានប្រសិទ្ធភាព? ( ឧទាហរណ៍ តើអ្វីដែលជាលក្ខណៈទូទៅ និងគុណភាពនៃការគ្រប់គ្រងរបស់គណៈកម្មការអភិវឌ្ឍជនបទខេត្ត (PRDC ExCom) ជាមួយនឹងមន្ទីរដែលពាក់ព័ន្ធ ? តើអ្វីដែលជាទំហំ និងគុណភាពនៃការណែនាំ និងគាំទ្រដែលផ្ដល់អោយមន្ទីរពាក់ព័ន្ធដោយក្រសួងរបស់ពួកគេរៀងៗខ្លួន ? តើក្រុមប្រឹក្សាឃុំមានគណនេយ្យភាពកំរិតណាដែលជាជំហានដំបូងឆ្ពោះទៅរកគណនេយ្យភាព ដ៏ទូលំទូលាយសំរាប់អ្នកនៅក្នុងតំបន់ ? បើមានអភិបាលកិច្ចល្អ និងកំពុងផ្ដល់ដោយប្រសិទ្ធិភាព តើហេតុអ្វីនេះជាមូលហេតុ? តើគុណភាពអភិបាលកិច្ចពឹងផ្អែកលើបុគ្គលិក ភាពជាដៃគូនិងអភិបាលកិច្ចមូលដ្ឋានគ្រប់ខេត្តកំរិតណា? ( ឧទាហរណ៍ តើពួកគេមានតំលៃយ៉ាង សំខាន់ដោយមានសមត្ថភាពផ្ដល់ការណែនាំ ឬក៏វាចាំបាច់ផងដែរដោយមិនមានបំណងសមត្ថភាពពិនិត្យមើលដែលទ្រទ្រង់កម្មវិធី ?)។ លទ្ធផលនៃការវាយតំលៃ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិដឹកនាំការងារនៃកម្មវិធីសិលា គួរអាចផ្ដល់វិភាគទានដល់គោលនយោបាយជាតិដែលថ្លែងពីការកាត់បន្ថយភាពក្រីក្រ។

**ឆ្ពោះទៅកិច្ចសំរបសំរួលប្រទេសផ្ដល់ជំនួយ**

សេដ្ឋកិច្ចប្រទេសកម្ពុជាពឹងផ្អែកលើជំនួយ។ អ្នកផ្ដល់ជំនួយ និងហិរញ្ញប្បទានសំរាប់អភិវឌ្ឍន៍ នឹងមិនផ្ដល់ហិរញ្ញវត្ថុ តាមបណ្ដាញតែមួយក្នុងទ្រង់ទ្រាយជួយគាំទ្រផ្នែកថវិកានាពេលឥឡូវនេះទេ ពីព្រោះថាការរៀបចំផ្ដល់សេវារបស់កម្ពុជានៅមានសភាពអន់ណាស់ រីឯការគ្រប់គ្រងចំណាយសាធារណៈមិនមានដំណើរការល្អនៅឡើយទេ។ ទោះបីជាមានចំណុច សុទិដ្ឋិនិយមជាច្រើនក៏ដោយ ក៏ចំនួនវិនិយោគសាធារណៈនឹងនៅបន្តបញ្ជូនតាមរយៈគំរោងដែលស្ថាបនារួមគ្នា និងសហ-ហិរញ្ញប្បទានដោយប្រទេសផ្ដល់ជំនួយ។

ដំណើរការនៃមូលនិធិវិនិយោគខេត្តបង្កើតអោយមានឱកាស និងយន្តការសំរាប់សំរបសំរួលនិងគ្រប់គ្រងវិនិយោគសាធារណៈនៅថ្នាក់ខេត្ត។ ជាពិសេសឱកាសនេះមាននៅខែកញ្ញាដែលនឹងធ្វើឡើងនាឆ្នាំនិមួយៗ។ ជាឧទាហរណ៍ នៃការផ្ដល់ហិរញ្ញប្បទានដល់កម្មវិធីជំងឺហ៊ីវអេដស៍ HIV/AIDS ក្នុងខេត្តពោធិសាត់ និងការផ្ដល់ហិរញ្ញប្បទានដល់ប្រព័ន្ធធារាសាស្រ្តក្នុងខេត្តព្រៃវែង ក្នុងរយៈពេលសិក្សានេះបានស្រាយបំភ្លឺថា លំហូរនៃជំនួយដែលមិនអាចប៉ាន់ស្មានបានពីម្ចាស់ជំនួយធ្វើអោយផែនការមានការពិបាក និងជាលទ្ធផលធ្វើអោយការបែងចែកធនធានសំរាប់កាត់បន្ថយភាពក្រីក្រមិនគ្រប់គ្រាន់។ អគ្គលេខានៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ក៏ជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជាផងដែរ ដែលជាដងខ្លួនដែលបង្កើតឡើងដើម្បីសំរបសំរួលវិនិយោគអភិវឌ្ឍន៏នៅកម្ពុជា។ ដូច្នេះត្រូវប្រគល់តួនាទីឱ្យ លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាអោយបានល្អដើម្បីធានាថា ពត៌មានដែលផ្ដល់ដោយម្ចាស់ ជំនួយអាចអោយទៅដល់បណ្ដាខេត្តនាពេលសមស្រប និង

ពត៌មានដែលត្រូវផ្តល់អោយម្ចាស់ជំនួយទាក់ទងទៅនឹងឱកាសក្នុងការសំរបសំរួលដែលផ្តល់អោយ ដោយដំណើរការមូលនិធិវិនិយោគខេត្តនៅថ្នាក់ខេត្ត ។

សេចក្តីបង្ហាញដំបូងយ៉ាងខ្លីអំពីមូលនិធិវិនិយោគខេត្ត (ប្រហែលជាមាន ២-៤ទំព័រ) ដែលបានបញ្ជូនទៅម្ចាស់អំណោយទាំងអស់អាចមានតំលៃ ប្រសិនបើយើងគិតថាជាទូទៅម្ចាស់ជំនួយមិនបានដឹងអំពីផែនការវិសហមជ្ឈការ និងការរៀបចំបែងចែកថវិកាដែលកំពុងអនុវត្តតាមរយៈមូលនិធិវិនិយោគខេត្ត។ ជំរើសដ៏ជាក់លាក់មួយសំរាប់ការសំរបសំរួលសំរាប់ មូលនិធិវិនិយោគខេត្តជាមួយនិងម្ចាស់ជំនួយរួមមាន :

១. សហហិរញ្ញប្បទាននៃមូលនិធិវិនិយោគខេត្ត មានន័យថាថវិកាត្រូវបែងចែកទៅក្នុងមូលនិធិវិនិយោគ ខេត្ត ដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងបែងចែកទៅវិស័យដែលស្ថិតក្នុងការទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត។ វិនិយោគគួរត្រូវបានបន្ថែម ដោយជំនួយបច្ចេកទេសទៅអោយក្រសួងដោយផ្តោតលើ គោលនយោបាយ និងសមត្ថភាពនៃ ការវាយតំលៃរបស់ពួកគេ ។

២. ខណៈដែលសហហិរញ្ញប្បទានមូលនិធិវិនិយោគខេត្តមានសញ្ញាសំគាល់នៃថវិកាសំរាប់វិស័យជាក់លាក់ ។ មានន័យថា ថវិកាគួរត្រូវបែងចែកទៅតាមបណ្តាខេត្តដោយ លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា យោងទៅតាមរូបមន្តមួយ និងការចំណាយដែលស្ថិតក្រោមបែបបទការចំណាយបច្ចុប្បន្នរបស់មូលនិធិវិនិយោគខេត្ត ប៉ុន្តែ ថវិកាត្រូវចំណាយលើវិស័យដែលសំរេចដោយម្ចាស់ជំនួយ ។

៣. ការផ្តល់ថវិកាទៅខេត្ត និងវិស័យដែលបានជ្រើសរើស រួមទាំងការបង្ហាញសញ្ញាសកម្មភាពជាក់លាក់ ប៉ុន្តែការផ្តល់ថវិកាតាមរយៈលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ឬក៏តាមរយៈគណៈកម្មការអភិវឌ្ឍជនបទខេត្ត (ការប៉ាន់ស្មានការអនុវត្តន៍បច្ចុប្បន្ននេះនៃកម្មវិធីសិទ្ធិកុមារ UNICEF និងកម្មវិធីកសិកម្ម IFAD) ។

៤. ការផ្តលពត៌មានទៅតាមបណ្តាខេត្ត (នាខែកញ្ញាឆ្នាំមុន) នៃការប៉ាន់ប្រមាណការចំណាយតាមវិស័យនៅក្នុងខេត្តនោះក្នុងកំឡុងឆ្នាំបន្ទាប់មក ។សេចក្តីត្រូវការនេះគឺគ្រាន់តែជាការប៉ាន់ស្មាន និងត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីអោយគណៈកម្មាធិអភិវឌ្ឍន៍ជនបទខេត្តមានលទ្ធភាពពិចារណាពេលដែលគេធ្វើផែនការធនធានរបស់ពួកគេសំរាប់ឆ្នាំបន្ទាប់ ។

**អនុសាសន៍លើភាពក្រីក្រ និងចំណងភ្ជាប់ទៅនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ**

១. គួររក្សា ទុកយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក្នុងទំរង់ជាឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ៦៨០ របស់ក្រសួងផែនការ រហូតដល់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រត្រូវបានធ្វើបច្ចុប្បន្នភាពជាថ្មី ឬដល់ពេលដែលគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលត្រូវបានកែសំរួលឡើងវិញ ក្នុងរូបភាពដែលផ្តល់ការតំរង់ទិសជាក់លាក់ជាងមុនដល់ការធ្វើសេចក្តីសំរេចនៅថ្នាក់ខេត្ត-ក្រុង ។

២. គ.ដ.ន.ស គួរមានកិច្ចសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធានាថាម្ចាស់ជំនួយ និងអ្នកផ្តល់ហិរញ្ញប្បទាននានាសំរាប់កិច្ចអភិវឌ្ឍន៍ បានដឹងពីយន្តការសំរាប់ការសំរបសំរួលមូលនិធិជំនួយតាមរយៈ

ដំណើរការមូលនិធិវិនិយោគខេត្ត-ក្រុង និងចាត់វិធានការដើម្បីធានានូវបន្តការនេះត្រូវបានប្រើប្រាស់។ ត្រូវផ្តល់អនុសាសន៍ឱ្យម្ចាស់ជំនួយនានា បញ្ជូនមូលនិធិខ្លួនតាមរយៈមូលនិធិវិនិយោគខេត្ត-ក្រុង។

៣. ភ្ជាប់ជាមួយការបញ្ចុះបញ្ចូលឱ្យមានការពង្រឹងគោលនយោបាយ និងមុខងារវាយតំលៃ ក្នុងក្រសួងពាក់ព័ន្ធនានា គជនស គួរទាក់ទាញឱ្យមន្ត្រីកសាងគោលនយោបាយថ្នាក់ក្រសួង បានចូលរួមសកម្មក្នុងការពិភាក្សាលើគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្រ។

៤. លេខាធិការដ្ឋាននៃ គជនស គួរធ្វើការវាយតំលៃលើគុណភាពនៃអភិបាលកិច្ចក្នុងការអនុវត្តន៍ មូលនិធិវិនិយោគខេត្ត-ក្រុង ហើយប្រើប្រាស់លទ្ធផលនៃការវាយតំលៃនេះ ជាវិភាគទានក្នុងកិច្ចពិភាក្សាគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្រ។

៥. លេខាធិការដ្ឋាននៃ គ.ជ.ន.ស ត្រូវតែចែងគោលការណ៍អោយបានច្បាស់លាស់ថា កម្មវិធីសិលាមានបំណងជួយឱ្យមន្ត្រី និងស្ថាប័នពាក់ពន្ធ័នានា អាចបំពេញការទទួលខុសត្រូវក្នុងអាណត្តិការងាររបស់ខ្លួន។

៦. សំរាប់ខេត្ត-ក្រុងមួយ មន្ត្រីក្រសួងពាក់ពន្ធ័គឺជាអ្នកសង្កេតការណ៍ និងជាទីប្រឹក្សារបស់មន្ទីរខ្សែបណ្តោយដែលត្រូវចូលរួមរាល់ការប្រជុំ និងតាមការគ្រប់ដំណាក់ការ នៃការអនុវត្តន៍ មូលនិធិវិនិយោគខេត្ត-ក្រុងក្នុងឆ្នាំនិមួយៗ។

**សរុបបញ្ជីអនុសាសន៍**

បញ្ជីអនុសាសន៍នានាខាងក្រោម គឺបានលំអិតចេញមកពីផ្នែកនានាខាងលើ។ អនុសាសន៍ចំបងៗ (មានបញ្ចូលទៅក្នុងទំព័រសង្ខេប) ត្រូវបានសរសេរជិតខ្មៅ។

**អនុសាសន៍លើការវិភាជន៍នៃមូលនិធិវិនិយោគខេត្ត-ក្រុងដោយ គ.ជ.ន.ស**

១. ប្រើប្រាស់និតិវិធីវិភាជន៍ថវិកា ជាការបង្ហាញគំរូនីតិវិធីដែលមានតម្លាភាព និងសមភាពត្រៀម សំរាប់ កំណែទំរង់វិសហមជ្ឈការ។ ការវិភាជន៍នេះគួរបញ្ចូលទាំងការប្រើលក្ខណៈវិនិច្ឆ័យនៃភាពក្រីក្រផង។

២. គួរពិនិត្យរកលទ្ធភាពផ្សារភ្ជាប់មូលនិធិវិនិយោគខេត្ត-ក្រុងជាមួយនឹងចរន្តមូលនិធិផ្ទាល់របស់ ខេត្ត-ក្រុង។

៣. កំណត់រកប្រធានបទ និងសំរបសំរួលការបណ្តុះបណ្តាលដល់មន្ត្រីជាតិទាំងទ្រឹស្តី និងការអនុវត្តន៍អំពីការវិភាជន៍ថវិកាទៅអោយថ្នាក់ខេត្ត និងឃុំ (វិមជ្ឈការសារពើពន្ធ)។

៤. បញ្ជាក់ឡើងវិញឱ្យច្បាស់ថា គប្រ នៃ គ.អ.ជ.ខ អាចបន្ថែមថវិកាឱ្យមន្ទីរនានា លើមូលនិធិដែលបានកំណត់រួចហើយដោយថ្នាក់ជាតិ។

៥. ពិចារណាបញ្ចូលការចំណាយសំរាប់វិស័យផែនការក្នុងប្រភេទចំណាយប្រតិបត្តិការ ជាជាងនៅក្នុងមូលនិធិវិនិយោគខេត្ត-ក្រុង។

**អនុសាសន៍លើការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុង ដោយ គប្រ នៃ គ.អ.ជ.ខ**

១. ការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុងទាំងមូល (១០០%) ត្រូវធ្វើឱ្យបានមុនការធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក (ត្រូវកែសំរួលប្រកាសលេខ ៦៨០ របស់ក្រសួងផែនការ)។

២. ចំពោះបញ្ហា "ផ្ដល់មូលនិធិលើស" និងមន្ទីរជំនាញដែលរួញរា គួរពិភាក្សាអោយបានល្អិតល្អន់នៅ វេទិកាថ្នាក់ជាតិ ។

៣. គួពិនិត្យកែសំរួលសមាសភាពនៃគណៈកម្មាធិការប្រតិបត្តិ គ.អ.ជ.ខ ដោយពិចារណាលើការដកតំណាងមន្ទីរជំនាញចេញ ពីគណៈកម្មាធិការប្រតិបត្តិ ។

៤. បង្កើនការផ្ដល់ធនធានសំរាប់ដំណើរការត្រួតពិនិត្យតាមដាន លើការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុង (ដំណើរការតួតពិនិត្យសមាហរណកម្មផែនការថ្នាក់ស្រុក-ខណ្ឌឆ្នាំ២០០៣) ។

**អនុសាសន៍លើការកំណត់គំរោង**

១. មន្ទីរជំនាញនានាគួរត្រូវបានហាមឃាត់ក្នុងការព្យាយាមផ្សព្វផ្សាយសេវាកម្មរបស់ខ្លួនជាមុន ដើម្បីអោយឃុំ-សង្កាត់ បញ្ចូលសេវាទាំងនោះទៅក្នុងបញ្ជីគំរូវការឃុំ ។ មន្ទីរមិនត្រូវយល់ច្រលំថា ចំនួនកិច្ចព្រមព្រៀងបណ្ដោះអាសន្នដែលត្រូវផ្គូផ្គងនឹងបញ្ជីអាទិភាពរបស់ឃុំ-សង្កាត់ គឺជាសូចនាករវាយតំលៃការងារមន្ទីរទេ ហើយតួលេខ បច្ចុប្បន្នដែលបង្ហាញថាមន្ទីរឆ្លើយតបបាន ៣០% នៃតំរូវការឃុំនោះមិនជាបញ្ហាអ្វីឡើយ ។

**២. បណ្ដាមន្ទីរជំនាញខេត្ត-ក្រុង គួធ្វើយុត្តិកម្មសំរាប់ការជ្រើសរើសទីតាំងគំរោងរបស់ខ្លួន ដោយប្រើប្រាស់ផែនទីខេត្ត-ក្រុង ហើយអភិបាលស្រុកគួត្រូវបានអញ្ជើញឱ្យផ្ដល់យោបល់ និងអនុសាសន៍ (ត្រូវកែសំរួលប្រកាស លេខ៦៨០ របស់ក្រសួងផែនការ) ។**

**៣. ចំពោះសេវាសង្គមជាមូលដ្ឋាន លក្ខណៈវិនិច្ឆ័យដែលគួរប្រើសំរាប់ជ្រើសរើសទីតាំងគំរោងគឺៈ ១) កំណត់រកឃុំ-សង្កាត់ទាំងឡាយដែលនៅមិនទាន់បានទទួលសេវាក្នុងកំរិតអប្បរិមា ។ ២) ជ្រើសរើសឃុំ-សង្កាត់ដែលក្រីក្រជាងគេក្នុងចំណោមនោះដើម្បីវិនិយោគ (ត្រូវកែសំរួលប្រកាស លេខ៦៨០របស់ក្រសួងផែនការ) ។**

៤. ក្រសួងផែនការគួកំណត់ទិន្នន័យសំរាប់ចាត់ថ្នាក់ភាពក្រីក្រឃុំ-សង្កាត់ ហើយធានាអោយមាន ទិន្នន័យទាំងនោះ ក្នុងទំរង់ជាផែនទី សំរាប់គ្រប់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌទាំងអស់ ។

៥. ក្នុងពេលកំណត់រកសកម្មភាពឆ្នាំថ្មី មន្ទីរជំនាញនានាគួរពិនិត្យឡើងវិញនូវ តារាងម៉ាទ្រិចនៃអាទិភាព ស្រុក-ខណ្ឌ (DPAM) កាលពីឆ្នាំកន្លងមក (ត្រូវកែសំរួលប្រកាសរបស់ក្រសួងផែនការ លេខ ៦៨០) ។

៦. គួរផ្ដល់ឱកាសក្នុងការពង្រឹងសមត្ថភាពដល់មន្ត្រីខេត្ត-ក្រុង ដើម្បីធ្វើការវាយតំលៃតាមបែបប្រៀបធៀបលើសក្ដានុពលភាពក្នុងការកាត់បន្ថយភាពក្រីក្រ របស់ការវិនិយោគផ្សេងៗគ្នានៅក្នុងវិស័យទាំងនោះ (ឧទាៈ តាមរយៈកិច្ចពិភាក្សាតទល់ក្នុងវេទិកាអភិវឌ្ឍន៍ខេត្ត-ក្រុង) ។

**អនុសាសន៍លើប្រសិទ្ធិភាពនៃគំរោង**

១. ការវាយតំលៃការបញ្ចប់គំរោងនៃមូលនិធិវិនិយោគខេត្ត-ក្រុង គួរមានបញ្ចូលនិទ្ទេសការវាយតំលៃរួមនៃគំរោង (ល្អ/បង្គួរ/មិនអាចទទួលយកបាន) ដោយអធិប្បាយយ៉ាងសង្ខេបសំរាប់បញ្ចូលក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា (SCD) នៅ គ.ជ.ន.ស ។

**២. គ.ជ.ន.ស គួរបញ្ចុះបញ្ចូលឱ្យគ្រប់បណ្តាក្រសួង រៀបចំបង្កើតអង្គភាពវាយតំលៃ និងគោល នយោបាយ ដែលត្រូវទទួលខុសត្រូវលើការវាយតំលៃរាល់គំរោងនៅក្រោមវិស័យខ្លួន( ជាពិសេសការវាយតំលៃប្រៀបធៀបគំរោងដែលគាំទ្រដោយម្ចាស់ជំនួយផ្សេងគ្នា) ដើម្បីកសាងគោលនយោបាយវិសយ័ដែលប្រកបដោយ ភាពចុះសំរុង និងគ្រប់ជ្រុងជ្រោយ ផ្អែកលើបទពិសោធន៏ដែលមាន ។**

៣. គ.ជ.ន.ស គួរផ្អែកលើបទពិសោធន៏ខេត្ត-ក្រុង ដែលបានអនុវត្តការវាយតំលៃគំរោងឆ្នាំ២០០៣ រួចហើយ ដើម្បីពង្រីសមត្ថភាពការវាយតំលៃប្រសិទ្ធិភាពគំរោង ដល់គ្រប់ខេត្ត-ក្រុងទាំងអស់ ។

**៤. កិច្ចសន្យាសំរាប់គំរោងនានាដែលផ្តោតលើការអភិវឌ្ឍន៏សេដ្ឋកិច្ច គួររួមបញ្ចូលនូវការគណនាសាមញ្ញអំពីប្រសិទ្ធិភាពសេដ្ឋកិច្ច ។ ការសិក្សានេះអាចគិតក្នុងករិតប្រហាក់ប្រហែលដោយមានទាំងការ ប៉ាន់ស្មានតំលៃ និងផលប្រយោជន៏ (តំលៃវិនិយោគ ទិន្នផល ថ្លៃទីផ្សារ តំលៃប្រតិបត្តិការ និងការរំលោះ) សំរាប់ជាមូលដ្ឋានដល់ការវាយតំលៃ និងដកពិសោធន៏ ។**

៥. គ.ជ.ន.ស គួរពិនិត្យរកកាលានុវត្តភាពក្នុងការផ្តួចផ្តើមសិក្សាស្រាវជ្រាវឯករាជ្យមួយក្នុងការកសាងជាសេចក្តីណែនាំអំពីកាលវេលាសមស្របសំរាប់មន្ត្រីខេត្ត-ក្រុង ចេញមុខដឹកនាំសំរបសំរួលរៀបចំ សហគមន៏ មូលដ្ឋាន ដើម្បីការពារសិទ្ធរបស់ប្រជាពលរដ្ឋក្រីក្រ ទៅលើធនធានធម្ម ជាតិ ។

៦. គប្រ នៃគ.អ.ជ.ខ គួរបានទទួលការគាំទ្រតទៅទៀត ដើម្បកែសំរួលឈ្មោះលទ្ធផលកិច្ចសន្យាអោយមានលក្ខណៈច្បាស់លាស់ និងអាចវាស់បាន (ឧទា: សង្ខេបចំណេះដឹងឬជំនាញសំខាន់ៗ ដែលត្រូវ ផ្ទេរជាជាងការសរសេរមិនច្បាស់ "កសាងសមត្ថភាពលើ.........") ។

**អនុសាសន៍លើការតាមដានកិច្ចព្រមព្រៀងបណ្តោះអាសន្ន**

១. អ្ន កផ្តល់សេវាចាំបាច់ត្រូវតែផ្តល់ពតិមានជាលាយលក័្ខអក្សរទៅដល់មេឃុំ-ចៅសង្កាត់ពីការបានអនុវត្តចប់ ឬនិរាករណ៏កិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងបណ្តោះអាសន្នគួរមានកូឡោនបន្ថែម សំរាប់អ្នកផ្តល់សេវាបំពេញពតិមានថែមនៅពេលក្រោយ ។

២. គួរបញ្ជាក់ឱ្យមេឃុំ-ចៅសង្កាត់ យល់ច្បាស់ថា សិក្ខាសាលាសមាហរណកម្មផែនការស្រុក គឺជាឱកាសសំរាប់ពួកគាត់ទាក់ទាញអ្នកផ្តល់សេវានានាឱ្យទទួលខុសត្រូវ ហើយបញ្ជ្រាបទៅក្នុងការ គិតគូររបស់ពួកគេនូវគំនិតសំរាប់រយៈពេលវែង និងការសំរេចចិត្តផ្តល់គំរោង (មិនគួរសន្មតិថា មេឃុំ-ចៅសង្កាត់ សុទ្ធតែយល់ដឹងប្រការទាំងនេះរួចហើយនោះទេ ព្រោះមានមេឃុំមួយចំនួនគឺ មិនដឹងទាល់តែសោះ) ។

**អនុសាសន៍លើការពង្រឹងទំនាក់ទំនងរវាងមូលនិធិឃុំ-សង្កាត់(CSF)និងមូលនិធិវិនិយោគខេត្ត-ក្រុង (PIF)**

១. លេ ខាធិការដ្ឋាននៃ គ.ជ.ន.ស មិនគួរព្យាយាមជំរុញ ការបំពេញឱ្យគ្នារវាង CSF និង PIF ទេ ហើយក៏មិនគួរទាមទារឱ្យប្រើ PIF សំរាប់តែប្រភេទគំរោងមិនមែនហេដ្ឋារចនាសម្ពន្ធ័នោះឡើយ ។ គ.ជ.ន.ស គួរជំរុញ ឱ្យក្រសួងនានាផ្តល់គោលនយោបាយណែនាំសមស្របសំរាប់មន្ទីរជាខ្សែបណ្តោយ ។

២. គ្រប់មន្ទីរជំនាញដែល មានសក្តានុពលរួមចំណែកកាត់បន្ថយភាពក្រីក្រ គួរបានទទួលការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុង ជារៀងរាល់ឆ្នាំ (លើកលែងមន្ទីរដែលបានមូលនិធិពីប្រភព ផ្សេងហើយ ដូចជា IFAD ឬកម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF)។

៣. គ្រប់ស្រុក-ខណ្ឌនៅក្នុងខេត្ត-ក្រុងទាំងអស់គួរបានទទួលវិនិយោគមួយចំនួនពីមូលនិធិវិនិយោគ ខេត្ត-ក្រុង ជារៀងរាល់ឆ្នាំ ដើម្បីធានាការបង្កើនសមត្ថភាពឃុំ-សង្កាត់ និងស្រុក-ខណ្ឌទាំងអស់ ក្នុងកិច្ចសំរបសំរួលជាមួយមន្ទីរ និងធ្វើសំនើគំរោងចំពោះមន្ទីរជំនាញនានា។

៤. ក្រុមប្រឹក្សាឃុំ-សង្កាត់ គួរត្រូវបានណែនាំច្បាស់លាស់ថា ពួកគាត់មានសិទ្ធិ និងការទទួលខុសត្រូវ ក្នុងការធានាលើគុណភាពគំរោងនៃមូលនិធិវិនិយោគខេត្ត-ក្រុង ចំពោះមុខពលរដ្ឋក្នុងឃុំ (ពង្រីកតួនាទីនេះ ដែលបង្ហាញថាកំណែទំរង់វិមជ្ឈការ គឺសំដៅគាំពារដល់គំរោងដែលការអនុវត្តន៏នៅក្នុងឃុំ-សង្កាត់ ទោះបីជាមិនមែន គំរោងរបស់ឃុំ-សង្កាត់ផ្ទាល់ក្តី)។

៥. យន្តការសំរាប់ជួយក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការប្រើសិទ្ធិលើការអនុវត្តមូលនិធិវិនិយោគ ខេត្ត-ក្រុង គួរត្រូវបានពង្រឹងថែមទៀត។ ក្រុមប្រឹក្សាឃុំ-សង្កាត់ គួរត្រូវបានអញ្ជើញឱ្យចូលរួមគ្រប់ ការដេញថ្លៃគំរោងដែលទាក់ទងនឹងឃុំខ្លួន តំលៃបាន់ស្មានគួរត្រូវសរសេរក្នុងកិច្ចព្រមព្រៀង បណ្តោះអាសន្ន ផែនការការងារ និងថវិកានៃអនុកិច្ចសន្យាក្រោមគប្រ គ.អ.ជ.ខ ត្រូវថតចំលង ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រោយពេលអនុមត័រួចភ្លាម។ ធ្វើដូច្នេះ ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងយល់ច្បាស់ពីមុខងារ ជាក់លាក់ក្នុងការវាយតំលៃបញ្ចប់គំរោងនានា។

## អនុសាសន៍លើភាពក្រីក្រ និងចំណងភ្ជាប់ទៅនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

១. គួររក្សា ទុកយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក្នុងទំរង់ជាឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ២៦៨០ របស់ក្រសួងផែនការ រហូតដល់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រត្រូវបានធ្វើបច្ចុប្បន្នភាពជាថ្មី ឬដល់ពេលដែលគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលត្រូវបានកែសំរួលឡើងវិញ ក្នុងរូបភាពដែលផ្តល់ការតំរង់ទិសជាក់លាក់ជាងមុនដល់ការធ្វើសេចក្តីសំរេចនៅថ្នាក់ខេត្ត-ក្រុង។

**២. គ.ជ.ន.ស គួរមានកិច្ចសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធានាថាម្ចាស់ជំនួយ និងអ្នកផ្តល់ហិរញ្ញប្បទាននានាសំរាប់កិច្ចអភិវឌ្ឍន៍ បានដឹងពីយន្តការសំរបសំរួលមូលនិធិជំនួយ តាមរយៈដំណើរការមូលនិធិវិនិយោគខេត្ត-ក្រុង និងចាត់វិធានការដើម្បីធានាឱ្យយន្តការនេះត្រូវបានប្រើប្រាស់។ ត្រូវផ្តល់អនុសាសន៍ឱ្យម្ចាស់ជំនួយនានា បញ្ជូនមូលនិធិខ្លួនតាមរយៈមូលនិធិ វិនិយោគខេត្ត-ក្រុង។**

៣. ភ្ជាប់ជាមួយការបញ្ចុះបញ្ចូលឱ្យមានការពង្រឹងគោលនយោបាយ និងមុខងារវាយតំលៃក្នុងក្រសួងពាក់ព័ន្ធនានា គ.ជ.ន.ស គួរទាក់ទាញឱ្យមន្ត្រីកសាងគោលនយោបាយថ្នាក់ក្រសួងបានចូលរួមសកម្ម ក្នុងការពិភាក្សាលើគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្រ។

៤. លេខាធិការដ្ឋាននៃ គ.ជ.ន.ស គួរធ្វើការវាយតំលៃលើគុណភាពនៃអភិបាលកិច្ចក្នុងការអនុវត្តន៍មូលនិធិខេត្ត-ក្រុង ហើយប្រើប្រាស់លទ្ធផលនៃការវាយតំលៃនេះ ជាវិភាគទានក្នុងកិច្ចពិភាក្សា គោលនយោបាយជាតិកាត់បន្ថយភាពក្រីក្រ ។

៥. លេខាធិការដ្ឋាននៃ គ.ជ.ន.ស ត្រូវតែថែងគោលការណ៍អោយបានច្បាស់លាស់ថា កម្មវិធីសិលាមានបំណងជួយឱ្យមន្ត្រី និងស្ថាប័នពាក់ពន្ធ័នានា អាចបំពេញការទទួលខុសត្រូវក្នុងអាណត្តិការងាររបស់ខ្លួន ។

៦. សំរាប់ខេត្ត-ក្រុងមួយ មន្ត្រីក្រសួងពាក់ពន្ធ័គឺជាអ្នកសង្កេតការណ៍ និងជាទីប្រឹក្សារបស់មន្ទីរខ្សែបណ្តោយ ដែលត្រូវចូលរួមរាល់ការប្រជុំ និងតាមកគ្រប់ដំណាក់ការនៃការអនុវត្តន៍មូលនិធិវិនិយោគខេត្ត-ក្រុង ក្នុង ឆ្នាំនិមួយៗ ។